មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែវិច្ឆិកា ឆ្នាំ២០២១

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា
# ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍

## របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)



## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

របាយការណ៍ស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ("របាយការណ៍") ជាការបោះពុម្ពផ្សាយរបស់គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលអនុវត្តដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

ចក្ខុវិស័យរបស់ ម.ស.ម.ក គឺ ចង់ឃើញប្រទេសកម្ពុជាមានសន្តិភាពដែលពលរដ្ឋគ្រប់រូបអាចទទួលបានសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។

ស្លាកសញ្ញារបស់ ម.ស.ម.ក មាន រូបសត្វស្លាបពណ៌ស កំពុងហើរបំបែកចេញពីរង្វង់មូលពណ៌ផ្ទៃមេឃដែលមានន័យថា គឺជាការទាមទារសេរីភាពនៅកម្ពុជា។

### ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org។

របាយការណ៍នេះ និងឯកសារបោះពុម្ពផ្សាយផ្សេងៗ អាចស្វែងរកបាននៅលើមូលដ្ឋានទិន្នន័យសង្កេតការណ៍ការជំនុំជម្រះរបស់ ម.ស.ម.ក តាមរយៈ www.tmp.sithi.org គេហទំព័រ www.cchrcambodia.org និងនៅលើ គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា តាមរយៈ www.sithi.org។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖

ផ្ទះលេខ ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរស័ព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

ទូរសារ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០២

cc BY NC SA

# មាតិកា


**មាតិកា** ........ 2

**តារាងតួលេខ** ........ 5

**បញ្ជីអក្សរកាត់** ........ 6

**ខ្លឹមសារសង្ខេប** ........ 8

**១. សេចក្តីផ្តើម** ........ 13

១.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ........ 13

*១.១.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ ........ 13*

*១.១.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ ........ 14*

១.២ វិសាលភាព និងវិធីសាស្ត្រ ........ 21

**២. ទិដ្ឋភាពទូទៅ** ........ 26

**៣ .សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព** ........ 29

៣.១ សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ........ 29

៣.២ សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ ........ 31

៣.៣ ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (គោលការណ៍នៃនីត្យានុកូលភាព) ........ 33

៣.៤ ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល ........ 34

**៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនទាន់ត្រូវបានគោរពពេញលេញ** ........ 36

៤.១ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ........ 36

៤.២ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ........ 40

៤.៣ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ........ 42

៤.៤ សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ ........ 46

៤.៥ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........ 52

៤.៦ សិទ្ធិបង្ហាញភស្តុតាង ........ 56

៤.៧ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ........ 60

៤.៨ សិទ្ធិរបស់អនីតិជន ..... 63

**៥. ឆ្នាំ២០១៤-២០២០៖ ការវិវឌ្ឍនៃការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌** ..72

៥.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព ..... 72

៥.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនទាន់ត្រូវបានគោរពពេញលេញ ..... 74

*៥.២.១ បម្រែបម្រួល៖ ពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពទៅជាមិនបានគោរពពេញលេញ ..... 74*

*៥.២.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញចាប់តាំងពីឆ្នាំ ២០១៤ មក ..... 80*

**៦.សេចក្តីសន្និដ្ឋាន** ..... 82

**៧. អនុសាសន៍** ..... 84

៧.១ អនុសាសន៍ទូទៅ ..... 84

៧.២ អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ..... 85

៧.៣ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ..... 85

៧.៤ អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ..... 85

៧.៥ អនុសាសន៍ទាក់ទងនឹងសិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ ..... 85

៧.៦ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ..... 86

៧.៧ អនុសាសន៍ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាង ..... 86

៧.៨ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ..... 87

៧.៩ អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់អនីតិជន ..... 87

**៨. គន្លឹះនិទ្ទេស** ..... 90

៨.១ នីតិជាតិ ..... 90

៨.២ លិខិតូបករណ៍គោលនយោបាយកម្ពុជា ..... 90

៨.៣ នីតិអន្តរជាតិ ..... 90

៨.៤ ករណីសិក្សាច្បាប់ ..... 92

៨.៥ ទ្រឹស្តី ..... 94

៨.៦ សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌ ..... 94

៨.៧ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ..... 95

៨.៨ ផ្សេងៗ ........ 95

**៩. ឧបសម្ព័ន្ធ** ........ 96

ឧបសម្ព័ន្ធទី១៖ តារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ ........ 96

ឧបសម្ព័ន្ធទី២៖ ក្រមសីលធម៌អ្នកសង្កេតការណ៍សវនាការ ........ 113

# តារាងតួលេខ

តួលេខទី ១៖ ទិដ្ឋភាពទូទៅអំពីសំណុំរឿងដែលត្រូវបានសង្កេតការណ៍ដោយ ម.ស.ម.ក (ឆ្នាំ២០១៧-២០២០) ...22
តួលេខទី ២៖ ទិដ្ឋភាពទូទៅអំពីសំណុំរឿងដែលត្រូវបានសង្កេតការណ៍ដោយ ម.ស.ម.ក នៅឆ្នាំ២០១៩/២០២០ ...27
តួលេខទី ៣៖ សវនាការនៅសាលាឧទ្ធរណ៍ដែលត្រូវបានសង្កេតការណ៍ – បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ.........27
តួលេខទី ៤៖ ភាគីធ្វើបណ្ដឹងឧទ្ធរណ៍ ..........28
តួលេខទី ៥៖ សិទ្ធិទទួលបានការប្រកាសសេចក្ដីសម្រេចជាសាធារណៈ ..........34
តួលេខទី ៦៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ..........39
តួលេខទី ៧៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ..........42
តួលេខទី ៨៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ -ទិដ្ឋភាពទូទៅ ..........45
តួលេខទី ៩៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - លម្អិត..........45
តួលេខទី ១០៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - ការរំលោភ ..........46
តួលេខទី ១១៖ សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ..........49
តួលេខទី ១២៖ ការពន្យល់ប្រាប់សិទ្ធិ ..........51
តួលេខទី ១៣៖ សិទ្ធិនៅស្ងៀម ..........53
តួលេខទី ១៤៖ ការសន្និដ្ឋានទុកជាមុនថាគ្មានទោស..........55
តួលេខទី ១៥៖ ការរំលោភនៃសំណុំរឿងដែលសាលដីកាពុំផ្ដល់សំអាងហេតុគ្រប់គ្រាន់ (ឆ្នាំ២០១៤-២០២០).........62
តួលេខទី ១៦៖ អាយុជនជាប់ចោទនៅពេលបទល្មើសកើតឡើង..........67
តួលេខទី ១៧៖ ភាគរយជនជាប់ចោទជាអនីតិជនត្រូវបានឃុំខ្លួន (ឆ្នាំ២០១៤-២០២០) ..........68
តួលេខទី ១៨៖ ការការពារឯកជនភាពរបស់អនីតិជន..........69
តួលេខទី ១៩៖ ការរំលោភសិទ្ធិក្នុងការជួបពិភាក្សាជាមួយមេធាវីមុនពេលជំនុំជម្រះ(ឆ្នាំ២០១៤-២០២០) ..........72
តួលេខទី ២០៖ ការប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀម (ឆ្នាំ២០១៤-២០២០)..........74
តួលេខទី ២១៖ ភាគរយនៃជនជាប់ចោទដែលបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានអ្នកទោស (២០១៤-២០២០)..........75
តួលេខទី ២២៖ ការរំលោភនៃសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ (ឆ្នាំ២០១៤-២០២០) .....76
តួលេខទី ២៣៖ ការរំលោភនៃសិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ (ឆ្នាំ២០១៤-២០២០)..........77
តួលេខទី ២៤៖ ការប្រាប់ និងពន្យល់អំពីសិទ្ធិមានមេធាវី ឬការការពារខ្លួនឯង (ឆ្នាំ២០១៤-២០២០) ..........78
តួលេខទី ២៥៖ ការរំលោភនៃសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព (ឆ្នាំ២០១៤-២០២០) ..........79
តួលេខទី ២៦៖ ភាគរយនៃជនជាប់ចោទជាអនីតិជនដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន (ឆ្នាំ២០១៤-២០២០) ..80
តួលេខទី ២៧៖ ភាគរយនៃសំណុំរឿង ដែលមានវិធានការការពារឯកជនភាពរបស់អនីតិជន (ឆ្នាំ២០១៤-២០២០) ..........80

# បញ្ជីអក្សរកាត់

| | |
|---|---|
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍ប្រើដោយអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ដើម្បីកត់ត្រាទិន្នន័យសវនាការនៅពេលសង្កេតការណ៍ |
| ការណែនាំអំពីតារាងសង្កេតការណ៍ | ឯកសារណែនាំលម្អិតដើម្បីជួយដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ឱ្យមានការយល់ច្បាស់លាស់ចំពោះសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍ |
| ក្រមសីលធម៌ | ឯកសារកំណត់អំពីកាតព្វកិច្ចនានានៃការមិនជ្រៀតជ្រែក គោលបំណងមិនលម្អៀង និងការសម្ងាត់ដែលចងជាកាតព្វកិច្ចដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| សាលាឧទ្ធរណ៍ | សាលាឧទ្ធរណ៍ភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា |
| អ.ស.ក | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក រក្សាទុកទិន្នន័យសវនាការ ដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍ |
| អ.វ.ត.ក | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| ECHR | តុលាការសិទ្ធិមនុស្សអឺរ៉ុប |
| HRC | គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| មិនដឹង | ព័ត៌មានដែលមិនទទួលបាន ឬមិនបានតាមដានបន្ត |
| មិនពាក់ព័ន្ធ | ទិន្នន័យមិនពាក់ព័ន្ធ |
| ក.ស.ម.រ.ប | ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស និងវិទ្យាស្ថានប្រជាធិបតេយ្យ |
| ការិយាល័យឧត្តមស្នងការ | ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ |
| អ.ស.ស.អ | អង្គការសម្រាប់សន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| គម្រោង | គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក |

| | |
|---|---|
| អំឡុងពេលធ្វើរបាយការណ៍ | ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១៩ ដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| អ្នកសង្កេតការណ៍ | អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក |
| ស.ស.ស.ម | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| យូនីសេហ្វ | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| អ្នករាយការណ៍ពិសេស | អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា |
| អ៊ុនតាក់ | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា |
| ច្បាប់អ៊ុនតាក់ | បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលឆ្នាំ ១៩៩២ |

# ខ្លឹមសារសង្ខេប

មុខងារនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅតែមានចំណុចជាច្រើនដែលត្រូវកែលម្អធ្វើឲ្យប្រសើរឡើង។ មានមតិរិះគន់មួយចំនួនដូចជា កង្វះឯករាជ្យភាព ការទទួលបានមេធាវីមិនគ្រប់គ្រាន់ ពន្ធនាគារមានភាពចង្អៀតណែន ការប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្នលើសការកំណត់ និងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ដើម្បីកំណត់គោលដៅទៅលើសំឡេងរិះគន់ជាដើម។

រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានបង្ហាញអំពីការប្ដេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហារិះគន់ទាំងនេះ ហើយនៅក្នុងឆ្នាំ២០២០ រដ្ឋាភិបាលបានកែលម្អនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងនោះរួមមានការបង្កើតតុលាការសាលាឧទ្ធរណ៍ថ្មីចំនួនបីនៅក្នុងខេត្តត្បូងឃ្មុំ ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ[1] ដើម្បីកែលម្អការទទួលបានយុត្តិធម៌នៅទូទាំងប្រទេស ចាត់វិធានការដើម្បីពង្រឹងការទទួលបានជំនួយផ្នែកច្បាប់នៅតំបន់ជនបទដាច់ស្រយាល[2] និងខិតខំប្រឹងប្រែងកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ។[3]

នៅចន្លោះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ("អំឡុងពេលធ្វើរបាយការណ៍") គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ("គម្រោង") បានធ្វើការសង្កេតការណ៍សវនាការព្រហ្មទណ្ឌចំនួន ២០៣ ករណីនៅសាលាឧទ្ធរណ៍ ("តុលាការ") ដើម្បីវាយតម្លៃអំពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សាលាឧទ្ធរណ៍ដូចដែលបានចែងនៅក្នុងច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ របាយការណ៍នេះបង្ហាញ និងវិភាគទៅលើទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលធ្វើរបាយការណ៍ ហើយក៏មានគោលបំណងរួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការផ្លាស់ប្ដូរជាវិជ្ជមាននៅក្នុងប្រទេសកម្ពុជាផងដែរ។

របាយការណ៍នេះមានរចនាសម្ព័ន្ធដូចខាងក្រោម៖

**សេចក្ដីផ្ដើម៖** ផ្ដល់ទិដ្ឋភាពសង្ខេបអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលពាក់ព័ន្ធមុននឹងឈានដល់ការកំណត់វិសាលភាព វិធីសាស្ត្រ និងគោលបំណងនៃរបាយការណ៍នេះ។

**ទិដ្ឋភាពទូទៅ៖** រៀបរាប់នូវទិន្នន័យដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះដូចជា ចំនួនសំណុំរឿងដែលបានសង្កេតការណ៍ និងចំនួនជនជាប់ចោទដែលជាប់ពាក់ព័ន្ធ។

**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព៖** កំណត់ថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាខ្លះត្រូវបានគោរពនៅសាលាឧទ្ធរណ៍តាមរយៈការវិភាគទិន្នន័យដែលបានប្រមូលនៅក្នុងអំឡុងពេល

[1] វ៉ន ដារ៉ា "សាលាឧទ្ធរណ៍តំបន់ចំនួន ៣ នឹងចាប់ផ្ដើមដំណើរការជំនុំជម្រះរឿងក្ដីនៅថ្ងៃទី ១ ខែមេសា" (ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០២០) https://bit.ly/2SkdqME ។

[2] ខាន់ ច័ន្ទវីរៈ "ក្រសួងគ្រោងនឹងបញ្ជូនមេធាវីទៅថ្នាក់មូលដ្ឋាន ដើម្បីជួយដោះស្រាយបញ្ហា" (ខ្មែរថាមស៍ ថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០២០) https://www.khmertimeskh.com/50772904/ministry-plans-to-deploy-lawyers-at-local-levels-to-help-resolve-issues/

[3] វី សុចន្ទ "លោក ស ខេង និយាយថាករណីជនជាប់ឃុំគួរត្រូវយកជាអាទិភាព" (ខ្មែរថាមស៍, ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០) https://www.khmertimeskh.com/50753633/kheng-says-detainee-cases-should-be-given-priority/; តាំង វីដា, "យុទ្ធនាការរយៈពេលប្រាំមួយខែ ក្នុងការពន្លឿនការកាត់ក្ដី៖ ក្រសួងយុត្តិធម៌" (ខ្មែរថាមស៍, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០) https://www.khmertimeskh.com/706199/six-month-campaign-to-speed-up-cases-justice-ministry/

សង្កេតការណ៍របស់ម.ស.ម.ក ហើយទន្ទឹមនឹងនោះក៏គូសបញ្ជាក់អំពីនិន្នាការសំខាន់ៗទាក់ទងនឹងការគោរពបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សាលាឧទ្ធរណ៍ផងដែរ បើប្រៀបធៀបទៅនឹងទិន្នន័យប្រមូលបានចាប់តាំងពីខែកក្កដា ឆ្នាំ២០១៤ មក។ សិទ្ធិនីមួយៗ ត្រូវបានលើកយកមកពិភាក្សានៅក្នុងអនុផ្នែកដាច់ដោយឡែកពីគ្នា ហើយក៏បានកំណត់បញ្ញត្តិនៃច្បាប់ក្នុងប្រទេសនិងអន្តរជាតិពាក់ព័ន្ធ ក៏ដូចជាពន្យល់អំពីអត្ថន័យនៃសិទ្ធិជាក់លាក់ផងដែរ។

**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនត្រូវបានគោរពពេញលេញ៖** គូសបញ្ជាក់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនត្រូវបានគោរពពេញលេញនៅសាលាឧទ្ធរណ៍ ដោយបង្ហាញអំពីទិន្នន័យ សំខាន់ៗដែលបានប្រមូលនៅក្នុងអំឡុងពេលសង្កេតការណ៍របស់ ម.ស.ម.ក។ ការវិវឌ្ឍនៃការអនុលោមនូវសិទ្ធិទាំងនេះដោយគិតពីឆ្នាំ២០១៤ មក ក៏ត្រូវបានលើកមកពិភាក្សាផងដែរ។ សិទ្ធិនីមួយៗត្រូវបានលើកយកមកពិភាក្សាគ្នានៅក្នុងអនុផ្នែកដាច់ដោយឡែកពីគ្នា ដែលបានកំណត់ក្នុងបទប្បញ្ញត្តិនៃច្បាប់ជាតិនិងអន្តរជាតិពាក់ព័ន្ធ ក៏ដូចជាពន្យល់អំពីអត្ថន័យនៃសិទ្ធិជាក់លាក់ផងដែរ។

**ឆ្នាំ២០១៤-២០២០៖ ការវិវឌ្ឍនៃការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖** បង្ហាញអំពីការវិវឌ្ឍនៃការការពារ ឬកង្វះខាតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ការវិវឌ្ឍមួយចំនួនបានធ្វើឡើងចាប់តាំងពីឆ្នាំ២០១៤ មក ហើយខ្លះទៀតវិវឌ្ឍន៍ពីការមិនបានការពារ ទៅជាមិនបានគោរពតាមពេញលេញ ហើយមួយចំនួនផ្សេងទៀតគឺត្រូវបានរំលោភបំពានជាប់ជានិច្ចចាប់តាំងពីឆ្នាំ២០១៤ មក។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** រួមមានអនុសាសន៍ដាក់ជូនចំពោះអង្គភាព និងស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងវិស័យយុត្តិធម៌ រួមទាំងរដ្ឋាភិបាល ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ អាជ្ញាធរអនុវត្តច្បាប់ និងអាជ្ញាធរពន្ធនាគារ។

របាយការណ៍នេះបានបង្ហាញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួនត្រូវបានធានានៅមុខសាលាឧទ្ធរណ៍រួមមាន សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលានិងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ។ លើសពីនេះទៅទៀត សាលាឧទ្ធរណ៍បានការពារយ៉ាងស៊ីសង្វាក់នូវការការពារប្រឆាំងនឹងការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល និងការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់។

| សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពនៅសាលាឧទ្ធរណ៍ |
| --- |
| • សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី |
| • សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ |
| • ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ |
| • ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល |

ប៉ុន្តែគួរឱ្យសោកស្តាយ ការសង្កេតការណ៍ក៏បានរកឃើញកង្វះការអនុលោមតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានមួយចំនួនផងដែរ។ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាពត្រូវបានចាត់ថ្នាក់ថាមិនត្រូវបានគោរពពេញលេញ ដោយហេតុថានៅតែមានជនជាប់ចោទជាច្រើនដែលអះអាងថាពួកគេទទួលរងនូវអំពើហិង្សា ឬការធ្វើទារុណកម្ម ដើម្បីបង្ខំឱ្យពួកគេសារភាពថាបានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ (ជនជាប់ចោទចំនួន ១៧ នាក់ក្នុងចំណោម ២៥៥ នាក់)។ សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ ដោយសារមានតែសវនាការចំនួន ៣១ ប៉ុណ្ណោះក្នុងចំណោមសវនាការដែល ម.ស.ម.ក បានសង្កេតការណ៍មានបិទកាលវិភាគសវនាការនៅលើក្តារខៀននៅខាងក្រៅបន្ទប់សវនាការ។ លើសពីនេះ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់បន្តត្រូវបានចាត់ទុកថា មិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ ដោយសារតែភាគរយនៃសំណុំរឿង ដែលជនជាប់ចោទត្រូវបានប្រាប់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ បើទោះបីជាមានភាពប្រសើរចាប់តាំងពីការសង្កេតការណ៍កាលឆ្នាំមុនក៏ដោយ នៅមិនទាន់មានភាពគ្រប់គ្រាន់នោះទេ (មានតែ ៦៧,៤% នៅក្នុងឆ្នាំ២០១៨/២០១៩ និង៧៨,៣% នៅអំឡុងពេលធ្វើរបាយការណ៍នេះ)។ សិទ្ធិមានមេធាវីជានិច្ចជាកាលមិនទាន់ត្រូវបានគោរពៈ ប្រហែលចំនួន ២៨% នៃជនជាប់ចោទពុំមានមេធាវីតំណាងឡើយ។

ជាងនេះទៅទៀត សំណុំរឿងចំនួន ១៥ នៅក្នុងចំណោមសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ ចៅក្រមពុំបានប្រាប់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីឡើយ ដែលនេះគឺជានិន្នាការគួរឱ្យព្រួយបារម្ភមួយ។ ស្រដៀងគ្នានេះដែរ ការសន្មតទុកជាមុនថាគ្មានទោសនៅតែមិនទាន់ត្រូវបានគោរពពេញលេញ ដោយចៅក្រមមិនបានប្រាប់ជនជាប់ចោទចំនួន ២៥.៦% នៃជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ ហើយចំនួន ២៨,២% នៃជនជាប់ចោទបានបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានដូចគ្នាទៅនឹងឯកសណ្ឋានរបស់ទណ្ឌិតដែរ។ ជាចុងក្រោយ សិទ្ធិរបស់ជនជាប់ចោទជាអនីតិជនដែលត្រូវបានការពារជាពិសេសនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់ជាតិកម្ពុជា ជារឿយៗក៏ត្រូវបានព្រងើយកន្តើយផងដែរ ដោយពុំមានវិធានការពិសេសណាមួយត្រូវបានដាក់ឱ្យអនុវត្តដើម្បីការពារសិទ្ធិរបស់អនីតិជនឡើយ ជាពិសេសឯកជនភាពរបស់ពួកគេតែម្តង។

| **សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនទាន់ត្រូវបានគោរពពេញលេញនៅសាលាឧទ្ធរណ៍** |
|---|
| • **សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព** |
| • **សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ** |
| • **សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់** |
| • **សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ** |
| • **សិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ** |

| |
|---|
| • **សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស** |
| • **សិទ្ធិបង្ហាញភស្តុតាង** |
| • **សិទ្ធិរបស់អនីតិជន** |

របាយការណ៍នេះធ្វើការប្រៀបធៀបទិន្នន័យឆ្នាំនេះជាមួយនឹងទិន្នន័យឆ្នាំ ២០១៤/២០១៥ ឆ្នាំ២០១៦/ ២០១៧ ឆ្នាំ២០១៧/២០១៨ និងឆ្នាំ២០១៨/១៩ ផងដែរ ដើម្បីកំណត់និន្នាការ និងវិភាគការវិវឌ្ឍនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា[4]។ ថ្វីបើការរកឃើញភាគច្រើនមានភាពប្រហាក់ប្រហែលគ្នាក៏ដោយ ក៏មានចំណុចចំនួនពីរបានលេចឡើងផងដែរ។

ទីមួយ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ដែល ម.ស.ម.ក បានរកឃើញថាត្រូវបានការពារនៅក្នុងឆ្នាំ២០១៤/២០១៥ និងឆ្នាំ២០១៦/២០១៧ ត្រូវបានប្តូរទៅផ្នែក "មិនទាន់ត្រូវបានគោរពពេញលេញ" នៅក្នុងឆ្នាំ២០១៧/២០១៨ និង២០១៨/២០១៩។ ការសង្កេតការណ៍នៅឆ្នាំនេះបានបង្ហាញថា សិទ្ធិនេះមិនទាន់បានគោរពពេញលេញ៖ ទោះបីជាចៅក្រមបានប្រាប់អំពីការចោទប្រកាន់ពាក់ព័ន្ធទាំងអស់ប្រឆាំងនឹងជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿងចំនួន ៧៨,៣% ដែលចំនួននេះមានការកើនឡើង គួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងចំនួន ៦៧,៤% នៅក្នុងឆ្នាំ២០១៨/២០១៩ ម.ស.ម.ក បានកត់សម្គាល់អំពីការធ្លាក់ចុះភាគរយនៃសំណុំរឿងដែលចៅក្រមបានប្រាប់អំពីច្បាប់ពាក់ព័ន្ធទីកន្លែង និងបទល្មើស និងភាគីពាក់ព័ន្ធ បើប្រៀបធៀបនឹងអំឡុងពេលធ្វើរបាយការណ៍កាលពីមុន។

ទីពីរ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព (ក៏ត្រូវបានស្គាល់ថាជាការការពារខ្លួនប្រឆាំងនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯង) បន្ទាប់ពីត្រូវបានចាត់ទុកថាត្រូវបានការពារនៅឆ្នាំ២០១៧/២០១៨ ត្រូវបានចាត់ចំណាត់ថ្នាក់ឡើងវិញថាមិនទាន់ត្រូវបានគោរពពេញលេញនៅឆ្នាំ២០១៨/២០១៩ នៅពេលដែលចំនួន ៤,៣% នៃជនជាប់ចោទបានលើកឡើងថាការសារភាពរបស់ខ្លួនត្រូវបានទទួលតាមរយៈអំពើហិង្សា ឬទារុណកម្ម។ នៅអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ អត្រានេះបានកើនឡើងម្តងទៀត ដោយមានជនជាប់ចោទចំនួន ៦,៦% ដែលបានលើកឡើងថាការសារភាពរបស់ខ្លួនត្រូវបានទទួលតាមរយៈអំពើហិង្សាឬទារុណកម្ម។ ចំណុចនេះគឺជាបញ្ហាគួរឱ្យព្រួយបារម្ភ ហើយករណីបែបទាំងនេះត្រូវតែមានការស៊ើបអង្កេតជាបន្ទាន់ និងឱ្យបានហ្មត់ចត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួន ត្រូវបានសាលាឧទ្ធរណ៍គោរពយ៉ាងស៊ីសង្វាក់ចាប់តាំងពីឆ្នាំ២០១៤ មក ដែលក្នុងនោះរួមមានសិទ្ធិក្នុងការជួបពិភាក្សាជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ និងការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល។ ប៉ុន្តែ សិទ្ធិជាក់លាក់មួយចំនួនទៀតមិនទាន់ត្រូវបានគោរពពេញលេញដោយស៊ីសង្វាក់ចាប់តាំងពីឆ្នាំ២០១៤ មកដែរ

---

[4] គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ត្រូវបានផ្អាកជាបណ្តោះអាសន្ននៅចន្លោះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ដោយសារតែកង្វះមូលនិធិ។ ជាលទ្ធផល មិនមានទិន្នន័យសម្រាប់រយៈពេលដែលបានផ្អាកនោះទេ។

ដូចជាសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ សិទ្ធិបង្ហាញភស្តុតាងនិងសិទ្ធិរបស់អនីតិជន។

របាយការណ៍នេះបញ្ចប់ដោយផ្តល់នូវអនុសាសន៍គន្លឹះមួយចំនួនដល់សាលាឧទ្ធរណ៍ ដើម្បីដោះស្រាយចំណុចខ្វះខាតដែលបានកំណត់នៅក្នុងរបាយការណ៍នេះ និងលើកកម្ពស់ការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅទូទាំងប្រទេសកម្ពុជា ដូចខាងក្រោម៖

- អនុវត្តតាមការអនុវត្តល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ដូចជាការបង្កើតក្របខ័ណ្ឌ ដែលចៅក្រមមានកាតព្វកិច្ចក្នុងការប្រាប់ និងពន្យល់អំពីសំអាងហេតុច្បាប់ និងភស្តុតាងនៅពីក្រោយសេចក្តីសម្រេចរបស់ខ្លួន ដែលអនុញ្ញាតឱ្យជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការដោយស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលនីតិវិធីព្រហ្មទណ្ឌទាំងអស់ និងបំពាក់បំប៉នចៅក្រមអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។
- រៀបចំទម្រង់បែបបទដែលរៀបរាប់អំពីព័ត៌មានទាំងអស់ដែលចៅក្រមត្រូវតែផ្តល់ដល់ជនជាប់ចោទ រាប់បញ្ចូលទាំងព័ត៌មានចោទប្រកាន់សំខាន់ដូចជា កាលបរិច្ឆេទ និងទីតាំងនៃការប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ ភាគីពាក់ព័ន្ធ និងច្បាប់ពាក់ព័ន្ធ សិទ្ធិត្រូវបានសន្មតជាមុនថាគ្មានទោស និងសិទ្ធិមានមេធាវីរបស់ពួកគេ។
- រក្សា និងរៀបចំឱ្យមានភាពទូទៅក្នុងការអនុវត្តបិទផ្សាយកាលវិភាគសវនាការប្រចាំថ្ងៃ នៅលើក្តារព័ត៌មានខាងក្រៅបន្ទប់សវនាការយ៉ាងហោចណាស់ឱ្យបាន ២៤ ម៉ោងមុនពេលសវនាការ និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសវនាការនៅលើគេហទំព័រ។
- ស៊ើបអង្កេតការលើកឡើងដែលថាការសារភាពទោសមិនត្រូវបានផ្តល់ដោយស្ម័គ្រចិត្ត។
- ធានាថាបន្ទុកនៃភស្តុតាងជានិច្ចជាកាលត្រូវបានដាក់លើភាគីដែលត្រូវទទួលខុសត្រូវពោលគឺអយ្យការ ជាពិសេស នៅក្នុងករណីដែលបានលើកឡើងថាចម្លើយសារភាពត្រូវបានទទួលតាមរយៈការបង្ខិតបង្ខំ។
- រៀបចំបង្កើតឯកសារណែនាំឱ្យបានច្បាស់លាស់ពាក់ព័ន្ធនឹងការបង្ហាញ និងការវាយតម្លៃភស្តុតាង។
- ធានាថាការចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរបានដាក់បញ្ចូលនូវច្បាប់ជាធរមានពាក់ព័ន្ធ និងភស្តុតាងសំខាន់ៗ ដែលប្រើប្រាស់ជាមូលដ្ឋាន និង
- ការពង្រឹង និងការពន្លឿនការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាពិសេសពាក់ព័ន្ធនឹងឯកជនភាព និងជម្រើសផ្សេងពីការឃុំឃាំង។

ម.ស.ម.ក សង្ឃឹមថាទិន្នន័យ ការវិភាគ និង អនុសាសន៍ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ នឹងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌ និងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជួយគាំទ្រការងារទាំងនោះ ដើម្បីធានាថាប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាគឺមានយុត្តិធម៌ និងស្មើភាពសម្រាប់អ្នកទាំងអស់គ្នា។

# ១. សេចក្តីផ្តើម

## ១.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គឺជាធាតុផ្សំគន្លឹះនៃការគោរពនីតិរដ្ឋ និងជានាទូវការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នេះគឺជាសិទ្ធិត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងមានចែងក្នុងច្បាប់អន្តរជាតិតាមរយៈសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ("ស.ស.ស.ម") និងមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") នៅក្នុងចំណោមលិខិតូបករណ៍ផ្សេងទៀត។[5] សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នេះក៏ត្រូវបានធានានៅក្នុងប្រទេសកម្ពុជាតាមរយៈរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដូចមានបង្ហាញបន្ថែមនៅក្នុងច្បាប់ជាតិផងដែរដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

### ១.១.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាផ្នែកដ៏សំខាន់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ សិទ្ធិនេះផ្តល់ឱ្យបុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ នូវការប្រព្រឹត្តដោយយុត្តិធម៌ និងស្មើភាពគ្នា ទោះបីជារដ្ឋកំណត់អំពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់អ្នកទាំងនោះ។ នៅពេលមានការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឱ្យបានត្រឹមត្រូវ នឹងការពារទាំងសិទ្ធិរបស់ជនជាប់ចោទ និងជនរងគ្រោះ ព្រមទាំងជានាការផ្តល់នូវយុត្តិធម៌ដ៏ត្រឹមត្រូវផងដែរ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌រួមផ្សំដោយសិទ្ធិជាក់លាក់ផ្សេងៗមួយចំនួន ហើយក្តោបនៅក្នុងនីតិវិធីច្បាប់ទាំងមូល ដោយគិតចាប់ពីដំណាក់កាលដំបូងនៃការឃាត់ខ្លួនជនសង្ស័យរហូតដល់ការប្តឹងតវ៉ាត្រូវបានបញ្ចប់។

> **មាត្រា ១០ នៃ ស.ស.ស.ម**
> មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នា និងពេញលេញក្នុងការសុំឱ្យតុលាការឯករាជ្យ និងមិនលម្អៀង ត្រួតពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចបានលើសិទ្ធិកាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ។

ទាំង ស.ស.ស.ម[6] និង ក.អ.ស.ព.ន[7] សុទ្ធតែធានាសិទ្ធិទទួលបានសវនាការយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្តីឯករាជ្យ និងឥតលម្អៀង។ ក.អ.ស.ព.ន បន្តបង្ហាញជាតុផ្សំផ្សេងៗនៃសវនាការយុត្តិធម៌ ដែលរួមមានជាអាទិ៍ សិទ្ធិនិងគោលការណ៍ ដូចរៀបរាប់តទៅនេះ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ[8] សិទ្ធិទទួលបានការ

---

[5] *សូមមើលផងដែរ* កតិកាសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩, មាត្រា ៨។ ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១) មាត្រា ៧។ កតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥០) មាត្រា ៦។ ធម្មនុញ្ញអឺរ៉ុបស្តីពីសិទ្ធិមូលដ្ឋាននៃសហភាពអឺរ៉ុប (ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០០) មាត្រា៤៧-៥០។

[6] មហាសន្និបាតអង្គការសហប្រជាជាតិ "សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស" ("ស.ស.ស.ម") (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨) មាត្រា ១០, www.un.org/en/universal-declaration-human-rights/index.html ។

[7] មហាសន្និបាតអង្គការសហប្រជាជាតិ "កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" ("ក.អ.ស.ព.ន") (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦) មាត្រា ១៤ (១) www.ohchr.org/en/professionalinterest/pages/ccpr.aspx ។

[8] មាត្រា ១៤ (១) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

សន្មតទុកជាមុនថាគ្មានទោស,[9] សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល[10] សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់[11] សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី[12] សិទ្ធិមានមេធាវី[13] ការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកបទល្មើសលើខ្លួនឯង(មិនសារភាពទោសកំហុសដោយសារតែការបង្ខិតបង្ខំ ឬការលួងលោម)[14] និងសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់លើផ្នែកអង្គហេតុ និងអង្គច្បាប់[15]។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ ក.អ.ស.ព.ន នៅឆ្នាំ១៩៩២ ហើយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានដាក់បញ្ចូល កាតព្វកិច្ចគោរពសិទ្ធិមនុស្សអន្តរជាតិដោយផ្ទាល់ទៅក្នុងច្បាប់ជាតិ។[16] បទប្បញ្ញត្តិនេះមានន័យថាបទដ្ឋានគតិយុត្តិស្តីពីសិទ្ធិមនុស្សអន្តរជាតិនានា រួមទាំងបទប្បញ្ញត្តិនៃ ក.អ.ស.ព.ន មានអានុភាពអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា ដូចដែលបានបញ្ជាក់បន្ថែមតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីឆ្នាំ ២០០៧។[17]

### ១.១.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារនៅកម្ពុជា តាមរយៈបទប្បញ្ញត្តិជាក់លាក់ និងទូទៅមួយចំនួនដែលមានចែងនៅក្នុងលិខិតូបករណ៍មួយចំនួន។ ក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌មានចែងនៅក្នុងរដ្ឋធម្មនុញ្ញដែលធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរថា៖

- មិនត្រូវឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។
- ការចោទប្រកាន់ ការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតឡើយ លុះត្រាតែអនុវត្តតាមបញ្ញត្តិច្បាប់។
- ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មខុសណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មទៅចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់។

---

[9] មាត្រា ១៤ (២) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[10] មាត្រា ១៤ (៣) (គ) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[11] មាត្រា ១៤ (៣) (ក) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[12] មាត្រា ១៤ (៣) (ខ) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[13] មាត្រា ១៤ (៣) (ឃ) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[14] មាត្រា ១៤ (៣) (ឆ) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[15] មាត្រា ១៤ (៣) (៥) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[16] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ" https://sithi.org/km/sogi/law/1993-09-21-the-constitution-of-the-kingdom-of-cambodia-1993-and-subsequent-amendments-2001 សំណៅនៃរដ្ឋធម្មនុញ្ញដែលបានធ្វើបច្ចុប្បន្នភាព ធ្វើវិសោធនកម្មលើកចុងក្រោយនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ គឺមិនទាន់មាននៅលើអនឡាញនោះទេ។

[17] សេចក្តីប្រកាសលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ ២, https://ccc.gov.kh/detail_info_kh.php?_txtID=214 ។

- ការទទួលសារភាព ដែលបានមកតាមរយៈការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។
- វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទណាក៏ដោយត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
- ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

បន្ថែមលើនេះ មាត្រា ៥១ មាត្រា ១២៨ មាត្រា ១៣០ មាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញក៏បានបញ្ញត្តិអំពីការបែងចែកអំណាច និងឯករាជ្យភាពរបស់តុលាការដែលធានាដោយព្រះមហាក្សត្រផងដែរ។

ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័តក្នុងឆ្នាំ២០០៧[18] ចែងយ៉ាងលម្អិតអំពីនីតិវិធីដែលត្រូវអនុវត្តលើជនសង្ស័យ។ ក្រមនេះបានកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងភាគីវេងការចោទប្រកាន់ដោយគិតចាប់ពីការផ្តួចផ្តើមនៃការស៊ើបអង្កេតបឋម រហូតដល់ពេលចាប់ខ្លួននៅក្នុងនីតិវិធីព្រហ្មទណ្ឌទាំងមូលរហូតដល់ការបញ្ចប់បណ្តឹងតវ៉ាជាស្ថាពរ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ ២០០៩ និងបានចូលជាធរមានកាលពីខែធ្នូ ឆ្នាំ២០១០ ចែងអំពីចំណាត់ថ្នាក់នៃបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។[19]

បន្ថែមលើនេះទៀត ច្បាប់ជាមូលដ្ឋានទាំងបីពាក់ព័ន្ធជាមួយប្រព័ន្ធយុត្តិធម៌ រួមមានច្បាប់ស្តីពីការរៀបចំអង្គការតុលាការ[20] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា[21] និងច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[22] ដែលបានអនុម័តក្នុងឆ្នាំ២០១៤ មានគោលបំណងធានាឯករាជ្យភាពរបស់អំណាចតុលាការ និងដើម្បីការពារសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋកម្ពុជា។ ប៉ុន្តែ ច្បាប់ទាំងនេះត្រូវបានរៀបចំសេចក្តីព្រាងដោយពុំបានផ្សព្វផ្សាយ ឬពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិល សាធារណជន ឬភាគីពាក់ព័ន្ធផ្សេងទៀតឡើយ ដែលធ្វើឱ្យវេងការរិះគន់លើភាពកម្សោយនៃការបែងចែកអំណាចនិងឯករាជ្យភាពរបស់ប្រព័ន្ធយុត្តិធម៌។ ច្បាប់ទាំងនេះបានផ្តល់នូវការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពនិងដោយផ្ទាល់ដល់ផ្នែកប្រតិបត្តិទៅលើប្រព័ន្ធតុលាការ ដោយការបង្កើនកម្រិតឥទ្ធិពលរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ទៅលើចៅក្រមនិងព្រះរាជអាជ្ញា តាមរយៈការចូលរួមរបស់ក្រសួងនេះនៅក្នុងការចាត់ចែងថវិកាសម្រាប់ប្រព័ន្ធយុត្តិធម៌ ការតែងតាំង ការដំឡើងឋានៈ អាណត្តិ និងការដកហូតតំណែង។[23]

---

[18] ក្រមនីតិវិធីព្រហ្មទណ្ឌជំនួសឱ្យផ្នែកមួយចំនួននៃបទប្បញ្ញត្តិទាក់ទិននឹងតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់ អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (ឆ្នាំ ១៩៩២) ("ច្បាប់អ៊ុនតាក់")។ អាចស្វែងរកបាននៅលើគេហទំព័រ https://sithi.org/km/law/2008-08-07-criminal-procedure-code-2007-new។

[19] ក្រមព្រហ្មទណ្ឌ https://sithi.org/km/tmp/publication/view/2009-12-14-criminal-code-of-the-kingdom-of-cambodia-2009 ។

[20] "ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ" (ឆ្នាំ២០១៤) https://sithi.org/km/law/2014-07-02-law-on-the-organization-of-the-court ។

[21] "ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា" (ឆ្នាំ២០១៤) http://www.sithi.org/judicial/docs/Judicial_Laws/Draft_Law_on_the_Statute_of_Judges_and_Prosecutors_NA_Eng.pdf

[22] "ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" (ឆ្នាំ២០១៤) http://www.sithi.org/admin/upload/law/03_Draft_Law_on_the_Organization_and_Functioning_of_the_Supreme_Council_of_Magistracy_English.pdf ។

[23] ម.ស.ម.ក, គោលដៅយុត្តិធម៌ និង អាដហុក "របាយការណ៍រួមរបស់រាជរដ្ឋាភិបាលសម្រាប់វដ្តលើកទី៣នៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (UPR) ដែលដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ស្តីពីការទទួលបានយុត្តិធម៌នៅកម្ពុជា" JST7 - ការដាក់

ជាចុងក្រោយ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលត្រូវបានអនុម័តក្នុងខែកក្កដា ឆ្នាំ២០១៦ ហើយបានចូលជាធរមានក្នុងខែមករា ឆ្នាំ២០១៧[24] បានចែងអំពីបទដ្ឋានគតិយុត្តិ និងនីតិវិធីពាក់ព័ន្ធជាមួយអនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។[25] ច្បាប់នេះត្រូវតែអនុម័តឱ្យបានតឹងរឹងបំផុតដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជន។

កាលពីខែមិថុនា ឆ្នាំ២០០៣ គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាក៏បានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ("យុទ្ធសាស្ត្រ")[26]។ ដែលយុទ្ធសាស្ត្រនេះ កំណត់អំពីគោលការណ៍ណែនាំចំនួន ៤ ដែលមានប្រភពចេញពីរដ្ឋធម្មនុញ្ញដើម្បីជាមគ្គុទ្ទេសក៏ការធ្វើកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌រួមមាន៖ សិទ្ធិរបស់បុគ្គល គោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។ យុទ្ធសាស្ត្រនេះក៏កំណត់អំពីកម្មវត្ថុជាយុទ្ធសាស្ត្រ[27] ដែលបង្កើតបានជាមូលដ្ឋានគ្រឹះនៃផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅក្នុងផែនការ

---

របាយការណ៍រួម ៧ (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) ផ្នែកទី ២ www.ohchr.org/EN/HRBodies/UPR/Pages/UPRKHStakeholdersInfoS32.aspx ("ការដាក់របាយការណ៍ស្តីពីការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) ម.ស.ម.ក "ការវិភាគផ្លូវច្បាប់ សេចក្តីព្រាងច្បាប់បីទាក់ទងនឹងវិស័យតុលាការ" (ខែឧសភា ឆ្នាំ២០១៤) https://cchrcambodia.org/admin/media/analysis/analysis/khmer/2014_06_17_CCHR_Analysis_of_the_Draft_Laws_on_Judicial_Reforms_Khmer.pdf ; ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា "មតិយោបល់ចំពោះបញ្ញត្តិជាក់លាក់នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" (ខែឧសភា ឆ្នាំ២០១៤) http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20draft%20Law%20on%20status%20of%20J%20and%20P,%20ENG%20May%202014%20final.pdf; ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា "មតិយោបល់ចំពោះបញ្ញត្តិជាក់លាក់នៃសេចក្តីព្រាងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" (ខែឧសភា ឆ្នាំ២០១៤) http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20SCM%20Draft%20law,%20ENG%20May%202014%20final.pdf; ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា "មតិយោបល់អំពីបញ្ញត្តិជាក់លាក់នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាកាទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" (ខែឧសភា ឆ្នាំ២០១៤) http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20draft%20Law%20on%20org%20of%20courts,%20ENG%20May%202014%20final.pdf.

[24] "ច្បាប់ស្តីពីយុត្តិធម៌អនីតិជន" (ឆ្នាំ២០១៦) https://sithi.org/medias/files/projects/sithi/law/Law-on-Juvenile-Justice-2016-Khmer-version.pdf ។

[25] "កម្រងសំណួរចម្លើយរបស់អង្គការយូនីសេហ្វ អំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលទើបនឹងអនុម័តថ្មីក្នុងប្រទេសកម្ពុជា" (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦) http://unicefcambodia.blogspot.com/2016/09/q-on-newly-adopted-juvenile-justice-law.html

[26] គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា("CRBD") និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ("CDC"), 'សមិទ្ធផលគោលនយោបាយរាជរដ្ឋាភិបាល (ឆ្នាំ២០០៤) www.cdc-crdb.gov.kh/cdc/7cg_meeting/position_paper_eng2004/7cg_02_1.html , វាក្យខណ្ឌ ១៦។

[27] កម្មវត្ថុរួមមាន៖ ១) កាកែលម្អការការពារសិទ្ធិជាមូលដ្ឋាន និងសេរីភាព ២) ទំនើបកម្មក្របខ័ណ្ឌការងារផ្នែកច្បាប់ ៣) ការផ្តល់លទ្ធភាពកាន់តែប្រសើរដើម្បីទទួលបានព័ត៌មានផ្នែកច្បាប់ និងយុត្តិធម៌ ៤) ការពង្រឹងគុណភាពដំណើរការផ្នែកច្បាប់ និងសេវាពាក់ព័ន្ធ ៥) ការពង្រឹងសេវាយុត្តិធម៌ ពោលគឺអំណាចរបស់អង្គតុលាការ និងសេវាអយ្យការ ៦) ការដាក់ឱ្យមានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ៧) ការពង្រឹងស្ថាប័នក្នុងវិស័យច្បាប់ និងយុត្តិធម៌ ដើម្បីបំពេញតាមអាណត្តិរបស់ខ្លួន។ CDC និង CRBD "អភិបាលកិច្ចគោលនយោបាយរបស់រដ្ឋាភិបាល" (២០០៤) www.cdc-crdb.gov.kh/cdc/7cg_meeting/position_paper_eng2004/7cg_02_1.htm, វាក្យខណ្ឌទី ១៥-២៤

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨។[28] កម្មវត្ថុទីមួយនៃកម្មវត្ថុជាយុទ្ធសាស្ត្រទាំងនេះ គឺដើម្បីកែលម្អការការពារសិទ្ធិជាមូលដ្ឋាន និងសេរីភាព។

រដ្ឋាភិបាលបានបញ្ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មីសម្រាប់ឆ្នាំ២០១៩-២០២៣ ដោយបានលើកឡើងអំពីចំណុចអាទិភាពសំខាន់ៗរបស់រដ្ឋាភិបាល ដែលក្នុងនោះរួមមានការលើកកម្ពស់សេវាយុត្តិធម៌ ដោយពង្រឹងការងាររបស់មន្ត្រីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ពង្រឹងទំនុកចិត្តសាធារណជនមកលើវិស័យតុលាការ និងប្រយុទ្ធប្រឆាំងនឹងអំពើអយុត្តិធម៌។[29] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ក៏បានបញ្ជាក់ថាក្រសួងយុត្តិធម៌នឹងបន្តអនុវត្តការធ្វើកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការរបស់ខ្លួនផងដែរ។

បន្ថែមលើនេះទៀត ក្នុងខែឧសភា ឆ្នាំ២០១៧ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងយុត្តិធម៌បានផ្តួចផ្តើមគំនិតឱ្យមានយុទ្ធនាការ ១០០ ថ្ងៃ ដើម្បីវាយតម្លៃលទ្ធផលការងារ និងប្រសិទ្ធភាពរបស់តុលាការ។[30] យុទ្ធនាការនេះ មានគោលបំណងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ និងធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធ្វើឱ្យប្រព័ន្ធយុត្តិធម៌កាន់តែមានលក្ខណៈគួរជាទីជឿជាក់ច្បាស់ និងអាចអនុវត្តបាន ហើយគោលបំណងរបស់យុទ្ធនាការនេះ ក៏ដើម្បីកែលម្អកិត្យានុភាពរបស់តុលាការ និងបង្កើនការទុកចិត្ត និងជំនឿជឿជាក់របស់សាធារណជនមកលើប្រព័ន្ធតុលាការផងដែរ។ គិតត្រឹមខែកញ្ញា ឆ្នាំ២០១៧ ដំណាក់កាលទីមួយនៃដំណើរការនេះបានបញ្ចប់រួចរាល់ហើយ ហើយលទ្ធផលបឋមបានបង្ហាញថាមានបញ្ហាប្រឈមចម្បងចំនួនបី៖ ការរៀបចំផែនការនិងយុទ្ធសាស្ត្រ ធនធានមនុស្សនិងហិរញ្ញវត្ថុ និងការប្រាស្រ័យទាក់ទងរវាងតុលាការ និងសាធារណជន។[31] ដំណាក់កាលទីពីរបានចាប់ផ្តើមកាលពីខែកញ្ញា ឆ្នាំ២០១៧ ប៉ុន្តែចាប់តាំងពីពេលនោះមក ពុំមានព័ត៌មានបច្ចុប្បន្នភាពអំពីដំណើរការនេះត្រូវបានធ្វើឡើងជាសាធារណៈឡើយ។[32]

តុលាការ និងក្រសួងពាក់ព័ន្ធនានាបានចេញសេចក្តីប្រកាសមួយចំនួននាពេលថ្មីៗនេះ ដែលអាចនាំឱ្យមានការកែលម្អគួរឱ្យកត់សម្គាល់ទៅលើស្ថានភាពអ្នកដែលកំពុងប្រឈមនឹងភាពអយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា៖

---

[28] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ "ផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥); រាជរដ្ឋាភិបាល, "ផែនការអភិវឌ្ឍន៍យុត្តិសាស្ត្រជាតិ ២០១៤-២០១៨" ទំព័រទី ៩-១២, វាក្យខណ្ឌទី ២.១១ ទៅ ២.២៣, www.ilo.org/wcmsp៥/groups/public/---asia/---ro-bangkok/---sro-bangkok/documents/genericdocument/wcms_៣៦៤៥៤៩.pdf (ការបកប្រែ)។ សំណៅច្បាប់ដើមអាចរកបាន http://cdc-crdb.gov.kh/cdc/documents/NSDP_2014-2018.pdf ។

[29] ក្រសួងផែនការ "ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ ២០១៩-២០២៣", http://www.mop.gov.kh/DocumentEN/NSDP%202019-2023%20in%20English.pdf, ទំព័រ ២០៥-២០៦, វាក្យខណ្ឌទី ៤.២១(៧)។

[30] លេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌នៃក្រសួងយុត្តិធម៌ "សេចក្តីជូនដំណឹងស្តីពីយុទ្ធនាការ ១០០ ថ្ងៃដើម្បីវាយតម្លៃលទ្ធផលការងារ និងប្រសិទ្ធផលរបស់តុលាការ" (ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧) www.facebook.com/334873460054405/photos/a.336969683178116/654031978138550/?type=3&theater (មានតែជាភាសាខ្មែរ); Nachemson Andrew និង Niem Chheng "ក្រសួងអនុវត្តការសិក្សាតុលាការដោយខ្លួនឯង" (*ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧) www.phnompenhpost.com/national/ministry-undertake-its-own-study-courts ។

[31] "មន្ត្រី៖លទ្ធផលបឋមយុទ្ធនាការ ១០០ ថ្ងៃរបស់ក្រសួងយុត្តិធម៌ រកឃើញចំណុចខ្វះខាត ៣ ធំ។ (វិទ្យុវាយោ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧) http://vayofm.com/news/detail/80228-555917756.html?option=tem&textid=49040 ។

[32] "មន្ត្រី៖លទ្ធផលបឋមយុទ្ធនាការ ១០០ ថ្ងៃរបស់ក្រសួងយុត្តីធម៌ រកឃើញចំណុចខ្វះខាត ៣ ធំ។" (វិទ្យុវាយោ, ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០១៧) http://vayofm.com/news/detail/80228-555917756.html?option=tem&textid=49040 ។

- ការបណ្ដុះបណ្ដាលប្រចាំឆ្នាំសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាស្ដីពីជំនាញបច្ចេកទេស ក្រមរិដ្ឋប្បវេណីរ និងច្បាប់ស្ដីពីសិទ្ធិមនុស្សអន្តរជាតិ។[33]
- សាងសង់មណ្ឌលឃុំខ្លួនថ្មីសម្រាប់អនីតិជនក្រោមអាយុ ១៨ ឆ្នាំនៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលនឹងក្លាយជាមណ្ឌលឃុំខ្លួនទីមួយដែលមានលក្ខណៈបែបនេះនៅក្នុងប្រទេសកម្ពុជា[34] ការសាងសង់ បានចាប់ផ្ដើមឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ២០២០ ដោយគ្រោងនឹងបញ្ចប់នៅដើមឆ្នាំ២០២១។[35]
- រៀបចំគោលនយោបាយជំនួយផ្លូវច្បាប់ទូទាំងប្រទេសដើម្បីផ្ដល់មេធាវីដល់ក្រុមទីទាល់ក្រនៅក្នុងតំបន់ជនបទនៅកម្ពុជា។[36]
- ការបង្កើត "បន្ទប់មេធាវី" នៅក្នុងបន្ទប់សវនាការទាំងអស់នៅទូទាំងប្រទេស ដែលអ្នកពុំមានមធ្យោបាយហិរញ្ញវត្ថុអាចពិគ្រោះយោបល់ជាមួយនឹងមេធាវីបានដោយឥតគិតថ្លៃ។[37]
- ការបង្កើតសាលាឧទ្ធរណ៍ភូមិភាគចំនួនបីនៅក្នុងខេត្តបាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ហើយមានគម្រោងបង្កើតបួនបន្ថែមទៀត[38] និងរៀបចំផែនការបណ្ដុះបណ្ដាលពេញលេញ និងបញ្ជូនចៅក្រមសាលាឧទ្ធរណ៍ទៅតាមសាលាឧទ្ធរណ៍ភូមិភាគទាំងនេះ។[39] សាលាឧទ្ធរណ៍ភូមិភាគទាំងបីនេះបានចាប់ផ្ដើមសវនាការនៅក្នុងឆ្នាំ២០២០។[40]

---

[33] រដ្ឋាភិបាល "របាយការណ៍ថ្នាក់ជាតិដែលបានដាក់ជូនដោយស្របតាមវាក្យខណ្ឌ ៥ នៃឧបសម្ព័ន្ធនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ ១៦/២១ រាជរដ្ឋាភិបាលកម្ពុជា" (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨) UN Doc. A/HR/WG.6/32/KHM/1, វាក្យខណ្ឌ ១៩, https://documents-dds-ny.un.org/doc/UNDOC/GEN/G18/341/00/PDF/G1834100.pdf?OpenElement ("របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ នៃ UPR (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨)")។

[34] វ៉ន ដារ៉ា "មណ្ឌលស្ដារនីតិសម្បទារបស់អនីតិជនក្នុងខេត្តកណ្ដាលត្រូវបានសាងសង់" (ភ្នំពេញប៉ុស្ដិ៍, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០) www.phnompenhpost.com/national/juvenile-rehab-centre-kandal-breaks-ground

[35] "មណ្ឌលឃុំខ្លួនអ្នកជាប់ឃុំយុវជនទីមួយត្រូវបានគម្រោងបង្កើតឡើង" (ខ្មែរថាមស៍, ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០) www.khmertimeskh.com/721320/first-juvenile-rehabilitation-centre-to-open-soon/ ។

[36] វ៉ន ដារ៉ា ""គោលនយោបាយច្បាប់ស្ដីពីក្រុមទីទាល់ក្រដែលបានបញ្ចប់ដោយរដ្ឋាភិបាល សហភាពអឺរ៉ុប" *(ភ្នំពេញប៉ុស្ដិ៍*, ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨) www.phnompenhpost.com/national/legal-policy-marginalised-groups-finished-govt-eu; អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាស្ដីពី "សេចក្ដីថ្លែងបញ្ចប់បេសកកម្ម" (ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨) ទំព័រ ៤, វាក្យខណ្ឌ ២ https://cambodia.ohchr.org/sites/default/files/pressstatementsource/181108%20ENG_END%200F%20MISSION%20STATEMENT.pdf ("អ្នករាយការណ៍ពិសេស, សេចក្ដីថ្លែងបញ្ចប់បេសកកម្ម (ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨)"); ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨) A/HRC/36/61, វាក្យខណ្ឌ ៧៩ http://cambodia.ohchr.org/sites/default/files/Annual-reports/Annual%20Report%202018%20of%20SR%20-%20A_HRC_39_73_EN.pdf ("របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨)")។

[37] របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ របស់យូភីអ (UPR) (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨) វាក្យខណ្ឌ ១៨ (ខ)។

[38] "សាលាឧទ្ធរណ៍ថ្មីចំនួន ៣ គ្រោងនឹងបញ្ចប់ការសាងសង់ឆ្នាំ ២០១៩" (ការសាងសង់អាគារ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨) www.construction-property.com/khread-news-1240/ (មានតែភាសាខ្មែរ)។

[39] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨) វាក្យខណ្ឌ ៨១។

[40] សែន ដាវីស "តុលាការសាលាឧទ្ធរណ៍ខេត្តព្រះសីហនុ ដំណើរការពេញលេញ" (ខ្មែរថាមស៍, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០) www.khmertimeskh.com/50761092/preah-sihanouk-appeal-court-in-full-service/។

- បង្កើតបន្ទប់តុលាការថ្មីចំនួនបួននៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីពន្លឿនការកាត់ក្តីសំណុំរឿង។[41]
- ការផ្សព្វផ្សាយអំពីសាលក្រមចំនួន ៤៤ ពីសំណុំរឿងរដ្ឋប្បវេណីដោយក្រសួងយុត្តិធម៌ ត្រូវប្រើប្រាស់ដូចទម្លាប់ពីមុនរបស់តុលាការសម្រាប់មេធាវី និងសាធារណជន ដោយសន្យាបន្តផ្សព្វផ្សាយអំពីសាលក្រមរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។[42]
- ការបង្កើតយុទ្ធនាការក្រសួងយុត្តិធម៌ ដើម្បីដោះស្រាយការរាំងស្ទះនូវសំណុំរឿងតុលាការនៅក្នុងប្រទេសកម្ពុជា ដើម្បីដោះស្រាយបញ្ហាចង្អៀតណែននៅក្នុងតុលាការ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានបញ្ជាក់ថាសំណុំរឿងចំនួន ៣៥,១០០ ករណី ស្មើនឹង ៨៩% នៃសំណុំរឿងដែលបានពន្យារពេល គឺត្រូវបានដោះស្រាយរួចរាល់។[43]
- ផែនការរបស់ក្រសួងមហាផ្ទៃក្នុងការបញ្ជូនមេធាវីតាមរយៈគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("គណៈមេធាវី") នៅតាមប៉ុស្តិ៍នគរបាលស្រុក និងខេត្តនៅទូទាំងប្រទេស ដើម្បីផ្តល់ជំនួយក្នុងការដោះស្រាយបញ្ហាក្នុងមូលដ្ឋាន ដោយបន្តផ្តោតលើការផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកត្រូវបានឃុំខ្លួនជាអនីតិជន។[44]
- ការសិក្សាលើលទ្ធភាពដើម្បីដាក់បញ្ចូលវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការប្រព្រឹត្តចំពោះជនជាប់ឃុំជាស្ត្រី និងវិធានមិនឃុំឃាំងជនល្មើសជាស្ត្រី (វិធានបាងកក)។[45]
- ការរៀបចំសេចក្តីព្រាងច្បាប់ដែលកំណត់នូវបទដ្ឋានអប្បបរមាទាក់ទងនឹងករណីអំពើហិង្សាលើស្ត្រី។[46]
- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក) ត្រូវបង្កើតក្រុមការងារជំនួយផ្នែកច្បាប់ដើម្បីការពារប្រជាជនក្រីក្រដែលត្រូវបានរងការរំលោភបំពានសិទ្ធិ[47] និងបង្កើតបណ្តាញទូរសព្ទសម្រាប់ផ្តល់ជំនួយផ្នែកច្បាប់ ដើម្បីលើកកម្ពស់ការទទួលបានយុត្តិធម៌។[48]
- ពន្លឿនដំណើរការតុលាការសម្រាប់ជនជាប់ឃុំជាស្ត្រីដែលរងចាំជំនុំជម្រះ។[49]

---

[41] វ៉ន ដារ៉ា "តុលាការក្រុង ចាត់វិធានការលុបបំបាត់បញ្ហារាំងស្ទះដោយបង្កើតបន្ទប់តុលាការថ្មីចំនួនបួនបន្ថែម"(ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០) www.phnompenhpost.com/national/municipal-court-set-clear-backlog-four-new-courtrooms ។

[42] នាម ឆេង "សេចក្តីសម្រេចរបស់តុលាការ" ត្រូវបានផ្សព្វផ្សាយទុកសម្រាប់ជាប្រភពយោង" (ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១) www.phnompenhpost.com/national/courts-decisions-now-published-reference-source ។

[43] វ៉ន ដារ៉ា "ក្រសួងយុត្តិធម៌៖ ៨៩% នៃសំណុំរឿងដែលបានរាំងស្ទះ គឺត្រូវបានដោះស្រាយ" (*ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០) www.phnompenhpost.com/national/justice-ministry-89-cent-court-case-backlog-cleared ។

[44] ខាន់ ច័ន្ទវីរៈ "ក្រសួងគ្រោងនឹងបញ្ជូនមេធាវីទៅថ្នាក់មូលដ្ឋាន ដើម្បីជួយដោះស្រាយបញ្ហា" (ខ្មែរថាមស៍, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០) www.khmertimeskh.com/50772904/ministry-plans-to-deploy-lawyers-at-local-levels-to-help-resolve-issues/ ។

[45] របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តទី ៣ របស់ UPR (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨) វាក្យខណ្ឌ ៤២។

[46] ជុំ ដោគជាតា "សង្គមស៊ីវិលពិភាក្សាលើសេចក្តីព្រាងច្បាប់ជួយទៅដល់ស្ត្រីនិងកុមារីរងគ្រោះដោយអំពើហិង្សា) មានសំឡេង "(បកប្រែជាភាសាអង់គ្លេស៖ Civil Society Discusses Draft Laws to Address Violent Women and Girls) (មណ្ឌលព័ត៌មានស្ត្រីកម្ពុជា, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨) https://wmc.org.kh/ngo-women/ (មានតែសំណៅជាភាសាខ្មែរ)។

[47] នាម ឆេង "CHRC បង្កើតក្រុមការងារផ្តល់ជំនួយផ្នែកច្បាប់" (ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩) www.phnompenhpost.com/national/chrc-form-legal-assistance-team ។

[48] សុទ្ធ គឹមសឿន "ខ្សែទូរសព្ទបន្ទាន់របស់គណៈកម្មាធិការសិទ្ធិមនុស្សទទួលបានការកោតសរសើរ" (ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩) www.phnompenhpost.com/national/human-rights-committees-legal-hotline-receives-praise ។

[49] នាម ឆេង "នាយករដ្ឋមន្ត្រី៖ ពន្លឿននីតិវិធីសវនាការចំពោះការឃុំខ្លួនស្ត្រីជាង ២០,០០០"(ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២០) www.phnompenhpost.com/national/pm-speed-trial-over-20000-women-detention ។

- រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ការកំណែទម្រង់ប្រព័ន្ធតុលាការ ជាចំណុចអាទិភាពកំពូលមួយរបស់ខ្លួន ដោយហេតុថាសន្តិភាពនិងស្ថិរភាពនឹងមិនអាចរក្សាបានឡើយ ប្រសិនបើពុំមានយុត្តិធម៌សង្គម និងប្រព័ន្ធតុលាការប្រកបដោយភាពស្មើភាព និងយុត្តិធម៌ទេនោះ។[50]

ជាទូទៅ រដ្ឋាភិបាលកម្ពុជាបានបន្តខិតខំប្រឹងប្រែងចាត់វិធានជាក់លាក់មួយចំនួនដើម្បីធ្វើការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌រួមទាំង ការកសាងសមត្ថភាព ការកែលម្អឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ និងការបែងចែកអំណាច ការលើកកម្ពស់ការគោរពសិទ្ធិបុគ្គលដើម្បី "ទទួលបានជំនឿជឿជាក់របស់សាធារណជនកាន់តែខ្លាំងឡើងមកលើប្រព័ន្ធតុលាការផងដែរ"។[51] ដូចបានបញ្ជាក់ពីខាងដើម រដ្ឋាភិបាលក៏បានបង្កើនកញ្ចប់ថវិកាសម្រាប់ និងការផ្តល់ជំនួយសេវាផ្នែកច្បាប់[52] និងបានដាក់ចេញផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិសម្រាប់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។[53]

ទោះជាយ៉ាងណាក៏ដោយ នៅតែមានក្តីបារម្ភមួយចំនួនលើប្រព័ន្ធយុត្តិធម៌ និងការគ្រប់គ្រងយុត្តិធម៌។ ក្តីបារម្ភទាំងនោះមានជាអាទិ៍ ការឃុំខ្លួនបណ្តោះអាសន្នហួសពេលកំណត់ ដែលជាលទ្ធផលធ្វើឱ្យពន្ធនាគារនៅកម្ពុជាមានភាពចង្អៀតណែន ដែលនៅក្នុងខែមិថុនា ឆ្នាំ២០២០ ពន្ធនាគារមានការឃុំខ្លួនលើសលទ្ធភាពខ្លួនជាង ៣០០%។[54] ការចោទប្រកាន់ថាកង្វះឯករាជ្យភាព និងភាពមិនលម្អៀងរបស់ប្រព័ន្ធតុលាការគឺកើតឡើងជាទូទៅ[55] ដូចដែលបានអះអាង

---

[50] "គ្មានការឈឺចាប់ គ្មានភាពជោគជ័យ៖ សម្តេច ហ៊ុនសែន បើកជំពូកកំណែទម្រង់ថ្មីសម្រាប់ប្រទេសកម្ពុជា" (ខ្មែរថាមស៍, ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩) www.khmertimeskh.com/639844/no-pain-no-gain-hun-sen-opens-a-new-reform-chapter-for-cambodia/; នាម ឆេង, "ក្រសួងយុត្តិធម៌ប្តេជ្ញាកែលម្អ" (*ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០) www.phnompenhpost.com/national/ministry-justice-vows-improve ។

[51] របាយការណ៍រាជរដ្ឋាបាលសម្រាប់វដ្តលើកទី ៣ នៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨) វាក្យខណ្ឌ ៧៤; ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "តួនាទី និងសមិទ្ធផលរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស" (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩) A/HRC/៤២/៣១, វាក្យខណ្ឌទី ៣០, https://cambodia.ohchr.org/sites/default/files/Ohchr-report/Role%20and%20achievements%20of%20the%20Office.pdf ("OHCHR, របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩)")។

[52] OHCHRC, របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩) វាក្យខណ្ឌ ៣០; ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" (ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩) A/HRC/៤២/៦០, វាក្យខណ្ឌ ៦៦, https://documents-dds-ny.un.org/doc/UNDOC/GEN/G19/253/48/PDF/G1925348.pdf?OpenElement ("របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩)")។

[53] ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, "ផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការច្បាប់ស្តីពីអនីតិជនឆ្នាំ ២០១៨-២០២០" https://www.unicef.org/cambodia/media/456/file/JJLSOP_Eng_០.PDF%20.pdf ។

[54] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" (ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០) A/HRC/៤៥/៥១, វាក្យខណ្ឌ. ៤១, https://cambodia.ohchr.org/sites/default/files/Annual-reports/A_HRC_45_51_AEV%20(1).pdf ("របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០)")។

[55] ការដាក់ចូលទៅការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (UPR) អំពីការទទួលបានយុត្តិធម៌(ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) ផ្នែកទី ២; របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩) វាក្យខណ្ឌ ៥៨។

ថានិទណ្ឌភាពនៅតែកើតឡើងជាបន្តបន្ទាប់នៅកម្ពុជា។[56] ការទទួលបានជំនួយផ្នែកច្បាប់នៅមានកម្រិត[57] ក៏ដូចជាការខ្វះលទ្ធភាពក្នុងការដាក់ពាក្យបណ្តឹងទៅកាន់តុលាការនៅក្នុងតំបន់ជនបទ[58] គឺជាចំណុចខ្វះខាតបន្ថែមទៀតរបស់ប្រព័ន្ធតុលាការ។ លើសពីនេះ ក៏មានបញ្ហាកង្វះស្ត្រីនៅក្នុងប្រព័ន្ធតុលាការ[59] ការទទួលបានយុត្តិធម៌នៅតែមានបញ្ហាប្រឈមសម្រាប់ជនមានពិការភាព មិនថាពួកគាត់ជាជនរងគ្រោះ ឬជនល្មើសនោះទេ[60] និងកង្វះខាតការការពារគ្រប់គ្រាន់លើកុមារដែលជាជនរងគ្រោះ ឬសាក្សីនៃបទល្មើស គឺជាកត្តាគួរឱ្យបារម្ភ។[61]

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា "ការអនុវត្តរបស់អាជ្ញាធរមានសមត្ថកិច្ច ដូចជា ចៅក្រម និងព្រះរាជអាជ្ញាជាទូទៅគឺផ្អែកលើច្បាប់ជាតិ ទាំងនៅក្នុងដំណើរការនីតិវិធី និងការធ្វើសេចក្តីសម្រេច ដោយមិនបានពិចារណាលើច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិឡើយ។"[62]

## ១.២ ទិសាលភាព និងវិធីសាស្ត្រ

*តួលេខទី ១៖ ទិដ្ឋភាពទូទៅអំពីសំណុំរឿងដែលត្រូវបានសង្កេតការណ៍ដោយ ម.ស.ម.ក (ឆ្នាំ២០១៧-២០២០)*

| | ទិដ្ឋភាពទូទៅអំពីសំណុំរឿងដែលត្រូវបានសង្កេតការណ៍ | | | |
|---|---|---|---|---|
| | ២០១៧/២០១៨ | ២០១៨/២០១៩ | ២០១៩/២០២០ | សរុប |
| ចំនួនសំណុំរឿង | ២១៣ | ២៣៩ | ២០៣ | ៦៥៥ |
| ចំនួនជនជាប់ចោទ | ៣១៥ | ៣៥២ | ២៥៥ | ៩២២ |

[56] ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (UPR) លើការទទួលបានយុត្តិធម៌ (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) ផ្នែក ២.៣; របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩) វាក្យខណ្ឌ ៥៨។

[57] ការដាក់ចូលទៅត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (UPR) លើការទទួលបានយុត្តិធម៌(ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) ផ្នែកទី ៣; ការិយាល័យឧត្តមស្នងការ, របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩) វាក្យខណ្ឌ ៣០; របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩) វាក្យខណ្ឌ ៦៦។

[58] ការដាក់ចូលទៅត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (UPR) លើការទទួលបានយុត្តិធម៌(ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) ផ្នែកទី ៤.៣.; របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩) វាក្យខណ្ឌ ៦៦។

[59] Leonie Kijewski and Yon Sineat, 'នៅក្នុងតលាការកម្ពុជា នេះគឺជាពិភពរបស់បុរស-ជាមួយឥទ្ធិពលដែលទទួលរងដោយនយោជិត និងជនរងគ្រោះជាស្ត្រីដូចគ្នា' (ភ្នំពេញប៉ុស្តិ៍ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨) https://www.phnompenhpost.com/national-post-depth/cambodias-courts-its-mans-world-effects-felt-female-employees-and-victims-alike។

[60] កម្មវិធីអភិវឌ្ឍសហប្រជាជាតិ, "សៀវភៅណែនាំស្តីពីជំនួយផ្នែកច្បាប់សម្រាប់ជនមានពិការភាពនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ៖ សេចក្តីណែនាំសម្រាប់ជនមានពិការភាព, អង្គការជនពិការ និងមេធាវីនៅកម្ពុជា" (២០២០) ទំព័រ ៤, https://www.kh.undp.org/content/cambodia/en/home/library/practical-guideline-on-legal-aid-for-persons-with-disabilitiesen.html

[61] អ្នករាយការណ៍ពិសេស "ការវាយតម្លៃការការពារអ្នកដែលប្រឈមនឹងហានិភ័យនៃការទុកចោលមិនអើពើ" (ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩) វាក្យខណ្ឌ ៣៣។

[62] របាយការណ៍រដ្ឋាភិបាលសម្រាប់វដ្តលើកទី ៣ នៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨) វាក្យខណ្ឌទី ៧០។

| | | | | |
|---|---|---|---|---|
| បទឧក្រិដ្ឋ | ៩៩ | ៨៩ | ៩៣ | ២៨១ |
| បទមជ្ឈិម | ១១១ | ១៥០ | ១១០ | ៣៧១ |
| បទលហុ | ៣ | ០ | ០ | ៣ |
| អនីតិជន (ជនជាប់ចោទ) | ៩ | ២២ | ១៥ | ៤៦ |
| ស្ត្រី (ជនជាប់ចោទ) | ៣៦ | ៤៧ | ១៩ | ១០២ |

នៅអំឡុងពេលធ្វើរបាយការណ៍នេះ អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ចូលរួមក្នុងសវនាការបទល្មើសព្រហ្មទណ្ឌជារៀងរាល់ថ្ងៃ។ ប៉ុន្តែនៅអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ សាលាឧទ្ធរណ៍បានបញ្ឈប់ការជំនុំជម្រះមួយរយៈដើម្បីឆ្លើយតបទៅនឹងសេចក្តីណែនាំក្នុងការទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ របស់រដ្ឋាភិបាល។ លើសពីនេះ លក្ខខណ្ឌតម្រូវសុវត្ថិភាពប្រឆាំងជំងឺកូវីដ ១៩ និងភាពចង្អៀតណែននៅក្នុងបន្ទប់សវនាការ អ្នកសង្កេតការណ៍សវនាការ ពេលខ្លះមិនអាចចូលរួមនិងសង្កេតការណ៍សវនាការនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍សវនាការក៏អាចសង្កេតការណ៍សវនាការបានចំនួន ២០៣ សំណុំរឿង។ ទំហំសំណាកគំរូនេះមានភាពគ្រប់គ្រាន់ក្នុងការប្រៀបធៀបទៅនឹងឆ្នាំមុនៗ។ អ្នកសង្កេតការណ៍សវនាការប្រើប្រាស់តារាងសង្កេតការណ៍សវនាការ ដែលបានបង្កើតឡើងជាពិសេស ("តារាងសង្កេតការណ៍សវនាការ") ដែលរួមមានសំណួរជាង ៧០ សំណួរ ដោយផ្តោតទៅលើសិទ្ធិទទួលបានការការជំនុំជម្រះសំខាន់ៗមួយចំនួនដូចខាងក្រោម៖[63]

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព
- សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិកោះហៅ និងសាកសួរសាក្សី)
- សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ
- សិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ

[63] ម.ស.ម.ក "តារាងសង្កេតការណ៍សវនាការសាលាឧទ្ធរណ៍" https://sithi.org/km/tmp/publication/view/2014-01-29-appeal-hearing-monitoring-checklist ។

- ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (បានជំនុំជម្រះបទល្មើសដែលមិនមែនជាបទល្មើស នៅពេលដែលបានចោទប្រកាន់)
- ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល និង
- សិទ្ធិរបស់អនីតិជន។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាចីរភាពនៃការចូលរួមបែបស្ថាបនានេះ ម.ស.ម.ក បានណែនាំនិងពន្យល់អំពីតារាងសង្កេតការណ៍សវនាការ និងសកម្មភាពសង្កេតការណ៍សវនាការរបស់ខ្លួនជូនតំណាងនៃសាលាឧទ្ធរណ៍។ ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធកម្រាស់មួយទំព័រដែលភ្ជាប់ជាមួយនឹងតារាងសង្កេតការណ៍សវនាការនេះ ដើម្បីប្រើប្រាស់សម្រាប់សវនាការពាក់ព័ន្ធនឹងអនីតិជន។ ដោយធ្វើការពិចារណាទៅលើភាពសង្ខេបខ្លីនៃតារាងសង្កេតការណ៍សវនាការ ម.ស.ម.ក បានចងក្រងឯកសារណែនាំដោយគ្រប់ជ្រុងជ្រោយ ("គោលការណ៍ណែនាំស្តីពីតារាងសង្កេតការណ៍សវនាការ")[64] ដើម្បីផ្តល់នូវការយល់ដឹងអំពីមូលដ្ឋានច្បាប់ និងគោលបំណងនៃសំណួរនីមួយៗ និងជានាឱ្យមានការបកស្រាយប្រកបដោយឯកសណ្ឋានភាពនៃសំណួរនីមួយៗ។អ្នកសង្កេតការណ៍សវនាការក៏ទទួលបាននូវឯកសារក្របខ័ណ្ឌច្បាប់ដែលលើកឡើងអំពីច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធ និងជាមូលដ្ឋាននៃសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍សវនាការនេះដែរ។

ម.ស.ម.ក បានផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះអង្គហេតុដែលថាសិទ្ធិក្នុងការប្តឹងជំទាស់[65] គឺមានសិទ្ធិក្នុងទទួលបានការពិនិត្យឡើងវិញទាំងស្រុង។ និយាយម្យាងទៀត ការពិនិត្យលើការប្តឹងជំទាស់ត្រូវតែពាក់ព័ន្ធនឹងទិដ្ឋភាពផ្នែកច្បាប់ និងវត្ថុតាងនៃការកាត់ឱ្យជាប់ទោស និងការដាក់ទោសបុគ្គល[66]។ ការណ៍នេះត្រូវតែផ្តល់ "ការវាយតម្លៃពេញលេញលើភស្តុតាង និងការបើកសវនាការ"។[67]

---

[64] ម.ស.ម.ក "គោលការណ៍ណែនាំស្តីពីតារាងសង្កេតការណ៍សវនាការសាលាឧទ្ធរណ៍របស់ ម.ស.ម.ក" https://sithi.org/km/tmp/publication/view/2014-01-29-guidance-notes-for-cchr-appeal-court-monitoring-checklist ។

[65] មាត្រា ១៤ (៥) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[66] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "សេចក្តីពន្យល់ទូទៅលេខ ៣២ – មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជុំនុំជម្រះដោយយុត្តិធម៌" (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧) CCPR/C/GC/៣២, វាក្យខណ្ឌ ៤៨, http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d/PPRiCAqhKb7yhsrdB□H1l59790VGGB%2BWPAXhRj□XNTTvKgFHbxAcZSvX10sJj/iyRmVA4IiMvUt2NlGKqqg2nh1qOE2hX5xoGtKE2v2YSQVV1Rv5NitNbSYwp ("គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២")

[67] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ការទំនាក់ទំនងលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥, *V. P. Domukovsky et al. v. Georgia* (ថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៨) *GAOR*, A/៥៣/៤០ (vol. II), ទំព័រ ១១១, វាក្យខណ្ឌ ១៨.១១, http://juris.ohchr.org/Search/Details/833 ។

ជាចុងក្រោយ ម.ស.ម.ក ប្ដេជ្ញាគោរពតាមគោលការណ៍អន្តរជាតិចំពោះការសង្កេតការណ៍សវនាការ[68] និងបានបង្កើតក្រមសីលធម៌ ("ក្រមសីលធម៌") សម្រាប់អ្នកសង្កេតការណ៍សវនាការ។[69] ក្រមសីលធម៌នេះចែងអំពីកាតព្វកិច្ចមិនជ្រៀតជ្រែក មិនជំទាស់ និងរក្សាការសម្ងាត់ដោយអ្នកសង្កេតការណ៍សវនាការដែលបានភ្ជាប់កតាព្វកិច្ច។

ការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក នៅសាលាឧទ្ធរណ៍មិនមានកំណត់គោលដៅលើសវនាការជាក់លាក់ណាមួយនោះទេ។ សវនាការដែលត្រូវសង្កេតការណ៍គឺត្រូវបានជ្រើសរើសដោយវិធីសាស្ត្រចៃដន្យ យោងទៅតាមកាលវិភាគរបស់សាលាឧទ្ធរណ៍ ដើម្បីធានាថាដំណើរការប្រមូលទិន្នន័យនៅតែមិនលម្អៀង និងតំណាង។ នៅពេលដែលអ្នកសង្កេតការណ៍សវនាការធ្វើការសង្កេតការណ៍សវនាការ ព័ត៌មានត្រូវបានកត់ត្រាទុកដោយផ្ទាល់ចូលទៅក្នុងតារាងសង្កេតការណ៍សវនាការ។ ទិន្នន័យដែលប្រមូលបានត្រូវបានកម្រិតត្រឹមដំណើរការសវនាការប៉ុណ្ណោះ មិនមានធ្វើការសម្ភាស ឬសន្ទនាបន្ថែមឡើយ លើកលែងតែអ្នកសង្កេតការណ៍សវនាការបានខិតខំប្រឹងប្រែងស្នើសុំព័ត៌មានពាក់ព័ន្ធនឹងសាលដីកាជុំនុំជម្រះ ដែលមិនត្រូវបានប្រគល់ជូននៅថ្ងៃសវនាការនោះ ប៉ុន្តែលើកទៅថ្ងៃក្រោយ។ នៅពេលបញ្ចប់សវនាការនីមួយៗ ទិន្នន័យដែលប្រមូលបានត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ("ប្រព័ន្ធគ្រប់គ្រងទិន្នន័យ")[70]។

ម.ស.ម.ក បានធ្វើការវិភាគទិន្នន័យសវនាការដែលបានកត់ត្រាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ហើយបានកំណត់រកឃើញនូវការអនុវត្តជាវិជ្ជមាន ក៏ដូចជាចំណុចគួរព្រួយបារម្ភមួយចំនួន ដែលកើតមាននៅអំឡុងពេលសវនាការផងដែរ។ គោលបំណងជារួមនៃការវិភាគនេះគឺជាការកំណត់ភាពខ្លាំង និងចំណុចខ្វះខាតរបស់សាលាឧទ្ធរណ៍ ក្នុងការអនុលោមនូវសិទ្ធិទទួលបានការជុំនុំជម្រះដោយយុត្តិធម៌ និងធ្វើការពិភាក្សាអំពីបញ្ហាទាំងនេះជាមួយនឹងសាលាឧទ្ធរណ៍ ក៏ដូចជាភាគីពាក់ព័ន្ធក្នុងវិស័យតុលាការដើម្បីបង្កើត និងអនុវត្តវិធីសាស្ត្រក្នុងការពង្រឹងការការពារសិទ្ធិទទួលបានការជុំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការកម្ពុជា។ ដោយសារតែសកម្មភាពសង្កេតការណ៍នៅតែបន្តប្រព័ន្ធគ្រប់គ្រងទិន្នន័យនេះនឹងត្រូវបានប្រើប្រាស់ ដើម្បីទាញយកការវិភាគបែបប្រៀបធៀប និងដើម្បីកំណត់និន្នាការក្នុងការអនុវត្តរបស់សាលាឧទ្ធរណ៍ ពង្រឹងការវាស់ស្ទង់ និងកំណត់រកអនុសាសន៍ណែនាំបន្ថែមទៀត។

ដើម្បីធានាបាននូវធាតុចូលពីភាគីដែលត្រូវបានសង្កេតការណ៍ ម.ស.ម.ក តែងតែដាក់ជូននូវសេចក្ដីព្រាងចុងក្រោយនៃរបាយការណ៍ទៅកាន់ប្រធានតុលាការឧទ្ធរណ៍ ដើម្បីមានឱកាសបានពិនិត្យ ឆ្លើយតប និងផ្ដល់អនុសាសន៍ផងដែរ។ សម្រាប់របាយការណ៍នេះ ម.ស.ម.ក បានទទួលធាតុចូលពីសាលាឧទ្ធរណ៍តាមរយៈលិខិតឆ្លើយតបលេខ ៤៣២

[68] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំអំពីសវនាការយុត្តិធម៌"(ឆ្នាំ១៩៩៨) <https://www.amnesty.org/en/documents/POL30/002/1998/en/>; គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្ស "តើសវនាការយុត្តិធម៌ជាអ្វី៖ ការណែនាំទូទៅចំពោះបទដ្ឋាន និងការអនុវត្តផ្លូវច្បាប់" (ឆ្នាំ២០០០) <https://www.humanrightsfirst.org/wp-content/uploads/pdf/fair_trial.pdf>; អង្គការ Organization for Security and Cooperation in Europe (OSCE) / ការិយាល័យ Democratic Institutions and Human Rights "ការសង្កេតការណ៍សវនាការ៖ សៀវភៅណែនាំយោងសម្រាប់អ្នកអនុវត្ត" (ឆ្នាំ២០០៨) <http://bit.ly/2CVLX77>; អង្គការ International Commission of Jurists "ការសង្កេតការណ៍សវនាការ" (ឆ្នាំ២០០២) <https://www.osce.org/odihr/94216>។

[69] ម.ស.ម.ក "ក្រមសីលធម៌នៃអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក" https://sithi.org/km/tmp/publication/view/2010-01-01-cchr-trial-monitoring-code-of-conduct ។

[70] ម.ស.ម.ក "ប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក" https://sithi.org/km/tmp/appeal ។

របខ/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ លើសេចក្ដីព្រាងរបាយការណ៍របស់ មក.ម.ស. ដែលបានផ្ញើជូនទៅតុលាការនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ ហើយធាតុចូលទាំងនេះត្រូវបានបញ្ចូលក្នុងរបាយការណ៍នេះ។ នៅពេលបោះពុម្ពរួច បុគ្គលិកគម្រោងអាចនឹងស្នើសុំឱ្យមានការប្រជុំជាក់លាក់ជាមួយនឹងតំណាងសាលាឧទ្ធរណ៍ និងជាមួយនឹងអង្គការ អង្គភាព ស្ថាប័នវិស័យយុត្តិធម៌ ដើម្បីបង្ហាញបបន្ថែមជុំវិញរបកគំហើញ និងអនុសាសន៍ដែលគួរត្រូវបានដោះស្រាយ។ កិច្ចប្រជុំទាំងនេះនឹងដើរតួនាទីជាមូលដ្ឋានសម្រាប់ការផ្លាស់ប្ដូរគំនិត ផ្ដល់ទស្សនៈនានាចំពោះបញ្ហាប្រឈមដែលបានជួបប្រទះដោយអ្នកដែលធ្វើការងារក្នុងវិស័យពាក់ព័ន្ធ ដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌ និងលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## ២. ទិដ្ឋភាពទូទៅ

ផ្នែកនេះនៃរបាយការណ៍កំណត់អំពីទិន្នន័យដើម ដែលបានកត់ត្រាក្នុងតារាងសង្កេតការណ៍សវនាការចំនួន ២០៣ សំណុំរឿង ដែលបានសង្កេតការណ៍នៅសាលាឧទ្ធរណ៍ ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលនឹងត្រូវវាយតម្លៃនៅក្នុងរបាយការណ៍នេះ។

*តួលេខទី ២៖ ទិដ្ឋភាពទូទៅអំពីសំណុំរឿងដែលត្រូវបានសង្កេតការណ៍ដោយ ម.ស.ម.ក នៅឆ្នាំ២០១៩/ ២០២០*




*តួលេខទី ៣៖ សវនាការនៅសាលាឧទ្ធរណ៍ដែលត្រូវបានសង្កេតការណ៍ – បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ*[71]




មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកំណត់និយមន័យបទឧក្រិដ្ឋថា ជាបទល្មើសទាំងឡាយណាដែលអតិបរិមានៃទោសដាក់ពន្ធនាគារលើសពីរយៈពេលប្រាំឆ្នាំ។ បទមជ្ឈិមត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ៤៧ ថាជាបទល្មើសទាំងឡាយណាដែលអតិបរមានៃទោសដាក់ពន្ធនាគារចាប់ពីប្រាំមួយថ្ងៃ និងក្រោម ឬស្មើនឹងប្រាំឆ្នាំ។ យោងតាមមាត្រា ៤៨ បទលហុគឺជាបទល្មើសដែលផ្តន្ទាទោសអតិបរមាឱ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយថ្ងៃ ឬតិចជាងនេះ ឬផ្តន្ទាទោសដោយការផាកពិន័យតែម្យ៉ាងប៉ុណ្ណោះ។[72] ដូចមានបង្ហាញដោយតារាងតួលេខទី ៣ ហើយថាសំណុំរឿងភាគច្រើនដែលគម្រោងបានសង្កេតការណ៍គឺជាបទមជ្ឈិម។

---

[71] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿងសរុបដែលបានសង្កេតការណ៍ (២០៣)។

[72] ក្រមព្រហ្មទណ្ឌ មាត្រា ៤៨។

*តួលេខទី ៤៖ ភាគីធ្វើបណ្តឹងឧទ្ធរណ៍*[73]




សេចក្តីសម្រេចចេញដោយសាលាដំបូងអាចត្រូវបានប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី (អ្នកទាំងពីរនេះអាចប្តឹងបានចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី)។[74] តួលេខទី ៤ នេះបង្ហាញថា បណ្តឹងឧទ្ធរណ៍ភាគច្រើន (៩០%) ធ្វើឡើងដោយភាគីជនជាប់ចោទ។

ក្នុងចំណោមសវនាការដែលត្រូវបានសង្កេតការណ៍ដោយ ម.ស.ម.ក តារាងខាងក្រោមនេះ បង្ហាញអំពីសិទ្ធិដែលត្រូវបានគោរព និងសិទ្ធិដែលមិនទាន់ត្រូវបានគោរពពេញលេញ៖

| សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព | សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនទាន់ត្រូវបានគោរពពេញលេញ |
|---|---|
| • សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី<br>• សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ<br>• ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ | • សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព<br>• សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ<br>• សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់<br>• សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ<br>• សិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ |

[73] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿងសរុបដែលបានសង្កេតការណ៍ (២០៣)។

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥។

| | |
|---|---|
| • ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល | • សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស<br>• សិទ្ធិបង្ហាញភស្តុតាង<br>• សិទ្ធិរបស់អនីតិជន |

ផ្នែកខាងក្រោមនេះវិភាគអំពីការអនុវត្តជាតុផ្សំពាក់ព័ន្ធផ្សេងៗ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយសាលាឧទ្ធរណ៍នៅអំឡុងពេលធ្វើរបាយការណ៍។ សម្រាប់គោលបំណងនៃការវិភាគនេះ ជាដំបូង របាយការណ៍នេះគូសបញ្ជាក់អំពីទិដ្ឋភាពផ្សេងៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានគោរពនៅសាលាឧទ្ធរណ៍ និងបន្ទាប់មកឆ្លុះបញ្ចាំងពីការអនុវត្តនានា ដែលមិនទាន់ត្រូវបានគោរពពេញលេញនូវសិទ្ធិជំនុំជម្រះដោយយុត្តិធម៌។

## ៣ .សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព

| សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានការពារនៅសាលាឧទ្ធរណ៍ |
|---|
| • សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី |
| • សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ |
| • ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ |
| • ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល |

### ៣.១ សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤ (៣)(ខ) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវមានពេលវេលា និងសម្ភារបរិក្ខាគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៨ | "[...] ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩៨ | "ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស [...]។ ជនដែលត្រូវបានជ្រើសរើសនេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ។ ក្រោយការសន្ទនាជននេះ អាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៥ | "កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃមុន ការសួរចម្លើយ។ ក្នុងថេរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី [...]" |

| | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ២៥៩ | "អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវប្រគល់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរបំផុត ១ (មួយ) ថ្ងៃ មុនពេលសវនាការ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣១៩ | "មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី [...]" |
| ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន<br>មាត្រា ២៩ | "ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្របត្រូវឱ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន។" |

បុគ្គលណាដែលប្រឈមនឹងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌគួរត្រូវបានផ្ដល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំត្រៀមការពារក្ដី។ រយៈពេលដែលថា "គ្រប់គ្រាន់" គឺអាស្រ័យទៅលើស្ថានភាពនៃសំណុំរឿង[75] ប៉ុន្តែជាគោលការណ៍ ជនជាប់ចោទចាំបាច់ត្រូវអាចរៀបចំការពារក្ដីរបស់ខ្លួនឱ្យបានសមស្របដើម្បីឆ្លើយតបទៅនឹងភស្តុតាង ការស៊ើបអង្កេតរបស់តំណាងអយ្យការ និងបង្ហាញសាក្សីការពារខ្លួនផងដែរ។ ជនជាប់ចោទមានតួនាទីស្នើសុំលើកពេលជំនុំជម្រះក្ដីរបស់ខ្លួន ប្រសិនបើខ្លួនយល់ឃើញដោយសមហេតុផលថាពេលវេលាសម្រាប់ការៀបចំការពារក្ដីគឺមិនគ្រប់គ្រាន់ទេនោះ។[76]

មធ្យោបាយចាំបាច់ក្នុងការរៀបចំការពារខ្លួនរាប់បញ្ចូលទាំងការទទួលបាននូវឯកសារ និងភស្តុតាងនានានៃសំណុំរឿងដើម្បីឱ្យជនជាប់ចោទបានដឹងអំពីបទចោទប្រកាន់មកលើខ្លួនបានពេញលេញ ហើយជនជាប់ចោទអាចមានលទ្ធភាពផ្ដល់ព័ត៌មានពេញលេញដល់មេធាវីរបស់ខ្លួន។[77] ជាពិសេស សិទ្ធិនេះក៏រួមបញ្ចូលទាំងការទទួលបានឯកសារទាំងអស់ដែលតំណាងអយ្យការគ្រោងនឹងបង្ហាញនៅក្នុងតុលាការនិងភស្តុតាងដែលដោះបន្ទុក។[78] នៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ ប្រការនេះក៏មានន័យថា ដើម្បីប្រើប្រាស់សិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ឱ្យមានប្រសិទ្ធភាព ជនជាប់ចោទគួរតែទទួលបានសាលក្រមជាលាយលក្ខណ៍អក្សររបស់សាលាដំបូង ដែលមានបញ្ជាក់ពីមូលហេតុត្រឹមត្រូវ និងប្រតិចារឹកនៃសវនាការជំនុំជម្រះដើម្បីឱ្យគាត់អាចរៀបចំការពារក្ដីរបស់ខ្លួនបាន។[79]

---

[75] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣២។

[76] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣២។

[77] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៣។

[78] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៣។

[79] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៤៩; សូមមើលឧទាហរណ៍ UN HRC Communication លេខ ១៧៩៧/២០០៨, *Mennen v. The Netherlands* (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០) វាក្យខណ្ឌ ៨.២.-៨.៤។

មានតែ ១ សំណុំរឿង ដែលមេធាវីរបស់ជនជាប់ចោទត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៅសាលាឧទ្ធរណ៍។ ចំណុចនេះមានន័យថាសិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ ត្រូវបានគោរពសម្រាប់ជនជាប់ចោទចំនួន ៧១,៣%។

បញ្ហាពេលវេលាគ្រប់គ្រាន់ និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្តីត្រូវបានលើកឡើងសម្រាប់ជនជាប់ចោទតែ ២ នៃ ១៨៣ នាក់។ ចំណុចនេះ មានន័យថា សិទ្ធិនេះត្រូវបានគោរពសម្រាប់ជនជាប់ចោទចំនួន ៧១% ។

បន្ថែមពីនេះ បុគ្គលដែលបានចោទប្រកាន់ត្រូវតែមានពេលវេលាគ្រប់គ្រាន់ និងទទួលបានការសម្របសម្រួលដើម្បីទំនាក់ទំនងជាមួយមេធាវីទៅតាមការជ្រើសរើសរបស់ខ្លួន។ បញ្ញត្តិនេះធានាឱ្យមានការគោរពគោលការណ៍ស្មើភាពគ្នា និងតម្រូវឱ្យជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីភ្លាមៗ។[80] លើសពីនេះ មធ្យោបាយដែលអាចឱ្យមានការពិភាក្សាជាសម្ងាត់រវាងជនជាប់ចោទ និងមេធាវីរបស់ពួកគេ ត្រូវតែជានា។[81]

ថ្វីបើការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ពុំបានផ្តល់ព័ត៌មានដែលចាំបាច់ទាំងអស់ដល់ ម.ស.ម.ក ដើម្បីវាយតម្លៃបានថាតើជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីរបស់ខ្លួន និងដើម្បីពិភាក្សាជាមួយមេធាវី ឬពុំមានក៏ដោយ បើយោងតាមព័ត៌មានដែលមាន ម.ស.ម.ក បានកត់សម្គាល់ឃើញជាវិជ្ជមានថា សំណុំរឿងភាគច្រើនលើសលប់ដែលបានសង្កេតការណ៍ បង្ហាញថា សិទ្ធិនេះត្រូវបានគោរព។ ម.ស.ម.ក រកឃើញថា មានតែជនជាប់ចោទ ១ នាក់ប៉ុណ្ណោះ (០,៤% នៃជនជាប់ចោទ) ដែលមេធាវីការពារត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍ ហើយសំណុំរឿងភាគច្រើនសុទ្ធតែមានមេធាវីនៅមុនពេលដំណើរការនីតិវិធី។ ចំណុចនេះបង្ហាញអំពីការថយចុះ បើធៀបទៅនឹងកាលពីពីរឆ្នាំមុន ដែលមាន ២% នៃជនជាប់ចោទនៅក្នុងឆ្នាំ២០១៨/២០១៩ និង ៥% នៅក្នុងឆ្នាំ២០១៧/២០១៨ ដែលមេធាវីត្រូវបានចាត់តាំងនៅថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍តែម្តង។ លើសពីនេះ មានតែពីរករណីប៉ុណ្ណោះដែលមេធាវីរបស់ជនជាប់ចោទបានលើកឡើងអំពីបញ្ហានៃកង្វះការរៀបចំការការពារក្តី។

## ៣.២ សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(១) | "[...] ប៉ុន្តែការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣១៧ | "នៅក្នុងគ្រប់ករណីទាំងអស់សាលក្រមត្រូវប្រកាសនៅពេលសវនាការជាសាធារណៈ។" |

[80] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៤។

[81] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៤។

| | |
|---|---|
| ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ<br>មាត្រា ៧ | "[...] នៅគ្រប់ករណីទាំងអស់ សាលក្រម និងសាលដីកាតុលាការ ត្រូវប្រកាសនៅក្នុងសាលសវនាការដែលបើកជាសាធារណៈ [...]" |

យោងតាមមាត្រា ១៤(១) ទោះបីជាសាធារណជនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមស្តាប់ការជំនុំជម្រះក៏ដោយ សេចក្តីសម្រេច រួមមាន របកគំហើញសំខាន់ៗ ភស្តុតាង និងសំអាងហេតុផ្លូវច្បាប់ត្រូវតែប្រកាសជាសាធារណៈ។[82] មានតែករណីលើកលែងតិចតួចប៉ុណ្ណោះសម្រាប់វិធាននេះ ឧទាហរណ៍នៅក្នុងករណីផលប្រយោជន៍របស់អនីតិជនតម្រូវមិនឱ្យប្រកាសសេចក្តីសម្រេចជាសាធារណៈ (សូមមើលផ្នែក ៤.៨. សិទ្ធិអនីតិជន)។[83]

សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈគឺជាចំណុចគន្លឹះដើម្បីធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព។ ប្រជាជនគ្រប់រូបត្រូវតែអាចមើលឃើញថាយុត្តិធម៌ត្រូវបានផ្តល់ជូនពិតប្រាកដមែន លើសពីនេះ ការអនុញ្ញាតឱ្យសាធារណជនចូលរួមនៅក្នុងសវនាការ អាចជួយកម្រិតលទ្ធភាពចៅក្រមក្នុងការប្រព្រឹត្តតាមតែចិត្តរបស់ខ្លួន។ ប្រការសំខាន់មួយទៀតគឺការទទួលបានព័ត៌មានផ្លូវច្បាប់ ដោយហេតុថាព័ត៌មានទាំងនេះនឹងអាចឱ្យសាធារណជនដឹងអំពីប្រភេទនៃឥរិយាបថដែលបានអនុញ្ញាត ឬហាមឃាត់ដោយច្បាប់។

ផែនការយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល ឆ្នាំ២០១៤-២០១៨ មានគោលបំណងណែនាំអំពី "ទិន្នន័យចុះបញ្ជីតុលាការតាមប្រព័ន្ធព័ត៌មាន" និងលើកកម្ពស់ "លទ្ធភាពទទួលបានព័ត៌មានអំពីតុលាការ រាប់បញ្ចូលទាំងព័ត៌មានអំពីសេចក្តីសម្រេចរបស់តុលាការ និងរបាយការណ៍ស្តីពីដំណើរការនីតិវិធី របាយការណ៍រដ្ឋបាលតាមពេលកំណត់ និងព័ត៌មានរដ្ឋបាលទាក់ទងនឹងសំណុំរឿងដែលមិនទាន់ជំនុំជម្រះ ដូចជាព័ត៌មានអំពីស្ថានភាព និងកាលវិភាគសវនាការ" ផងដែរ។[84] កិច្ចការនេះត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាលឆ្នាំ ២០១៩-២០២៣ ដែលចែងអំពីការបង្កើត "ប្រព័ន្ធថ្មីសម្រាប់ការគ្រប់គ្រងបញ្ជីសំណុំរឿង"។[85] ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ថ្វីបើមានកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងក្តី ឧទាហរណ៍ ដើម្បីផ្សព្វផ្សាយកាលវិភាគសវនាការតុលាការ ព័ត៌មានសំខាន់ៗ ជាពិសេស សេចក្តីសម្រេចរបស់តុលាការ ភាគច្រើននៅតែមិនទាន់មានការផ្សព្វផ្សាយជាសាធារណៈនៅឡើយនោះទេ។ នៅឆ្នាំ២០១៩ ក្រសួងយុត្តិធម៌បានប្រកាសថា ខ្លួនអាចបង្កើតមូលដ្ឋានទិន្នន័យនៅក្នុងរាជធានីភ្នំពេញ ដើម្បីសម្របសម្រួលដល់ការប្រមូល និងវិភាគទិន្នន័យពីសាលាដំបូង។[86] ប៉ុន្តែរហូតមកដល់ពេលនេះ នៅមិនទាន់មានព័ត៌មានបញ្ជាក់ថ្មីនោះទេ។

---

[82] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ២៩។

[83] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ២៩។

[84] រដ្ឋាភិបាល "ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ" (២០១៤-២០១៨) វាក្យខណ្ឌ ២.១៦ <http://cdc-crdb.gov.kh/cdc/documents/NSDP_២០១៤-២០១៨.pdf>។

[85] រដ្ឋាភិបាល "ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ" (២០១៩-២០២៣) ទំព័រ ១២៦-១២៧, វាក្យខណ្ឌ ៤.២៦ <http://www.mop.gov.kh/DocumentEN/NSDP%20២០១៩-២០២៣%20in%20English.pdf>។

[86] ការិយាល័យឧត្តមស្នងការ "របាយការណ៍ប្រចាំឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាន UN OHCHR" វាក្យខណ្ឌ ៣៥។ <https://cambodia.ohchr.org/sites/default/files/Ohchr-report/Role%20and%20achievements%20of%20the%20Office.pdf>។

ទោះបីជាក្រុមប្រឹក្សាធម្មនុញ្ញបានផ្សព្វផ្សាយអំពីសេចក្តីសម្រេចរបស់ខ្លួនជាប្រចាំ[87]យ៉ាងណាក៏ដោយ សេចក្តីសម្រេចមកពីតុលាការផ្សេងទៀតគឺពិបាកនឹងស្វែងរកណាស់។ ប៉ុន្តែ នៅដើមខែមករា ឆ្នាំ២០២១ អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន បានប្រកាសអំពី "ការចាប់ផ្តើមផ្សព្វផ្សាយអំពីសាលក្រម" រួមទាំងសំណុំរឿងព្រហ្មទណ្ឌផងដែរ។[88] សេចក្តីប្រកាសនេះ គឺជាការវិវឌ្ឍដ៏គួរឱ្យស្វាគមន៍មួយ ដោយសារតែភាពខ្វះខាតនៃតម្លាភាពនៅជុំវិញសេចក្តីសម្រេចរបស់តុលាការធ្វើឱ្យការអនុវត្តច្បាប់មិនអាចអនុវត្តបាន ហើយបានរារាំងមេធាវីពីការបង្កើនប្រសិទ្ធភាពការពារផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព។

*តួលេខទី ៥៖ សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ*[89]




នៅគ្រប់សំណុំរឿងទាំងអស់ដែលព័ត៌មានត្រូវបានទទួល (១៧) សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈត្រូវបានគោរព។

## ៣.៣ ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (គោលការណ៍នៃនីត្យានុកូលភាព)

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ស.ស.ស.ម<br>មាត្រា ១១(២) | "គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយបានប្រព្រឹត្ត ឬភ្លាំងភ្លាត់ប្រព្រឹត្ត ដែលអំពើនេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិ។ មិនត្រូវផ្តន្ទាទោសឱ្យធ្ងន់ជាងទោស ដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេលបទល្មើសបានកើតឡើងឡើយ។ |
| ក.អ.ស.ព.ន<br>មាត្រា ១៥ | "គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទ |

87 "រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" គេហទំព័រ <http://www.ccc.gov.kh>។

88 នាម ឆេង "សេចក្តីសម្រេចរបស់តុលាការ" ត្រូវបានផ្សព្វផ្សាយទុកសម្រាប់ជាប្រភពយោង" (ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១) <https://www.phnompenhpost.com/national/courts-decisions-now-published-reference-source>។

89 ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប ២០៣ នាក់ ដែលពាក់ព័ន្ធក្នុងសំណុំរឿងដែលបានសង្កេតការណ៍។ "មិនដឹង" សំដៅលើសំណុំរឿងមិនទទួលបានព័ត៌មាន ឬសំណុំរឿងដែលមិនត្រូវបានតាមដានបន្តដោយសារអ្នកសង្កេតការណ៍សវនាការមិនមានវត្តមាននៅថ្ងៃប្រកាសសាលដីកា។

| | |
|---|---|
| | ល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុនជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងមុន។ គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើឬការខកខាននោះជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។" |
| ក្រមព្រហ្មទណ្ឌ មាត្រា ៣ | "មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះ មានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបផ្តន្ទាទោសព្រហ្មទណ្ឌបាន។" |
| ក្រមព្រហ្មទណ្ឌ មាត្រា ១០ | "បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ ប៉ុន្តែការផ្តន្ទាទោសជាស្ថាពរ ហើយនោះ ត្រូវអនុវត្តទោះបីជាទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ។" |

មាត្រា ១៥ នៃ ក.អ.ស.ព.ន ចែងអំពីគោលការណ៍នៃនីត្យានុកូលភាព និងបានហាមឃាត់មិនឱ្យមានការអនុវត្តប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដោយឆ្លុះបញ្ចាំងនូវគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង *(nullum crimen sine lege*) និងគ្មានទោស បើគ្មានច្បាប់ចែង *(nulla poena sine legel)*។ គោលការណ៍នេះមានន័យថា គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដោយស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះដែរ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។

> ចំនួនសវនាការដែលបានសង្កេតការណ៍ ១០០% ច្បាប់ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ គឺចូលជាធរមាននៅថ្ងៃដែលបទល្មើសត្រូវបានប្រព្រឹត្ត។

ពុំមានសំណុំរឿងណាមួយក្នុងចំណោមសំណុំរឿងជំនុំជម្រះដែលបានសង្កេតការណ៍ទាំង ២០៣ បានបង្ហាញថាច្បាប់ដែលត្រូវបានប្រើប្រាស់ដើម្បីកាត់ទោសជនជាប់ចោទ មិនមានជាធរមាននោះទេ នៅកាលបរិច្ឆេទកើតបទល្មើសដែលត្រូវបានចោទប្រកាន់។ អាស្រ័យហេតុនេះ របបគំហើញរបស់ ម.ស.ម.ក បង្ហាញថាការការពារប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌគឺត្រូវបានការពារ។ និន្នាការនេះមានភាពស៊ីសង្វាក់ចាប់តាំងពី២០១៤ មកម្ល៉េះ។

## ៣.៤ ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល

មាត្រា ១៤(៧) នៃ ក.អ.ស.ព.ន មានចែងអំពីគោលការណ៍ការហាមឃាត់ការវិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល *(ne bis in idem)* ហើយបានចែងថាគ្មានជនណាម្នាក់ត្រូវបានយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។[90] ការហាមឃាត់នេះមិនបានហាមការជំនុំជម្រះក្តីឡើងវិញលើជនណាម្នាក់

[90] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៥៤។

បន្ទាប់ពីតុលាការជាន់ខ្ពស់បដិសេធការផ្តន្ទាទោស ការសន្មតទុកនៃការជំនុំជម្រះបទល្មើសប្រសិនបើត្រូវបានផ្តល់ហេតុផលដោយ "ករណីលើកលែង" ដូចជា ការរកឃើញភស្តុតាងថ្មី។[91] មានអត្ថប្រយោជន៍ជាច្រើនសម្រាប់តែបុគ្គលជាជនជាប់ចោទ និងសង្គមទាំងមូល ក្នុងការទទួលបានសេចក្តីសម្រេចចុងក្រោយ រួមទាំងការផ្តល់ភាពច្បាស់លាស់ផ្នែកច្បាប់ និងបង្ការការខ្ជះខ្ជាយធនធានផ្នែកច្បាប់ផងដែរ។

> នៅក្នុងសវនាការដែលបានសង្កេតការណ៍ទាំង ១០០% ពុំមានការលើកឡើងថាជនជាប់ចោទត្រូវបានជុំនុំជម្រះ និងកាត់ទោសចំពោះបទល្មើសពីមុននោះទេ។

សូមកត់សម្គាល់ថាគ្មានជនជាប់ចោទណាម្នាក់ក្នុងចំណោមជនជាប់ចោទចំនួន ២៥៥ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ករណី ដែលម.ស.ម.ក បានសង្កេតការណ៍ត្រូវបានជំនុំជម្រះនិងដាក់ទោសសម្រាប់បទល្មើសដដែលដែលបានប្រព្រឹត្តកាលពីមុនឡើយ។ ដូច្នេះការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែលគឺត្រូវបានធានា។ សូមបញ្ជាក់ថា និន្នាការនេះបានកើតឡើងយ៉ាងស៊ីសង្វាក់ចាប់តាំងពី២០១៤ មកម្ល៉េះ ។

[91] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៥៦។

## ៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនទាន់ត្រូវបានគោរពពេញលេញ

សិទ្ធិមួយចំនួនមិនទាន់ត្រូវបានធានា និង/ឬការមិនទាន់អនុវត្តបានពេញលេញនៅឡើយ ហេតុដូច្នេះបានគំរាមកំហែងដល់សិទ្ធិបុគ្គលក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សិទ្ធិទាំងនេះមានដូចជា៖

- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព
- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ
- សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិរបស់អនីតិជន

### ៤.១ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ស.ស.ស.ម<br>មាត្រា ៥ | "គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្ម ឬការប្រព្រឹត្តិកម្មកាចសាហាវផុតមនុស្សធម៌ ឬថោកទាបបានឡើយ។" |
| ក.អ.ស.ព.ន<br>មាត្រា ១៤<br>(៣)(ឆ) | "ក្នុងការសម្រេចសេចក្ដីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៣៨ | "ច្បាប់នេះហាមឃាត់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១៤៥ | "[...] ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជន ត្រូវចោទដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីអំពីអវត្តមាននេះ ត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣២១ | "[...] ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ [...]" |

| | |
|---|---|
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥ | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ [...] មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជនឡើយ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស ត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [...] សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង [...]" |

មាត្រា ១៤(៣)(ឆ) នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិបុគ្គល "មិនត្រូវបានបង្ខិតបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង ឬឱ្យសារភាពពីពិរុទ្ធភាព"។[92] សិទ្ធិនេះមានពីរផ្នែក៖ ទីមួយ ជនសង្ស័យ ឬជនជាប់ចោទមិនត្រូវបានបង្ខិតបង្ខំ ឬជំរុញឱ្យផ្តល់ភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ។ នៅក្នុងការអនុវត្តជាក់ស្តែង ចំណុចនេះមានន័យថា នៅពេលជនសង្ស័យ ឬជនជាប់ចោទសារភាព ការសារភាពនោះត្រូវធ្វើឡើងដោយពុំមានការបង្ខិតបង្ខំផ្លូវកាយ ឬផ្លូវចិត្តដោយផ្ទាល់ ឬដោយប្រយោលណាមួយឡើយ។[93] ដូច្នេះសិទ្ធិនេះមានភាពជាប់ទាក់ទងយ៉ាងជិតស្និតជាមួយនឹងការហាមឃាត់ដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិប្រឆាំងទារុណកម្ម និងទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដូចមានចែងនៅក្នុងមាត្រា ៧ នៃ ក.អ.ស.ព.ន។ ប្រសិនបើការសារភាព ឬការថ្លែងណាមួយបានធ្វើឡើងដោយការបង្ខិតបង្ខំ ទារុណកម្ម ឬការធ្វើបាបឯទៀត នោះត្រូវដកចេញពីភស្តុតាង លើកលែងតែត្រូវបានប្រើប្រាស់ជាភស្តុតាងដែលបញ្ជាក់ថា ការបង្ខិតបង្ខំ ឬការធ្វើទារុណកម្ម ឬការប្រព្រឹត្តឯទៀតដែលត្រូវបានហាមឃាត់ដោយមាត្រា ៧ នៃ ក.អ.ស.ព. បានកើតឡើងប៉ុណ្ណោះ។[94]

[92] សូមមើលផងដែរអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០(២)(ខ)(iv)។

[93] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៤១; សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ *សំណុំរឿង Deolall ទល់នឹង Guyana* សេចក្តីសម្រេចលេខ ៩១២/២០០០ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨២/D/៩១២/២០០០ (ឆ្នាំ២០០៤) វាក្យខណ្ឌ ៥.១ http://juris.ohchr.org/Search/Details/1149។ ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *សំណុំរឿង Singarasa ទល់នឹងប្រទេសស្រីលង្កា*, សេចក្តីសម្រេចលេខ ១០៣៣/២០០១ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨១/D/១០៣៣/២០០ (ឆ្នាំ២០០៤) វាក្យខណ្ឌ ៧.៤http://juris.ohchr.org/Search/Details/1125។ UN HRC *សំណុំរឿង Khuseynova and Butaeva ទល់នឹងប្រទេសតាជីគីស្ថាន* សេចក្តីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ នៅក្នុងឯកសាររបស់ អ.ស.ប CCPR/ C/៩៤/D/១២៦៣–១២៦៤/២០០៤ (ឆ្នាំ២០០៨) វាក្យខណ្ឌ ៨.៣ http://juris.ohchr.org/Search/Details/1457។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាំង ហ្គិច អ៊ាវ ហៅ ឌុច (សំណុំរឿងលេខ ០០១) អង្គជំនុំជម្រះ សាលក្រម (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) វាក្យខណ្ឌ ៣៦០ ("បច្ចេកទេសសួរចម្លើយខាងក្រោម [...] បានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរលើរូបរាងកាយ និងស្មារតីក្នុងគោលបំណងបង្ខំឱ្យសារភាព ឬទទួលទោស ហើយបង្កើតទៅជាអំពើទារុណកម្ម៖ ការវាយដំធ្ងន់ធ្ងរ ឆក់ខ្សែភ្លើង យកថង់ប្លាស្ទីកគ្របមុខ ដាក់ក្រណាត់សើមគ្របមុខ យកម្ជុលចាក់ ឬដកក្រចកដៃ ក្រចកជើង ដុតបារី បង្ខំជនជាប់ឃុំឱ្យគោរពរូបឆ្កែ ឬរបស់របរ ការបង្ខំឱ្យស៊ីលាមក និងផឹកទឹកនោម ការគំរាមកំហែងធ្វើទារុណកម្ម ឬសម្លាប់ដោយផ្ទាល់ ឬដោយប្រយោលលើជនជាប់ឃុំឃាំង ឬសមាជិកគ្រួសារ ការប្រើប្រាស់ភាសាបំបាក់ស្មារតី ការធាក់ជនជាប់ឃុំ ការជ្រមុជក្បាលចូលក្នុងទឹក និងការចងស្លាបសេកទៅក្រោយលើកឡើងលើ និងការរំលោភសេពសន្ថវៈជាក់ស្តែង")។

[94] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៤១។

ទីពីរ ជនសង្ស័យ/ជនជាប់ចោទមិនអាចត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាពខ្លួនឯងតាមរយៈការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ និយាយម្យ៉ាងទៀតបានន័យថា ជនសង្ស័យ/ជនជាប់ចោទត្រូវតែទទួលបានសិទ្ធិដែលមិនអាចដកហូតបានក្នុងការមិនផ្តល់ភស្តុតាងដែលអាចត្រូវបានយកទៅប្រើប្រាស់ប្រឆាំងពួកគេ។[95] ប្រសិនបើជនម្នាក់បដិសេធក្នុងការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសារភាពទោសកំហុស ស្ថានភាពដែលចៅក្រមចេញសេចក្តីសន្និដ្ឋានជាអវិជ្ជមានពីការនៅស្ងៀមនេះត្រូវបានហាមឃាត់។[96] ក្នុងករណីនៃអនីតិជន ច្បាប់នេះមានលក្ខណៈកាន់តែទូទៅថែមទៀត៖ ពួកគេមិនត្រូវបានបង្ខិតបង្ខំ "ឱ្យផ្តល់សក្ខីកម្ម" ឡើយ។[97] សិទ្ធិនេះក៏ត្រូវបានធានាតាមមាត្រាទាំងអស់នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ជាពិសេសមាត្រា ១៥[98] ពីព្រោះសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាពនេះគ្របដណ្តប់លើការហាមឃាត់ជាដាច់ខាតប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

### *តួលេខទី ៦៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព*[99]




---

[95] ក.អ.ស.ព.ន មាត្រា ១៤ (៣)(ធ); មាត្រា ១៤ (៣) (ធ) សូមមើលកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៤០ (២)(ខ)(iv)។

[96] *Condron v. the United Kingdom* (ECtHR, ២០០០) វាក្យខណ្ឌ ៥៦ <http://hudoc.echr.coe.int/eng?i=001-58798>; *Beckles v. the United Kingdom* (ECtHR, ២០០២) វាក្យខណ្ឌ ៥៨ <http://hudoc.echr.coe.int/eng?i=001-60672>។

[97] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៤០(២)(ខ)(iv)។

[98] អនុសញ្ញាស្តីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប មាត្រា ១៥៖ *"រដ្ឋភាគីត្រូវធានាថា ឯកសារពោយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសារពោយការណ៍នោះ ត្រូវបានធ្វើសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម។*
<http://cambodia.ohchr.org/sites/default/files/Treaty/CAT-EN.pdf>។

[99] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (២៥៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍។ មិនពាក់ព័ន្ធ គឺមិនមានវត្តមានជនជាប់ចោទ ឬមេធាវី ដូច្នេះមិនមាននរណាលើកអំពីបញ្ហានេះ។

នៅអំឡុងពេលធ្វើរបាយការណ៍ ជនជាប់ចោទចំនួន ៤ នាក់ក្នុងចំណោម ២៥៥ នាក់ដែលបានលើកឡើងថា ពួកគេត្រូវបានសួរចម្លើយដោយគ្មានវត្តមានមេធាវី។ ជនជាប់ចោទចំនួន ពីរនាក់បានលើកឡើងថា ពួកគេបានរងការគំរាមកំហែងឱ្យសារភាព ខណៈដែលជនជាប់ចោទចំនួន ១៧ នាក់ (៦,៧%) បានលើកឡើងថា ពួកគេទទួលរងការប្រើអំពើហិង្សា ឬទារុណកម្ម ដើម្បីឱ្យពួកគេសារភាពចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ នៅអំឡុងពេលសាកសួរដោយនគរបាលយុត្តិធម៌។ ទិន្នន័យនេះបង្ហាញអំពីការកើនឡើងបន្តិចបន្តួច បើធៀបទៅនឹងអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៨/២០១៩ ដែលនេះគឺជាក្ដីបារម្ភយ៉ាងខ្លាំង ដែលចំណុចនេះបង្ហាញថាមិនមានការកែលម្អសំខាន់ៗណាមួយត្រូវបានធ្វើឡើងឡើយ ទោះបីជាបញ្ហានេះ ត្រូវបានលើកឡើងដល់សាលាឧទ្ធរណ៍ហើយក៏ដោយ។

***វាក្យសព្ទច្បាប់ស្ដីពីសិទ្ធិមនុស្សអន្តរជាតិ៖***

- *សិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិ៖ ជាសិទ្ធិមួយដែលការអនុវត្តមិនអាចព្យួរបានដោយរដ្ឋាភិបាល ទោះជានៅក្នុងកាលៈទេសៈ "គ្រាមានអាសន្ន" នៅក្រោមមាត្រា ៤ នៃ ក.អ.ស.ព.ន។*
- *សិទ្ធិដាច់ខាត៖* សិទ្ធិដែលពុំអនុញ្ញាតឱ្យមានការរឹតត្បិត។
- *គោលការណ៍មូលដ្ឋាននៃច្បាប់អន្តរជាតិទូទៅ (គោលការណ៍ ជូស យូហ្សិន្ទ (jus cogens))៖* "[ក] គឺជាបទដ្ឋានដែលត្រូវបានទទួលយក និងទទួលស្គាល់ដោយសហគមន៍អន្តរជាតិថាជាបទដ្ឋាន ដែលហាមឃាត់មិនឱ្យមានបដិប្បញ្ញត្តិ និងអាចកែសម្រួលបានតែតាមរយៈបទដ្ឋានបន្តបន្ទាប់នៃច្បាប់អន្តរជាតិទូទៅដែលមានលក្ខណៈចរិតដូចគ្នាតែប៉ុណ្ណោះ"។[100]

ថ្វីបើចំនួនសំណុំរឿងដែលមានសញ្ញាណបញ្ជាក់អំពីការបង្ខិតបង្ខំ ឬការធ្វើទារុណកម្ម (ផ្លូវចិត្ត ឬផ្លូវកាយ) ក្នុងអំឡុងពេលសួរចម្លើយមានចំនួនតិចតួចក្តី ប៉ុន្តែនេះជាបញ្ហាគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងផងដែរ។ ជាការពិតណាស់ ការហាមឃាត់ការធ្វើទារុណកម្មមានចែងយ៉ាងពិសេសនៅក្នុងច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ។ សិទ្ធិនេះមិនត្រឹមតែជាសិទ្ធិបដិប្បញ្ញត្តិ តែសិទ្ធិនេះក៏ជាសិទ្ធិដាច់ខាតផងដែរ។ មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ការហាមឃាត់ការធ្វើទារុណកម្មគឺជាបទដ្ឋានមូលដ្ឋាននៃច្បាប់អន្តរជាតិទូទៅ *(គោលការណ៍ ជូស យូហ្សិន (jus cogens))*។[101]

សាលាឧទ្ធរណ៍ចាំបាច់ត្រូវស៊ើបអង្កេតលើអំណះអំណាងទាំងអស់នេះឱ្យសព្វជ្រុងជ្រោយ។ ប្រសិនបើការលើកឡើងអំពីការបង្ខិតបង្ខំណាមួយត្រូវបានបង្ហាញជាភស្តុតាងថាជាការពិតក្រោយការស៊ើបអង្កេត ចៅក្រមមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការចេញសេចក្តីសម្រេចដាក់ភស្តុតាងក្រោមការសារភាព ដែលបានធ្វើឡើងនោះជាភស្តុតាងមិនអាចទទួលយកបានក្នុងតុលាការ និងមានមូលដ្ឋានសមហេតុផលដើម្បីជឿជាក់ថា ការសារភាពនោះត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំ។ ថ្វីបើបញ្ហានេះគួរត្រូវបានដោះស្រាយក្នុងដំណាក់កាលស៊ើបសួរក្តី ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ត្រូវរក្សាការប្រុងប្រយ័ត្ន និងធានាថា រាល់អំណះអំណាងស្តីពីការបង្ខិតបង្ខំដែលពុំត្រូវបានដោះស្រាយក្នុងអំឡុងពេលមុន

---

[100] គណៈកម្មការច្បាប់អន្តរជាតិ "របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីការងារនៃសម័យប្រជុំលើកទី៧១" កំណត់ត្រាផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី៧៤ ឯកសារបំពេញបន្ថែមលេខ ១០ (A/៧៤/១០), (ឆ្នាំ២០១៩), វាក្យខណ្ឌ ៥៦, អាចរកបាននៅ <https://legal.un.org/ilc/reports/2019/>។

[101] M. Nowak, *U.N. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់អង្គការសហប្រជាជាតិ* (2nd edn, N.P. Engel ២០០៥), ទំព័រ ១៥៧។

សវនាការនោះ ត្រូវបានស៊ើបអង្កេតសព្វជ្រុងជ្រោយ មុនពេលសវនាការត្រូវបានអនុញ្ញាតឱ្យបន្តទៅមុខទៀត។ ឆ្លើយតបនឹងចំណុចនេះ សាលាឧទ្ធរណ៍បានលើកឡើងថា នៅក្នុងករណីខ្លះ ជនជាប់ចោទបានកែចម្លើយនៅមុខសាលាឧទ្ធរណ៍ ដោយសំអាងថាចម្លើយរបស់ខ្លួននៅមុខនគរបាលយុត្តិធម៌មិនពិត ដោយសារមានការគំរាមកំហែង ការប្រើហិង្សា ឬការគៀបសង្កត់ផ្សេងៗ ប៉ុន្តែការលើកឡើងនេះពុំមានភស្តុតាងបញ្ជាក់សោះទេ។ ក្នុងករណីនេះ បើតុលាការយល់ឃើញថា ការកែប្រែចម្លើយគ្មានមូលហេតុត្រឹមត្រូវ ដោយផ្អែកលើចម្លើយសារភាពរបស់ជនជាប់ចោទនៅមុខនគរបាលយុត្តិធម៌ អយ្យការអមសាលាដំបូង ចៅក្រមស៊ើបសួរ និងក្នុងនីតិវិធីជំនុំជម្រះសាលាដំបូង ដែលជនជាប់ចោទមិនបានស្នើសុំកែប្រែចម្លើយ នាំឱ្យសាលាឧទ្ធរណ៍មិនអាចជឿបានលើការកែប្រែចម្លើយនោះ សាលាឧទ្ធរណ៍មិនចាំបាច់ចាត់របៀបស៊ើបអង្កេតលើករណីនេះឡើងវិញទេ។[102]

## ៤.២ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤ (១) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ឬសិទ្ធិរបស់ខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣៩២ | "ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការជាសាធារណៈ។" |
| ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ<br>មាត្រា ៧ | "ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការជាសាធារណៈ។" |

***ការជោនាក្នុងករណីនៃសវនាការជាអសាធារណៈ***

ទោះបីជាក្នុងករណីដែលសាធារណជនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងសវនាការដោយសារតែករណីលើកលែងមួយចំនួនក៏ដោយ នៅតែមានការការពារដើម្បីធានានូវសាធារណភាពផងដែរ។ នៅក្នុងស្ថានភាពបែបនេះ សេចក្តីសម្រេច រាប់បញ្ចូលទាំងរបបគំហើញសំខាន់ៗ ភស្តុតាង និងសំអាងហេតុផ្លូវច្បាប់ ត្រូវតែធ្វើការផ្សព្វផ្សាយជាសាធារណៈ។[103]មានតែនៅក្នុងករណីតិចតួចប៉ុណ្ណោះ(ឧ. ប្រសិនបើចាំបាច់ដើម្បីផលប្រយោជន៍របស់អនីតិជន) អាចជាករណីលើកលែងចំពោះការការពារលើកចុងក្រោយនេះ។

---

[102] លិខិតឆ្លើយតបរបស់សាលាឧទ្ធរណ៍ភ្នំពេញ លេខ ៤៣១ បឧ/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ លើសេចក្តីព្រាងរបាយការណ៍របស់ ម.ស.ម.ក ឆ្នាំ២០១៩/២០២០។

[103] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ២៩។

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការសម្រេចថាមានពិរុទ្ធភាព ឬគ្មានទោសនៅក្នុងសវនាការជាសាធារណៈ លើកលែងតែក្នុងករណីពិសេសជាក់លាក់មួយចំនួន។ ក្នុងចំណោមមូលហេតុដែលអាចជំរុញឱ្យតុលាការចេញបទបញ្ជាឱ្យមានសវនាការជាអសាធារណៈពេញលេញ ឬផ្នែកខ្លះគឺដោយសារតែសវនាការសាធារណៈជាហានិភ័យ និងបង្កឱ្យមាន "*ការប៉ះពាល់ធ្ងន់ធ្ងរ*"ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ឬសីលធម៌ ផលប្រយោជន៍នៃជីវិតឯកជនរបស់ភាគី (ជាពិសេសសំណុំរឿងបំពានខាងផ្លូវភេទមួយចំនួន) ឬវត្តមានជនជាប់ចោទជាអនីតិជន[104] (សូមមើល ៤.៨. សិទ្ធិរបស់អនីតិជន)។ លើកលែងតែនៅក្នុងស្ថានភាពពិសេសមួយចំនួនដែលមានចែងដោយច្បាប់មិនអាចអនុញ្ញាតឱ្យសាធារណជនទាំងអស់ ឬមួយចំនួន ចូលរួមបានឡើយ។ នៅក្នុងកាលៈទេសៈផ្សេងទៀត សវនាការត្រូវតែបើកចំហចំពោះសាធារណជន រួមមាន អ្នកសារព័ត៌មាន និងមិនអាចផាត់ចេញនូវប្រភេទបុគ្គលជាក់លាក់មួយចំនួនឡើយ។[105] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ក៏មានពាក់ព័ន្ធនឹងកាតព្វកិច្ចដែលតុលាការត្រូវផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងពេលវេលា និងទីតាំងសវនាការដល់សាធារណជន និងផ្តល់មធ្យោបាយមានគ្រប់គ្រាន់ក្នុងកម្រិតសមហេតុផលសម្រាប់ឱ្យសាធារណជនចូលរួម។[106]

### *តួលេខទី ៧៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ*[107]







ការជូនដំណឹងអំពីសវនាការ ការបង្ហាញកាលបរិច្ឆេទ ទីតាំង និងពេលវេលាចាប់ផ្តើមសវនាការដាក់នៅខាងក្រោមបន្ទប់សវនាការគឺជាវិធីនៃការលើកកម្ពស់សវនាការជាសាធារណៈតាមរយៈការជូនដំណឹងដល់សាធារណជន ដែល

---

[104] គណៈកម្មាធិការសិទ្ធិកុមារអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ២៤ នៅក្នុងសិទ្ធិរបស់កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌កុមារ (ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៩) CRC/C/GC/២៤, វាក្យខណ្ឌ ៦៧ http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d%2FPPRiCAqhKb7yhsqIkirKQZLK2M58RF%2F5F0vEnG3QGKUxFivhToQfjGxYjV05tUAIgpOwHQJsFPdJXCiixFSrDRwow8HeKLLh8cgOw1SN6vJ%2Bf0RPR9UMtGkA4, ("គណៈកម្មាធិការសិទ្ធិកុមារអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ២៤")។

[105] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ២៩។

[106] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ២៨; UN HRC, *Van Meurs v. The Netherlands*, Communication No. ២១៥/១៩៨៦, UN Doc. CCPR/C/៣៩/D/២១៥/១៩៨៦ (១៩៩០) វាក្យខណ្ឌ ៦.២ <http://juris.ohchr.org/Search/Details/311>។

[107] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍។

គូរត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់សវនាការដែលការជំនុំជម្រះត្រូវបានធ្វើឡើង។ នៅឆ្នាំ២០១៧ និង ឆ្នាំ២០១៨ សាលាឧទ្ធរណ៍[108]ទទួលស្គាល់អំពីកង្វះខាតការជូនដំណឹងអំពីសវនាការ ពាក់ព័ន្ធនឹងកាលវិភាគរបស់តុលាការ ហើយបានប្រាប់ ម.ស.ម.ក ថា ពួកគេនឹងចាត់វិធានការ ដើម្បីពង្រឹងការផ្តល់ព័ត៌មានជូនសាធារណជន និងការចូលស្តាប់សវនាការ។ នៅឆ្នាំ២០១៩ សាលាឧទ្ធរណ៍បានបញ្ជាក់ថា ការបង្ហាញកាលវិភាគសវនាការជាសាធារណៈគឺជាបញ្ហារដ្ឋបាល និងមិនតម្រូវដោយច្បាប់ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ សាលាឧទ្ធរណ៍បានកំណត់អាទិភាពបញ្ហានេះ និងបានបង្កើតគេហទំព័រ ដើម្បីបង្ហោះព័ត៌មានអំពីសំណុំរឿងដែលបានមកជាបន្តបន្ទាប់ ព្រមទាំងកាលវិភាគសវនាការ។ ឥឡូវនេះ ព័ត៌មានទាំងនេះអាចរកបាន និងត្រូវបានផ្តល់ជូនដូចជាកាលបរិច្ឆេទ ពេលវេលា និងទីតាំងសវនាការ លេខសំណុំរឿង បទចោទប្រកាន់និងឈ្មោះចៅក្រម។ នៅអំឡុងពេលធ្វើរបាយការណ៍នេះ ការជូនដំណឹងអំពីសវនាការត្រូវបានបិទផ្សាយនៅខាងក្រៅបន្ទប់សវនាការតែចំនួន ៣១ (១៥%) ក្នុងចំណោមសវនាការដែលបានសង្កេតការណ៍ចំនួន ២០៣ សំណុំរឿង។ ចំនួននេះបង្ហាញអំពីភាពល្អប្រសើរចាប់ពីអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៨/២០១៩ ដែលការជូនដំណឹងអំពីសវនាការមិនត្រូវបានបិទផ្សាយចំពោះសវនាការដែលបានសង្កេតការណ៍ចំនួន ២៣៩ សំណុំរឿង។ ប៉ុន្តែ កង្វះការជូនដំណឹងអំពីសវនាការបានកើតឡើងជាប់ជាប្រចាំចាប់តាំងពីឆ្នាំ២០១៤ មកម្ល៉េះ ហើយនេះគឺជាការសំខាន់ដែលថា ជំហានដ៏រឹងមាំត្រូវបានអនុវត្តដើម្បីដោះស្រាយចំណុចខ្វះខាតចំពោះសវនាការទាំងអស់នៅសាលាឧទ្ធរណ៍សម្រាប់សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ដែលត្រូវចាត់ទុកថាត្រូវបានគោរពពេញលេញ។

ពាក់ព័ន្ធនឹងសវនាការដែលនៅតែមានភាពបើកចំហចំពោះសាធារណជន និងប្រព័ន្ធផ្សព្វផ្សាយ នេះគឺជាចំណុចគួរឱ្យស្វាគមន៍ដែលថា នៅអំឡុងពេលធ្វើរបាយការណ៍នេះ សាធារណជន ឬប្រព័ន្ធផ្សព្វផ្សាយមិនត្រូវបានរារាំង ឬបណ្តេញចេញពីបន្ទប់សវនាចំពោះសវនាការដែលបានសង្កេតការណ៍ទាំងអស់ចំនួន ២០៣ (១០០%) សំណុំរឿង។

## ៤.៣ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤ (៣)(ក) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។" |
| **ក.អ.ស.ព.ន មាត្រា ១៤(៣)(ច)** | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ។" |

[108] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានជួបជាមួយសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាអំពីរបកគំហើញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៦/២០១៧ និងរបាយការណ៍ ឆ្នាំ២០១៧/២០១៨។

| | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២២ | "ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។" |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៥** | "ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣០ | ក្នុងករណីចាំបាច់ ប្រធានអាចហៅរកអ្នកបកប្រែ។" |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣១** | "កាលណាសំណួរត្រូវសួរដល់ជនគ និងថ្លង់ ក្រឡាបញ្ជីត្រូវសរសេរសំណួរ ហើយឱ្យសាមីខ្លួនអាន និងឆ្លើយជាលាយលក្ខណ៍អក្សរ។ ក្នុងករណីសាមីជនមិនចេះអាន ឬមិនចេះអក្សរ ប្រធានត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៣០ [...] ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជនគ និងថ្លង់នោះ មកបកប្រែ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៩៦ | "វិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូងក៏ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍។" |
| **ច្បាប់ស្តីពីយុត្តិធម៌ អនីតិជន មាត្រា ៦** | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖[...] សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី [...] សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់[...]" |
| ច្បាប់ស្តីពីយុត្តិធម៌ អនីតិជន មាត្រា ៥១ | "នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនយល់បានអំពីសិទ្ធិដូចខាងក្រោម៖ សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ [...]." |

ជនទាំងឡាយណាដែលត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌត្រូវតែទទួលបាននូវការជូនដំណឹង "ភ្លាមៗ" អំពីប្រភេទនៃបទល្មើស ដែលពួកគេត្រូវបានចោទប្រកាន់នោះ។ ចៅក្រមមានកាតព្វកិច្ចផ្តល់នូវការពន្យល់គ្រប់គ្រាន់ និងត្រូវប្រាកដថា ជនជាប់ចោទយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់លើពួកគេ។ ប្រសិនបើគ្មានព័ត៌មានដ៏សំខាន់ទាំងនេះទេ នេះមិនអាចរៀបចំឱ្យបានត្រឹមត្រូវដើម្បីការការពារក្តី ឬផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយដល់មេធាវី ក្នុងករណីដែលជនជាប់ចោទមានមេធាវីតំណាងស្របច្បាប់។ ដើម្បីអនុវត្តកាតព្វកិច្ចតាមមាត្រា ១៤ នៃ ក.អ.ស.ព.ន ព័ត៌មានពាក់ព័ន្ធនឹងការចោទប្រកាន់ត្រូវតែផ្តល់ជូនភ្លាមៗនៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ជាផ្លូវការពីបទល្មើសព្រហ្មទណ្ឌតាមច្បាប់ជាតិ ឬភ្លាមៗនៅពេលដែលជននោះត្រូវបានហៅជាសាធារណៈថាជាជនជាប់ចោទ។

ចំណុចនេះអាចធ្វើឡើងតាមរយៈការផ្តល់ព័ត៌មានផ្ទាល់មាត់ (តែនៅក្នុងករណីដែលក្រោយមកត្រូវបានបញ្ជាក់ជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ) ឬជាលាយលក្ខណ៍អក្សរ លុះត្រាព័ត៌មានបង្ហាញថាទាំងច្បាប់ និងអង្គហេតុទូទៅ ដែលត្រូវបានចោទប្រកាន់ ជាមូលដ្ឋាននៃការចោទប្រកាន់នោះ។[109]

គួរកត់សម្គាល់ថា អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យចាប់តាំងពីពេលចាប់ផ្តើមសវនាការមក នៅពេលដែលជនជាប់ចោទគួរបានដឹងអំពីបទចោទប្រកាន់មកលើខ្លួនរួចហើយ ដែលជាលទ្ធផលនៃការអនុវត្តនីតិវិធីឃាត់ខ្លួន/ឃុំខ្លួនបណ្តោះអាសន្ន។ ទោះជាយ៉ាណាក៏ដោយ ចៅក្រមក៏នៅតែត្រូវរំឭកដល់ជនជាប់ចោទអំពីព័ត៌មាននេះនៅមុនពេលសវនាការចាប់ផ្តើម ហើយត្រូវប្រាកដថាជនជាប់ចោទពិតជាយល់ព័ត៌មាននេះ។ នេះជាការងារដ៏មានសារសំខាន់ជាពិសេស ដោយសារតែពេលខ្លះ បទចោទអាចត្រូវបានផ្លាស់ប្តូរ ឬកែប្រែនៅចន្លោះពេលនៃការឃាត់ខ្លួនដំបូង/ការចោទប្រកាន់ និងពេលសវនាការជាក់ស្តែង។

*តួលេខទី ៨៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ -ទិដ្ឋភាពទូទៅ*[110]




នៅក្នុងសំណុំរឿងភាគច្រើន (១៥៩ នៃ ២០៣ ឬ ៧៨,៣%) ចៅក្រមបានប្រាប់ដល់ជនជាប់ចោទអំពីការចោទប្រកាន់ពាក់ព័ន្ធទាំងអស់ ដែលត្រូវបានចោទប្រកាន់លើពួកគេ។ ដោយហេតុថា ជាងមួយភាគប្រាំ (២១,៦%) នៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍នៅអំឡុងពេលធ្វើរបាយការណ៍ ជនជាប់ចោទមិនត្រូវបានប្រាប់អំពីបទចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់លើពួកគេ ឬមិនបានប្រាប់អំពីបទចោទប្រកាន់លើពួកគេទាំងអស់ឡើយ ដែលនេះគឺជាការព្រួយបារម្ភមួយផងដែរ។ ទោះបីជាភាគរយនៅទាបជាងនៅអំឡុងពេលធ្វើរបាយការណ៍កាលពីមុនក្តី នេះនៅតែបង្ហាញអំពីចំណែកនៃករណីដ៏សំខាន់។ ដូច្នេះ ម.ស.ម.ក បានចាត់ចំណាត់ថ្នាក់សិទ្ធិនេះថាមិនទាន់ត្រូវបានគោរពពេញលេញ។

[109] សេចក្តីពន្យល់ទូទៅលេខ ៣២។ សូមមើលផងដែរ៖ *Williams v. Jamaica* ដែលនៅក្នុងនោះគណៈកម្មាធិការបានបញ្ជាក់បន្ថែមថាព័ត៌មានលម្អិតអំពីការចោទប្រកាន់ត្រូវតែផ្តល់ជូននៅ "ដំណាក់កាលដំបូងនៃការស៊ើបអង្កេតបឋម ឬការបើកសវនាការមួយចំនួនផ្សេងទៀតដើម្បីគាំទ្រការសង្ស័យផ្លូវការកាន់តែច្បាស់ទៅលើជនជាប់ចោទ។"

[110] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍។

*តួលេខទី ៩៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - លម្អិត*[111]




តួលេខខាងលើនេះបង្ហាញថា ក្នុងសំណុំរឿងភាគច្រើន ចៅក្រមនៅសាលាឧទ្ធរណ៍បានប្រាប់ឡើងវិញអំពីបទចោទប្រកាន់ អង្គហេតុ កាលបរិច្ឆេទ និងព័ត៌មានទាក់ទងនឹងបទចោទ។ ហេតុនេះ សិទ្ធិយល់ដឹងអំពីប្រភេទនៃការចោទប្រកាន់នៅក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍ជាញឹកញាប់ត្រូវបានគោរព។ ប៉ុន្តែ នៅពេលប្រៀបធៀបជាមួយនឹងរបកគំហើញពីការសង្កេតការណ៍សវនាការអំឡុងពេលធ្វើរបាយការណ៍កាលពីឆ្នាំ២០១៧/២០១៨ និងឆ្នាំ២០១៨/២០១៩ ការគោរពសិទ្ធិនេះមានការល្អប្រសើរឡើងតែបន្តិចបន្តួចប៉ុណ្ណោះដូចមានបញ្ជាក់នៅក្នុងតារាងខាងក្រោមនេះ។

*តួលេខទី ១០៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ - ការវិវឌ្ឍ*[112]

| | ២០១៧/ ២០១៨ | ២០១៨/ ២០១៩ | ២០១៩/ ២០២០ |
|---|---|---|---|
| ភាគរយនៃសំណុំរឿងដែលចៅក្រមបានប្រាប់អំពីការចោទប្រកាន់ទាំងអស់ | ៦៩% | ៦៧,៤% | ៧៨,៣% |
| ភាគរយនៃសំណុំរឿងដែលចៅក្រមបានប្រាប់អំពីច្បាប់ដែលពាក់ពាក់ព័ន្ធ | ៦៣% | ៦៨,២% | ៥៩,៦% |
| ភាគរយនៃសំណុំរឿងដែលចៅក្រមបានលើកឡើងអំពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស | ៩៤,៨% | ៩០,៨% | ៩៥,១% |
| ភាគរយនៃសំណុំរឿងដែលចៅក្រមបានប្រាប់ពីទីកន្លែងប្រព្រឹត្តបទល្មើស | ៧៨,៤% | ៨៥,៤% | ៨៣,៧% |

[111] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍។

[112] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៧/២០១៨ សំណុំរឿងដែលបានសង្កេតការណ៍ចំនួន ២៣៩ ដែលបានសង្កេតការណ៍នៅក្នុងឆ្នាំ ២០១៨/២០១៩ និងសំណុំរឿងចំនួន ២០៣ បានសង្កេតការណ៍នៅក្នុងឆ្នាំ ២០១៩/២០២០។

| | | | |
|---|---|---|---|
| ភាគរយនៃសំណុំរឿងដែលចៅក្រមបានរៀបរាប់ឈ្មោះអ្នកចូលរួម | ៩២,៥% | ៩១,២% | ៩០,៦% |

នៅអំឡុងពេលធ្វើរបាយការណ៍នេះ ព័ត៌មានដែលចៅក្រមមិនបានប្រាប់ ភាគច្រើនគឺទាក់ទងនឹងមាត្រាច្បាប់ដែលពាក់ព័ន្ធ និងទីកន្លែងប្រព្រឹត្តបទល្មើស។ ក្នុងករណីដែលចៅក្រមមិនបានប្រាប់អំពីព័ត៌មានពាក់ព័ន្ធនឹងច្បាប់និងទីកន្លែងនៃបទល្មើសបានធ្លាក់ចុះនៅពេលប្រៀបធៀបទៅនឹងរយៈពេលធ្វើរបាយការណ៍ចំនួនពីរចុងក្រោយ។ ព័ត៌មានទាំងនេះគឺជាព័ត៌មានលម្អិតសំខាន់ ដែលត្រូវប្រាប់ដល់ជនជាប់ចោទនៅពេលសវនាការព្រហ្មទណ្ឌ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី សាលាឧទ្ធរណ៍បានលើកឡើងថា ផ្អែកតាមនីតិវិធី ចៅក្រមបានអានរបាយការណ៍ព្រហ្មទណ្ឌ ដែលបង្ហាញពីអត្តសញ្ញាណរបស់គូភាគី បទចោទប្រកាន់ អង្គហេតុ ភស្តុតាង និងសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង ព្រមទាំងទម្រង់នៃបណ្តឹងឧទ្ធរណ៍ ដែលជាផ្នែកមួយនៃនីតិវិធីត្រូវប្រតិបត្តិដោយហ្មត់ចត់របស់អង្គជំនុំជម្រះ។[113]

## ៤.៤ សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤(៣)(ឃ) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។" |
| រដ្ឋធម្មនុញ្ញ មាត្រា ៣៨ | "ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៣ | "នៅពេលដែលជនត្រូវចោទដែលជាអនីតិជន ចូលបង្ហាញខ្លួនជាលើកដំបូង ជននេះត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ តុលាការត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣០០ | "ជនជាប់ចោទត្រូវចូលបង្ហាញខ្លួន នៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទ ត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនបានដែរនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។" |

[113] លិខិតឆ្លើយតបរបស់សាលាឧទ្ធរណ៍ភ្នំពេញ លេខ ៤៣១ របឧ/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ លើសេចក្តីព្រាងរបាយការណ៍របស់ ម.ស.ម.ក ឆ្នាំ២០១៩/២០២០។

| | |
|---|---|
| **ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣០១** | "ជំនួយពីមេធាវីត្រូវតែមានជាចាំបាច់ខាតនៅក្នុងករណីដូចតទៅ៖ ១. ករណីបទឧក្រិដ្ឋ ២. កាលណា ជនជាប់ចោទជាអនីតិជន។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៨៩ | "ជនជាប់ចោទដែលជាប់ឃុំ ត្រូវតែផ្ទេរនៅក្នុងរយៈពេលយ៉ាងខ្លីបំផុតតាមបញ្ជារបស់អគ្គព្រះរាជអាជ្ញាឱ្យទៅនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍។" |
| **ច្បាប់ស្ដីពីពន្ធនាគារ មាត្រា ៦២** | "ក្រៅពីទណ្ឌិត ការផ្ទេរជនជាប់ឃុំពីពន្ធនាគារមួយទៅពន្ធនាគារមួយ ក៏ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្ដី។"(ការបកប្រែរបស់ម.ស.ម.ក) |
| ច្បាប់ស្ដីពីយុត្តិធម៌ អនីតិជន មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថា បានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [...] សិទ្ធិទទួលបានជំនួយពីមេធាវី [...]" |
| **ច្បាប់ស្ដីពីយុត្តិធម៌ អនីតិជន មាត្រា ៥០** | "ជំនួយរបស់មេធាវី ត្រូវតែមានជាចាំបាច់ខាតនៅក្នុងសវនាការ [...]" |
| ច្បាប់ស្ដីពីយុត្តិធម៌ អនីតិជន មាត្រា ៥១ | "នៅពេលចាប់ផ្ដើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោម៖<br>• សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ<br>• សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្ដី<br>• សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ<br>• សិទ្ធិប្ដឹងជំទាស់ចំពោះសាលក្រមកំបាំងមុខ ...<br>• សិទ្ធិធ្វើសំណូមពរចុងក្រោយ និង<br>• សិទ្ធិប្ដឹងឧទ្ធរណ៍។" |

ការដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយអាចជាបទពិសោធន៍គួរឱ្យខ្លាច ហើយនីតិវិធីច្បាប់អាចមានភាពស្មុគស្មាញ និងច្របូកច្របល់។ ហេតុដូច្នេះ ជាការសំខាន់ណាស់ដែលបុគ្គលគ្រប់រូបមានឱកាសទទួលបានមេធាវី។ បន្ថែមលើនេះទៀត ប្រសិនជនជាប់ចោទដែលពុំមានលទ្ធភាពអាចជួលមេធាវីដោយខ្លួនឯងបានទេ អាជ្ញាធរដែលពាក់ព័ន្ធគួរផ្ដល់មេធាវីដោយឥតគិតថ្លៃក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ។[114] ស្ថានទម្ងន់នៃបទល្មើស និងការមានឱកាសទទួលបានភាពមិនលម្អៀងមួយចំនួន ដើម្បីឈ្នះបណ្ដឹងនៅសាលាឧទ្ធរណ៍គឺជាកត្តាដែលត្រូវតែ

[114] ក.អ.ស.ព.ន, មាត្រា ១៤(៣)(ឃ); គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៨។

យកមកពិចារណាក្នុងការវាយតម្លៃថាតើគួរតែផ្តល់មេធាវីដោយឥតគិតថ្លៃដើម្បីផលប្រយោជន៍យុត្តិធម៌ឬយ៉ាងណា។[115] សិទ្ធិមានមេធាវីនេះធានាថា ជនជាប់ចោទមានឱកាសក្នុងការទទួលបានការណែនាំផ្នែកវិជ្ជាជីវៈពីអ្នកជំនាញផ្នែកតស៊ូមតិ ដែលមានលទ្ធភាពពន្យល់នូវបទចោទប្រកាន់ប្រឆាំង ពន្យល់ពីសិទ្ធិ ណែនាំពីដំណើរការជំនុំជម្រះ និងការពារផលប្រយោជន៍ដល់ពួកគេនៅក្នុងតុលាការ។ នៅក្នុងប្រទេសកម្ពុជា ជាលក្ខខណ្ឌតម្រូវដោយច្បាប់សម្រាប់បុគ្គលដែលត្រូវទទួលបានមេធាវី ប្រសិនបើពួកគេត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬជននោះជាអនីតិជន។ ថ្វីបើពុំមានការតម្រូវដោយច្បាប់ចំពោះការទទួលបានមេធាវី ប្រសិនជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម (លើកលែងតែជាអនីតិជន) ជននោះក៏នៅតែមានជម្រើស ប្រសិនបើខ្លួនប្រាថ្នាចង់បានមេធាវីការពារ។ នៅក្នុងករណីបែបនេះ បន្ទុកក្នុងការផ្តល់មេធាវីពុំមែនជាបន្ទុករបស់តុលាការឡើយ។

បន្ថែមពីលើនេះទៀត សវនាការចាំបាច់ត្រូវធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ[116] ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទអាចបានឮ និងឆ្លើយតបចំពោះសំណុំរឿងដែលបានប្តឹងប្រឆាំងរូបខ្លួន ព្រមទាំងបង្ហាញការការពារខ្លួន។ ទាក់ទងនឹងអនីតិជន សវនាការគួរធ្វើឡើងដោយមាន "ជំនួយផ្នែកច្បាប់ ឬជំនួយសមស្របដទៃទៀត" ព្រមទាំងឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់កុមារ លើកលែងតែរកឃើញថា ការធ្វើបែបនេះពុំមែនជាឧត្តមប្រយោជន៍របស់កុមារ។[117]

សិទ្ធិមានវត្តមានផ្ទាល់គឺអនុវត្តចំពោះនីតិវិធីបណ្តឹងឧទ្ធរណ៍ ប្រសិនបើនីតិវិធីទាំងនេះពាក់ព័ន្ធសំណួរផ្នែកអង្គហេតុផងនិងអង្គច្បាប់ផង[118] ដែលករណីនេះកើតមាននៅក្នុងប្រទេសកម្ពុជា។ ថ្វីបើសវនាការ *កំបាំងមុខ* អាចត្រូវបានអនុញ្ញាតឱ្យមានតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិក្តី សវនាការកំបាំងមុខអាចត្រូវបានអនុញ្ញាតឱ្យធ្វើឡើងបានតែក្នុងស្ថានភាពពិសេស និងនៅពេលធ្វើបែបនេះផ្តល់ផលប្រយោជន៍ដល់ការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវប៉ុណ្ណោះ។[119] ចាំបាច់ត្រូវមានការផ្តល់ហេតុផលសមស្របដើម្បីអាចធ្វើសវនាការកំបាំងមុខបាន។[120]

បន្ថែមលើនេះទៀត ចាំបាច់ត្រូវមានការបញ្ជាក់ច្បាស់ពីជនជាប់ចោទថា ខ្លួនបោះបង់សិទ្ធិមានវត្តមាននៅពេលសវនាការរបស់ពួកគេ។[121]

ជាការឆ្លើយតបបលើបញ្ហានេះ សាលាឧទ្ធរណ៍បានអះអាងថា តុលាការមិនធានាជាប់វងក្នុងការផ្តល់មេធាវីដល់ជនជាប់ចោទនៃគ្រប់បទល្មើសនោះទេ តុលាការជានាប់វងចំពោះតែជនជាប់ចោទដែលប្រព្រឹត្តបទឧក្រិដ្ឋ និងបទល្មើសដែលប្រព្រឹត្តដោយអនីតិជន ប្រសិនបើពួកគេមិនមានមេធាវីទេ សាលាឧទ្ធរណ៍នឹងស្វះស្វែងរកមេធាវីជូន។ ចំពោះបទមជ្ឈិមវិញ គឺអាស្រ័យទៅលើជនជាប់ចោទដែលត្រូវពឹងពាក់មេធាវី ឬមិនពឹងពាក់មេធាវី ហេតុនេះ សាលា

---

[115] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៨។

[116] ក.អ.ស.ព.ន, មាត្រា ១៤(៣)(ឃ); គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៦។

[117] អ.ស.ក, មាត្រា ៤០(២)(ខ)(iii); សូមមើល គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៤២។

[118] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, Karttunen v. Finland, Communication ៣៨៧/១៩៨៩, UN Doc CCPR/C/៤៦/D/៣៨៧/១៩៨៩ (១៩៩២) វាក្យខណ្ឌ ៧.៣ <http://juris.ohchr.org/Search/Details/402>។

[119] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៦។

[120] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, Mbenge v. Zaire, Communication ០១៦/១៩៧៧, UN Doc CCPR/C/១៨/D/១៦/១៩៧៧ (១៩៨៣) វាក្យខណ្ឌ ១៤.១ <http://juris.ohchr.org/Search/Details/573>។

[121] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣៦។

ឧទ្ធរណ៍អាចដំណើរការជំនុំជម្រះបានដោយមិនមានមេធាវីការពារបានសម្រាប់តែបទមជ្ឈិម តែចៅក្រមសាលាឧទ្ធរណ៍ក៏បានប្រាប់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីផងដែរ។[122]

ពាក់ព័ន្ធនឹងសិទ្ធិមានវត្តមាននៅពេលសវនាការវិញ សាលាឧទ្ធរណ៍បានអះអាងថា ក្នុងករណីជនជាប់ចោទអវត្តមាន តែមានមេធាវីការពារ ឬក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងខុសទម្រង់ច្បាប់ ឬមានបណ្ដឹងឧទ្ធរណ៍របស់តំណាងអយ្យការ ឬប្រសិនបើរឿងក្ដីនោះអូសបន្លាយពេលវេលាយូរ និងមានសំណូមពរពីភាគី ឬតំណាងអយ្យការ តុលាការអាចដំណើរការសវនាការតាមនីតិវិធីច្បាប់បាន។[123]

*តួលេខទី ១១៖ សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ[124]*




នៅចន្លោះឆ្នាំ២០១៨/២០១៩ និងឆ្នាំ២០១៩/២០២០ ភាគរយនៃជនជាប់ចោទដែលមានវត្តមាននៅពេលសវនាការមានចំនួនកើតឡើងយ៉ាងល្អចាប់ពី ៨០,៧% ដល់ ៩០,២%។ ទោះជាយ៉ាងនេះក្ដី ចំនួនជនជាប់ចោទដែលមានមេធាវីតំណាងបានធ្លាក់ចុះពី ៧៤,៤% ដល់ ៧១,៧%។ តួលេខនេះនៅតែជាក្ដីបារម្ភ ដែលជាងមួយភាគបីនៃជនជាប់ចោទមិនមានមេធាវីតំណាង។

បើគិតទៅលើលក្ខណៈសម្បត្តិជាមូលដ្ឋាននៃសិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី ហេតុដែលជនជាប់ចោទចំនួន ២៨,២% ពុំមានមេធាវីតំណាង និងជនជាប់ចោទចំនួន ៩,៨% មិនមានវត្តមាននៅពេលសវនាការ នៅតែជាតួលេខខ្ពស់គួរឱ្យព្រួយបារម្ភខ្លាំងនៅឡើយ។ នៅខែមេសា ឆ្នាំ២០១៨ អនុប្រធានសាលាឧទ្ធរណ៍[125]បានគូសបញ្ជាក់ថាសំណុំរឿងភាគច្រើនដែលជនជាប់ចោទអវត្តមានពេលសវនាការ ដោយសារតែបញ្ហាកង្វះខាតនៃការដឹកជញ្ជូនជន

---

[122] លិខិតឆ្លើយតបរបស់សាលាឧទ្ធរណ៍ភ្នំពេញ លេខ ៤៣១ របឧ/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ លើសេចក្ដីព្រាងរបាយការណ៍របស់ ម.ស.ម.ក ឆ្នាំ២០១៩/២០២០។

[123] លិខិតឆ្លើយតបរបស់សាលាឧទ្ធរណ៍ភ្នំពេញ លេខ ៤៣១ របឧ/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ លើសេចក្ដីព្រាងរបាយការណ៍របស់ ម.ស.ម.ក ឆ្នាំ២០១៩/២០២០។

[124] ទិន្នន័យនេះផ្អែកលើចំនួនសរុបនៃជនជាប់ចោទ (២៥៥ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍។

[125] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្ដម ប្លង់ សំណាង ឯកឧត្ដម ញ៉ង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៦/២០១៧។

ជាប់ចោទពីមណ្ឌលឃុំឃាំងមកតុលាការ ដែលនេះជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារ។ នៅខែសីហា ឆ្នាំ២០១៩ សាលាឧទ្ធរណ៍បានលើកឡើងថា ទោះបីជាការមានមេធាវីជាទូទៅតែងតែតម្រូវឱ្យមានសម្រាប់សវនាការសំណុំរឿងឧក្រិដ្ឋ និងអនីតិជន ខណៈដែរសំណុំរឿងមជ្ឈិម ជនជាប់ចោទមិនតម្រូវឱ្យមានមេធាវីឡើយ ប្រសិនបើជនជាប់ចោទមិនមែនជាអនីតិជន[126]។

លើសពីនេះទៅទៀត មេធាវីតំណាងឱ្យជនជាប់ចោទច្រើនជាងម្នាក់នៅក្នុងសំណុំរឿងចំនួន ៥៨ នៅអំឡុងពេលធ្វើបោយការណ៍។ ស្ថានភាពដែលមេធាវីតំណាងឱ្យជនជាប់ចោទច្រើនជាងម្នាក់ ដែលពេលខ្លះមានប្រសិទ្ធភាពថ្លៃចំណាយនោះ បានធ្វើឱ្យមានការព្រួយបារម្ភកើនឡើងចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗ ឧទាហរណ៍ នៅពេលដែលការការពារក្តី ឬការបង្វែរហេតុការណ៍របស់ជនជាប់ចោទម្នាក់ក្នុងចំណោមសហជនជាប់ចោទមានភាពខុសគ្នា ឬមានភាពផ្ទុយគ្នាទៅនឹងស្ថានភាពរបស់សហជនជាប់ចោទផ្សេងទៀត។ ប្រសិនបើមេធាវីតែម្នាក់តំណាងឱ្យជនជាប់ចោទទាំងពីរនឹងធ្វើឱ្យការការពារក្តីរបស់ជនជាប់ចោទម្នាក់មានផលប៉ះពាល់អវិជ្ជមានទៅលើជនជាប់ចោទម្នាក់ទៀតជាក់ជាមិនខាន ហើយជនជាប់ចោទម្នាក់នោះនឹងមិនអាចទទួលបានការការពារក្តីដោយប្រសិទ្ធភាព ហើយការតំណាងគ្រប់គ្រាន់ដោយមេធាវីជនជាប់ចោទឡើយ។ ក្នុងករណីបែបនេះ គឺមានទំនាស់ផលប្រយោជន៍។ ជនជាប់ចោទម្នាក់ៗ គួរតែមានមេធាវីដាច់ដោយឡែកពីគ្នា[127]។ គួរកត់សម្គាល់ផងដែរថា នៅអំឡុងពេលធ្វើរបាយការណ៍ អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក មិនបានកំណត់អំពីទំនាស់ផលប្រយោជន៍នៅក្នុងសំណុំរឿងដែលមេធាវីតំណាងឱ្យជនជាប់ចោទច្រើននាក់ទេ។

[126] នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ម.ស.ម.ក បានជួបប្រជុំជាមួយនឹងប្រធាន អនុប្រធានទាំងអស់ មហាអយ្យការ អ្នកតំណាងចៅក្រមម្នាក់ និងអគ្គលេខាធិការរដ្ឋបាលនៃសាលាឧទ្ធរណ៍ដើម្បីពិភាក្សាអំពីលទ្ធផលរកឃើញនៃរបាយការណ៍នេះ។

[127] សូមមើលឯកសារណែនាំសម្រាប់តារាងសង្កេតការណ៍ប្រើដើម្បីកត់ត្រាទិន្នន័យសវនាការនៅពេលសង្កេតការណ៍របស់ ម.ស.ម.ក ទំព័រ ៤៧ < https://sithi.org/km/tmp/publication/view/2014-01-29-guidance-notes-for-cchr-appeal-court-monitoring-checklist>។

### *តួលេខទី ១២៖ ការពន្យល់ប្រាប់សិទ្ធិ*[128]




ដោយហេតុថា ៧១,៨% នៃសំណុំរឿងទាំងអស់ចំនួន ២០៣ ដែល ម.ស.ម.ក បានសង្កេតការណ៍ ជនជាប់ចោទមានមេធាវីតំណាង បង្ហាញថាសិទ្ធិរបស់បុគ្គលក្នុងការទទួលបានមេធាវីភាគច្រើនត្រូវបានការពារ ដោយនៅតែមានលំនឹងចាប់តាំងពីឆ្នាំ២០១៧/២០១៨ មក។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមសំណុំរឿងចំនួន ១៥ នៃសំណុំរឿងទាំងអស់ចំនួន ៧,៤% ចៅក្រមមិនបានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទឡើយ។ តួលេខនេះត្រូវបានចាត់ទុកថាមានលក្ខណៈល្អប្រសើរបន្តិច បើធៀបជាមួយនឹងឆ្នាំ២០១៨/២០១៩ ដែលភាគរយពេលនោះគឺ ៨,៤%។ ទោះជាយ៉ាងនេះក្តី សិទ្ធិនេះនៅមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ។

ក្នុងករណីជនជាប់ចោទពុំមានវត្តមាននៅពេលសវនាការជាញឹកញាប់ អវត្តមាននេះដោយសារបញ្ហាភ័ស្តុភារ ក៏ដូចជាបញ្ហាផ្នែកការប្រាស្រ័យទាក់ទងរវាងចៅក្រមជាមួយមណ្ឌលកែប្រែ ឬកន្លែងឃុំឃាំង។ នៅពេលចាប់ផ្តើមធ្វើរបាយការណ៍នេះ សាលាឧទ្ធរណ៍មានតែមួយប៉ុណ្ណោះសម្រាប់ប្រទេសទាំងមូល ដែលតម្រូវឱ្យជនជាប់ចោទដែលជាប់ឃុំនៅក្នុងមណ្ឌលកែប្រែតាមខេត្តត្រូវធ្វើដំណើរមកកាន់សាលាឧទ្ធរណ៍នៅភ្នំពេញនៅថ្ងៃសវនាការ។ ប៉ុន្តែមានករណីជាច្រើនដែលការដឹកជញ្ជូនជនជាប់ចោទពុំអាចធ្វើឡើងបាន ដោយសារតែសាលាឧទ្ធរណ៍បញ្ជូនព័ត៌មានទៅខុសមណ្ឌលកែប្រែ ឬដោយសារតែមណ្ឌលកែប្រែពុំបានផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីការផ្ទេរជនជាប់ឃុំពីមណ្ឌលកែប្រែមួយទៅមណ្ឌលកែប្រែមួយទៀត។ បញ្ហាភ័ស្តុភារទាំងអស់នេះនឹងត្រូវរំពឹងថាបានដោះស្រាយបានតាមរយៈការបង្កើតសាលាឧទ្ធរណ៍តំបន់ចំនួនបីបន្ថែមទៀត ដែលសាលាឧទ្ធរណ៍ទាំងនេះនឹងត្រូវដំណើរការនៅក្នុងឆ្នាំ២០២០។ ប៉ុន្តែ បញ្ហាទាំងនេះចាំបាច់ត្រូវដោះស្រាយតាមរយៈការកែលម្អកំណត់ត្រា និងការប្រាស្រ័យទាក់ទងរវាងសាលាឧទ្ធរណ៍ជាមួយមណ្ឌលកែប្រែផងដែរ។

ពាក់ព័ន្ធនឹងសិទ្ធិមានមេធាវី សាលាឧទ្ធរណ៍បានបញ្ជាក់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់របាយការណ៍ឆ្នាំ២០១៨/២០១៩ ថាការមានមេធាវីតំណាងគឺជាការតម្រូវចាំបាច់សម្រាប់សំណុំរឿងបទឧក្រិដ្ឋ និងអនីតិជន។ សម្រាប់សំណុំរឿងបទមជ្ឈិម រដ្ឋមិនជានាផ្តល់ជំនួយផ្នែកច្បាប់ឡើយ ប៉ុន្តែជនជាប់ចោទមិនត្រូវបានហាមឃាត់ក្នុងការ

[128] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍។ "មិនពាក់ព័ន្ធ" គឺជនជាប់ចោទអវត្តមាន។

ជួលមេធាវីផ្ទាល់ខ្លួននោះទេ។ សាលាឧទ្ធរណ៍បានលើកឡើងថា ពួកគេបានព្យាយាមស្វែងរកជំនួយផ្នែកច្បាប់សម្រាប់ជនជាប់ចោទដែរ។ មានបន្ទប់ចំនួនពីរសម្រាប់ការពិគ្រោះយោបល់ផ្នែកច្បាប់រវាងមេធាវី និងកូនក្ដីនៅសាលាឧទ្ធរណ៍ និងបន្ទប់រង់ចាំសម្រាប់ជនជាប់ចោទ ហើយមេធាវីអាចថតចម្លងឯកសារសំណុំរឿងដោយឥតគិតថ្លៃចំពោះសំណុំរឿងនៃជនជាប់ចោទក្រីក្រ។ លើសពីនេះទៅទៀត សាលាឧទ្ធរណ៍បានលើកឡើងថា ការដាក់ពាក្យស្នើសុំមេធាវីសម្រាប់ជនក្រីក្រគឺមានការលំបាក ដោយសារតែមានការតម្រូវឱ្យផ្ដល់លិខិតបញ្ជាក់អំពីស្ថានភាពក្រីក្រដល់គណៈមេធាវី។ ជាងនេះទៅទៀត គណៈមេធាវីមានបញ្ហាប្រឈមផ្នែកថវិកាផងដែរ ដែលមានន័យថា នេះគឺជាបញ្ហាដែលនាំឱ្យមានការយឺតយ៉ាវក្នុងការឆ្លើយតបទៅនឹងពាក្យស្នើសុំ និងការផ្ដល់មេធាវី។ សាលាឧទ្ធរណ៍បានបញ្ជាក់ថា ចៅក្រមបានសួរជនជាប់ចោទក្នុងបទមជ្ឈិមអំពីជំនួយផ្នែកច្បាប់ ប្រសិនបើពួកគេមិនមានមេធាវីតំណាង ប៉ុន្តែជនជាប់ចោទមួយចំនួនយល់ព្រមឱ្យបន្តដំណើរការសវនាការដោយមិនមានជំនួយផ្នែកច្បាប់។[129]

## ៤.៥ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(២) | "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៣៨ | "ជនជាប់ចោទណាក៏ដោយ ត្រូវទុកថាជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។" |
| ច្បាប់ស្ដីពីយុត្តិធម៌<br>អនីតិជន<br>មាត្រា ៥ | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ [...] សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។" |

ការសន្មតទុកជាមុនថាគ្មានទោសគឺជាសិទ្ធិមូលដ្ឋាន និងជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានទទួលស្គាល់ជាសាកល ហើយសិទ្ធិនេះអនុវត្តនៅពេញរយៈពេលនៃនីតិវិធីនៃការស៊ើបអង្កេត និងការជំនុំជម្រះផ្នែកព្រហ្មទណ្ឌ រហូតដល់ការបញ្ចប់បណ្ដឹងជំទាស់ចុងក្រោយ។[130] មានន័យថាបុគ្គលម្នាក់ត្រូវបានសន្មតទុកជាមុនថាគ្មានទោស រហូតទាល់តែពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់ និងតាមរយៈសេចក្ដីសម្រេចស្ថាពរ។ គោលការណ៍ដែលថាបន្ទុកនៃភស្តុតាងស្ថិតនៅលើស្ថាប័នអយ្យការ មិនមែនជាបន្ទុករបស់ជនជាប់ចោទទេ គឺមានប្រភពចេញមកពីការសន្មតទុកជាមុនថាគ្មានទោស។[131]

---

[129] ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយប្រធាន និងអនុប្រធានសាលាឧទ្ធរណ៍ ព្រមទាំងអគ្គព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ និងអគ្គលេខាធិការ និងអគ្គលេខាធិការរងសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើបេកគំហើញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៨/២០១៩។

[130] ការិយាល័យឧត្តមស្នងការ "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី I), ជំពូក ៦",ទំព័រ ២១៩ <https://www.ohchr.org/Documents/Publications/training9chapter6en.pdf>; Amnesty International "សៀវភៅណែនាំអំពីសវនាការយុត្តិធម៌", ទំព័រ ១២៥, ផ្នែក ១៥.២. < https://www.amnesty.org/download/Documents/8000/pol300022014en.pdf>។

[131] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣០។

បើទោះបីជាជនជាប់ចោទមិននិយាយអ្វីទាំងអស់ និងមិនបង្ហាញភស្តុតាងអ្វីទាល់តែសោះក៏ដោយ ជនជាប់ចោទត្រូវបានឱ្យរួចផុតពីបទចោទ ប្រសិនបើអយ្យការមិនអាចបង្ហាញភស្តុតាងដាក់បន្ទុកដែលឈានដល់ការកាត់ឱ្យជាប់ទោស ឬអាចនិយាយម្យ៉ាងទៀតថា ជនជាប់ចោទពុំមានកាតព្វកិច្ចត្រូវបង្ហាញភស្តុតាងដើម្បីបង្ហាញថាខ្លួនជាជនគ្មានទោសនោះឡើយ។

កាន់តែជាក់លាក់ទៀត ការសន្និតទុកជាមុនថាគ្មានទោសតម្រូវឱ្យ៖

i. តុលាការ ឬសាលាក្តីមិនត្រូវធ្វើបុរេវិនិច្ឆ័យចំពោះសំណុំរឿងដែលនាំមកចំពោះមុខខ្លួនឡើយ។

ii. ពិរុទ្ធភាពហួសពីវិមតិសង្ស័យចាំបាច់ត្រូវបង្ហាញភស្តុតាងដោយអយ្យការ។

iii. ការប្រព្រឹត្តចំពោះជនជាប់ចោទ មិនគួរធ្វើឡើងក្នុងលក្ខណៈដែលបង្ហាញថា ជនជាប់ចោទមានពិរុទ្ធភាពនោះឡើយ។

iv. ប្រព័ន្ធផ្សព្វផ្សាយគួរចៀសវាងការផ្សព្វផ្សាយព័ត៌មានទាំងឡាយណាដែលបំផ្លាញដល់ការសន្និតទុកជាមុនថាគ្មានទោស និង

v. អាជ្ញាធរសាធារណៈគួរចៀសវាងការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈណាដែលអាចប៉ះពាល់ដល់ការសន្និតទុកជាមុននេះដែរ[132]។

## *តួលេខទី ១៣៖ សិទ្ធិនៅស្ងៀម*[133]




សិទ្ធិនៅស្ងៀមចាក់ឫសគល់នៅក្នុងសិទ្ធិទទួលបានការសន្និតទុកជាមុនថាគ្មានទោស។ នៅក្នុងសំណុំរឿងចំនួន ២៥,៦% ចៅក្រមមិនបានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទនោះទេ។ នេះបង្ហាញអំពីការកែលម្អគួរឱ្យកត់សម្គាល់ចាប់ពីអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៨/២០១៩ នៅអំឡុងពេលដែលចៅក្រមមិនបានប្រាប់ និងពន្យល់អំពីសិទ្ធិនេះនៅក្នុងសំណុំរឿងចំនួន ៦៦%។ នៅពេលដែលការកែលម្អមានភាពគួរឱ្យកត់សម្គាល់ និងគួរឱ្យស្វាគមន៍ ចំពោះការអនុវត្តរបស់ចៅមក្រោមដែលបានប្រាប់ និងពន្យល់អំពីសិទ្ធិទទួលបាន

---

[132] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៣០; *Barberá, Messegué and Jabardo v. Spain* (ECtHR, ១៩៨៨) វាក្យខណ្ឌ ៧៧ <http://hudoc.echr.coe.int/eng?i=001-57429>។

[133] ទិន្នន័យនោះរួមមានសំណុំរឿងចំនួន ១៨៥ ដែលបានសង្កេតការណ៍ (ក្នុងចំណោមសំណុំរឿងចំនួន ២០៣) ដែលជនជាប់ចោទមានវត្តមាននៅពេលសវនាការ។

ការសន្មតទុកជាមុនថាគ្មានទោសដល់ជនជាប់ចោទទាំងអស់ ដែលសិទ្ធិនេះចាំបាច់ត្រូវតែអនុវត្តជាបន្ទាន់ ដោយហេតុថា សិទ្ធិនេះជាសិទ្ធិស្នូលមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ទោះជាយ៉ាងនេះក្តី សាលាឧទ្ធរណ៍បានលើកឡើងថា គោលការណ៍នេះជាគោលការណ៍ចម្បង ដែលមានចែងក្នុងបទដ្ឋានអន្តរជាតិ និងមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលតុលាការត្រូវគោរពដោយហ្មត់ចត់ ប៉ុន្តែមិនមែនជាសិទ្ធិរបស់ជនជាប់ចោទដែលតម្រូវឱ្យតុលាការត្រូវប្រាប់នោះទេ តែជនជាប់ចោទមានសិទ្ធិនៅស្ងៀមប្រសិនបើខ្លួនមិនចង់និយាយ។[134]

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស រាប់បញ្ចូលទាំងកាតព្វកិច្ចរបស់អាជ្ញាធរក្នុងការធានាថាគ្មានការសន្មតទោសទុកជាមុនលើជនជាប់ចោទនៅអំឡុងពេលជំនុំជម្រះ ដែលអាចប៉ះពាល់ដល់ការសន្មតទុកជាមុនថាគ្មានទោស។[135] នៅពេលដែលជនជាប់ចោទចូលរួមក្នុងសវនាការក្នុងឯកសណ្ឋានជាអ្នកទោស[136] ការសន្មតទុកជាមុនថាគ្មានទោសត្រូវបានប៉ះពាល់។ករណីនេះ ជាពិសេសនៅពេលដែលពុំមានការបង្ហាញឱ្យឃើញពីភាពខុសគ្នារវាងអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការនិងទណ្ឌិត។ នៅពេលដែលអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោសនោះ ការបង្ហាញខ្លួននេះគឺដូចគ្នាទៅនឹងទណ្ឌិតដែលត្រូវបានកាត់ទោសជាស្ថាពរហើយ។ ដោយសារតែពុំមានការបញ្ជាក់ពីភាពខុសគ្នារវាងអ្នកជាប់ឃុំទាំងពីរប្រភេទ ការអនុវត្តបែបនេះធ្វើឱ្យមានការសន្មតយ៉ាងជាក់ស្តែងថាជនជាប់ចោទគឺពិតជាជនល្មើសដែលត្រូវបានផ្តន្ទាទោសរួចហើយ ហេតុដូច្នេះ អាចជះឥទ្ធិពលដល់សេចក្តីសម្រេចរបស់ចៅក្រម ក៏ដូចជាការយល់ឃើញរបស់សាធារណជនផងដែរ។ សូម្បីតែនៅពេលជនជាប់ចោទកំពុងតែអនុវត្តទោសក៏ដោយ ការណ៍ដែលថាជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោស ក៏ធ្វើឱ្យមានការប៉ះពាល់ដល់គោលការណ៍យុត្តិធម៌ដូចគ្នាដែរ។ បញ្ហាដែលជនជាប់ចោទបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោសនេះគឺជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារ។

ការប្រតិបត្តិល្អជាលក្ខណៈអន្តរជាតិនៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌចង្អុលឱ្យឃើញថា ជនជាប់ចោទគួរតែអាចស្លៀកសម្លៀកបំពាក់របស់ខ្លួនពេលបង្ហាញខ្លួននៅក្នុងតុលាការ។ វិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមា

---

[134] លិខិតឆ្លើយតបរបស់សាលាឧទ្ធរណ៍ភ្នំពេញ លេខ ៤៣១ របឧ/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ លើសេចក្តីព្រាងរបាយការណ៍របស់ ម.ស.ម.ក ឆ្នាំ២០១៩/២០២០។

[135] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣០ ["*ជាធម្មតា ជនជាប់ចោទមិនគួរត្រូវបានដាក់ខ្នោះ ឬដាក់ក្នុងទ្រុងក្នុងអំឡុងពេលជំនុំជម្រះនោះទេ បើមិនដូច្នោះទេ ការបង្ហាញខ្លួនក្នុងតុលាការក្នុងលក្ខណៈបែបនេះអាចបង្ហាញថាជនជាប់ចោទគឺជាឧក្រិដ្ឋជនដ៏គ្រោះថ្នាក់*"]; សូមមើល ECtHR, *Samoila and Cionca v. Romania*, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៨, វាក្យខណ្ឌ ៩៩-១០១។
https://hudoc.echr.coe.int/eng#{"fulltext":["SAMOILA%20AND%20CIONCA"],"documentcollectionid2":["GRANDCHAMBER","CHAMBER"],"itemid":["001-85390"]}

[136] ចំណុចនេះសំដៅលើឯកសណ្ឋានពណ៌ខៀវរបស់ទណ្ឌិត ដែលក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសថាឯកសណ្ឋានពណ៌ខៀវនេះគឺសម្រាប់ទណ្ឌិតដែលសាលក្រម ឬសាលដីកាបានចូលជាស្ថាពររួចហើយ។ សូមមើលព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ឯកសណ្ឋានជនជាប់ឃុំ និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស (ខែមិថុនា ឆ្នាំ២០១៧) https://sithi.org/km/tmp/publication/view/2017-06-05-issue-2-quarterly-newsletter-on-prisoner-uniform-and-the-presumption-of-innocence។

សម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ("វិធាននែលសាន់ ម៉ាន់ដឺឡា (Nelson Mandela)"[137] បានអនុម័តដោយមហាសន្និបាទអង្គការសហប្រជាជាតិក្នុងឆ្នាំ២០១៥ និងដែលបង្ហាញពីការប្រតិបត្តិល្អសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំត្រូវបានទទួលស្គាល់ជាអន្តរជាតិថែងថា "ជនជាប់ឃុំ ដែលពុំទាន់កាត់ទោសត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់របស់ខ្លួន ប្រសិនបើសម្លៀកបំពាក់នោះស្អាតបាតត្រឹមត្រូវល្អ។ ប្រសិនបើគេស្លៀកពាក់ឯកសណ្ឋានពន្ធនាគារ ឯកសណ្ឋាននោះមិនត្រូវឱ្យដូចគ្នាទៅនឹងឯកសណ្ឋានរបស់ជនជាប់ឃុំ ដែលតុលាការបានកាត់ទោសជាស្ថាពរហើយនោះទេ"។ នៅ អ.វ.ត.ក ជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការព្រហ្មទណ្ឌ រហូតមានសេចក្តីសម្រេចជាស្ថាពរ។ ហេតុនេះ ជនជាប់ចោទគួរតែទទួលបានការអនុញ្ញាតឱ្យបង្ហាញខ្លួនចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ផ្ទាល់ខ្លួន។ យ៉ាងហោចណាស់ ឯកសណ្ឋានពន្ធនាគារដែលពួកគេស្លៀកពាក់ត្រូវតែខុសពីឯកសណ្ឋានរបស់ទណ្ឌិត។ ជាលទ្ធផលនៃការតស៊ូមតិរបស់ ម.ស.ម.ក មានការផ្លាស់ប្តូរជាសន្សឹមៗទៅលើចំណុចនេះ ដោយក្នុងនោះមានជនជាប់ចោទកាន់តែច្រើនបានបង្ហាញខ្លួនក្នុងឯកសណ្ឋានពណ៌ផ្សេង (ពណ៌ទឹកក្រូច) ជាជាងឯកសណ្ឋានរបស់ទណ្ឌិត (ពណ៌ខៀវ)។ បន្ថែមលើនេះទៀត មានសំណុំរឿងមួយចំនួនតូច ដែលជនជាប់ចោទអាចបង្ហាញខ្លួនចំពោះមុខតុលាការក្នុងសម្លៀកបំពាក់របស់ខ្លួនផ្ទាល់[138]

### *តួលេខទី ១៤៖ ការសន្មតទុកជាមុនថាគ្មានទោស*[139]

| | មាន | មិនមាន | មិនពាក់ព័ន្ធ |
|---|---|---|---|
| តើជនជាប់ចោទបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានរបស់ទណ្ឌិតដែរឬទេ? | ៧២ (២៨,២%) | ១៤៩ (៥៨,៣%) | ៣៤ (១៣,៣%) |
| តើជនជាប់ចោទត្រូវបានដាក់ខ្នោះនៅពេលសវនាការឬទេ? | 0 (0%) | ២២១ (៨៦,៧%) | ៣៤ (១៣,៣%) |
| តើចៅក្រមបានលើកឡើងអំពីពិរុទ្ធភាពរបស់ជនជាប់ចោទមុនពេលចេញសាលដីកាដែរឬទេ? | ២ (0,៨%) | ២៥៣ (៩៩,២%) | 0 (0%) |

---

137 អង្គមហាសន្និបាតអង្គការសហប្រជាជាតិ "វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តិចំពោះជនជាប់ឃុំ" សេចក្តីសម្រេចលេខ ៧០/១៧៥, ឧបសម្ព័ន្ធ, (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥) <https://www.unodc.org/documents/justice-and-prison-reform/GA-RESOLUTION/E_ebook.pdf>។

138 នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ជនជាប់ចោទពីបទជួញដូរគ្រឿងញៀន ដែលត្រូវបានសាលាដំបូងខេត្តតាកែវកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលប្រាំឆ្នាំ ត្រូវបានបញ្ជូនទៅសាលាឧទ្ធរណ៍ដើម្បីចូលរួមសវនាការឧទ្ធរណ៍លើសំណុំរឿងរបស់ខ្លួនក្នុងសម្លៀកបំពាក់ស៊ីវិល។ លោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ ក៏បានបង្ហាញខ្លួនក្នុងសវនាការដោយស្លៀកសម្លៀកបំពាក់របស់គាត់ដែរ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨។

139 ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (២៥៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍។ "មិនពាក់ព័ន្ធ" សំដៅលើសំណុំរឿងដែលជនជាប់ចោទមិនមានវត្តមាន ឬមិនជាប់ពន្ធនាគារ។

| | | | |
|---|---|---|---|
| តើមានការបង្ហាញថា ចៅក្រមបានទាញសេចក្តីសន្និដ្ឋាន និងសម្រេចទោសដោយសារតែការនៅស្ងៀមរបស់ជនជាប់ចោទឬទេ? | ១ (០,៤%) | ២២៩ (៨៩,៨%) | ២៥ (៩,៨%) |

តួលេខខាងលើបង្ហាញថាជនជាប់ចោទចំនួន ៧២ នាក់ ក្នុងចំណោម ២៥៥ នាក់នៅតែបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតនៅពេលសវនាការ ដែលតំណាងឱ្យចំនួន ២៨,២% នៃសំណុំរឿងរបស់ជនជាប់ចោទដែលបានសង្កេតការណ៍ដោយម.ស.ម.ក។ នេះបង្ហាញអំពីការកើនឡើងបើប្រៀបធៀបជាមួយនឹងឆ្នាំ២០១៨/២០១៩ ដែលមានចំនួន ២១,៩% នៃជនជាប់ចោទបានបង្ហាញខ្លួនក្នុងឯកសណ្ឋានទណ្ឌិត។ ការអនុវត្តបែបនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសន្មតទុកជាមុនថាគ្មានទោស។ នេះគឺជាបញ្ហាគួរព្រួយបារម្ភយ៉ាងជាពិសេស ដែលបានធ្វើឱ្យមានការតស៊ូមតិជាច្រើនលើបញ្ហានេះ ដោយសារតែបញ្ហានេះត្រូវបានលើកឡើងដល់សាលាឧទ្ធរណ៍ជាច្រើនដងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ នៅអំឡុងពេលកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងសាលាឧទ្ធរណ៍នៅអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ ២០១៨/២០១៩ សាលាឧទ្ធរណ៍បានលើកឡើងថា ឯកសណ្ឋានរបស់ជនជាប់ចោទមិនត្រូវបានកំណត់ដោយស្ថាប័នរបស់ខ្លួនឡើយ ហើយសាលាឧទ្ធរណ៍នឹងមិនជ្រៀតជ្រែកដល់ការអនុវត្តរបស់នាយកដ្ឋានពន្ធនាគារទេ។[140]

នៅពេលដែលជនជាប់ចោទបង្ហាញខ្លួនក្នុងឯកសណ្ឋានដូចគ្នាជាមួយឯកសណ្ឋានជាទណ្ឌិត នេះបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ។ ជាការចាំបាច់ដែលការអនុវត្តក្នុងការអនុញ្ញាតឱ្យជនជាប់ចោទស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួននៅពេលបង្ហាញខ្លួនចំពោះមុខតុលាការ ត្រូវបានយកទៅអនុវត្តជាទូទៅ។ ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នា អាជ្ញាធរគួរចេញគោលការណ៍ណែនាំឱ្យបានច្បាស់លាស់ដោយគូសបញ្ជាក់ថា ជនជាប់ចោទដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬអ្នកដែលស្ថិតក្នុងដំណាក់កាលជំនុំជម្រះ ប៉ុន្តែនៅពុំទាន់មានសេចក្តីសម្រេចស្ថាពរនៅឡើយ ចាំបាច់ត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួនចំពោះមុខតុលាការដោយស្លៀកសម្លៀកបំពាក់ធម្មតា។

## ៤.៦ សិទ្ធិបង្ហាញភស្តុតាង

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤<br>(៣)(ង) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។" |

[140] ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយប្រធាន និងអនុប្រធានសាលាឧទ្ធរណ៍ ព្រមទាំងអគ្គព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ និងអគ្គលេខាធិការ និងអគ្គលេខាធិការរងសាលាឧទ្ធរណ៍នៅភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៨/២០១៩។

| | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៥៣ | "ចៅក្រមស៊ើបសួរអាចសាកសួរបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្តែងឱ្យឃើញការពិត [...] ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផងដែរ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៥៤ | "មុននឹងឆ្លើយទៅនឹងសួរសំណួរ សាក្សីម្នាក់ៗ ត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិតប៉ុណ្ណោះ។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនេះ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៩៨ | "ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយណាដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ។ |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២១ | "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។ ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ។ ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន និងអាចយកមកធ្វើជាភស្តុតាងបានឡើយ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៤ | "នៅពេលបើកកិច្ចពិភាក្សាដេញដោល ភាគីនីមួយៗអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែបុគ្គលនោះមិនបានកោះហៅឱ្យបានត្រឹមត្រូវទេ។ ការស្តាប់ចម្លើយសាក្សីនេះ ត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះឱ្យថយទៅនៅបន្ទប់រង់ចាំ។" |

| | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៦ | "ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ [...]។ ព្រះរាជអាជ្ញា មេធាវី និងភាគីទាំងអស់ អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរ។ គ្រប់ការលើកសំណួរទាំងអស់ ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់ព្រះរាជអាជ្ញា និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈសវនាការ។ ក្នុងករណីមានការតវ៉ាប្រធានសវនាការសម្រេចចិត្តដោយឥតស្សរចិត្តថា តើសំណួរនេះត្រូវតែសួរ ឬទេ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៨ | "មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីនីមួយៗ ត្រូវស្បថថា ខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៩៤ | "ក្រោយពេលសួរចម្លើយជនជាប់ចោទរួច ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ សាក្សី និងអ្នកជំនាញនឹងត្រូវបានគេស្តាប់ចម្លើយ លុះត្រាតែតុលាការបង្គាប់ឱ្យស្តាប់ចម្លើយជនទាំងនេះ។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [........] សិទ្ធិបង្ហាញភស្តុតាង។ សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី [...]." |

រាល់សេចក្តីសម្រេចទាំងអស់របស់តុលាការត្រូវតែផ្អែកទាំងស្រុងលើភស្តុតាងដែលបានបង្ហាញនៅក្នុងដំណាក់កាលនៃការជំនុំជម្រះ។ ហេតុដូច្នេះ នេះជាការសំខាន់ដែលភាគីនីមួយៗមានឱកាសដើម្បីបង្ហាញភស្តុតាង និងហៅសាក្សីនានាដែលគាំទ្រដល់សំណុំរឿងរបស់ខ្លួន។[141] នេះជារឿងសំខាន់ដូចគ្នាដែលភាគីនីមួយៗត្រូវបានផ្តល់ឱកាសដើម្បីសួរដេញដោលសាក្សី និងតតាំងនឹងភស្តុតាងដែលខ្លួនមិនទទួលយក[142]។ ថ្វីបើវិធាននៃភស្តុតាងតាមរយៈសក្ខីកម្មជាលាយលក្ខណ៍អក្សរ (មានន័យថាភស្តុតាងដែលមិនបានផ្តល់ក្នុងអំឡុងពេលសវនាការ) មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្តី ការធ្វើបែបនេះក៏ត្រូវអនុលោមតាមច្បាប់សិទ្ធិមនុស្សផងដែរ ហើយជនជាប់ចោទមានសិទ្ធិតតាំង និងដេញដោលសួរសាក្សីនៅពេលដែលសាក្សីនោះបានផ្តល់សក្ខីកម្ម ឬនៅដំណាក់កាលបន្ទាប់ទៀតនៃនីតិវិធីមុនសវនាការផ្ទាល់។[143] ជាចុងក្រោយ យោងតាមច្បាប់សិទ្ធិមនុស្ស នៅពេលជនសង្ស័យ ឬជនជាប់ចោទផ្តល់ការសារភាព ការសារភាព

---

[141] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣៤ ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៩។

[142] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ១៣, ៣៩។

[143] សូមមើលឧទាហរណ៍ ECtHR *សំណុំរឿង Mirilashvili ទល់នឹងប្រទេសរុស្ស៊ី* ឆ្នាំ២០០៨ វាក្យខណ្ឌ ១៦៣ http://hudoc.echr.coe.int/eng?i=001-90099។ ECtHR *សំណុំរឿង Asch ប្រទេសអូទ្រីស* ឆ្នាំ១៩៩១ វាក្យខណ្ឌ ២៧ http://hudoc.echr.coe.int/eng?i=001-57676។ ECtHR សំណុំរឿង Isgrò ទល់នឹងប្រទេសអ៊ីតាលី ឆ្នាំ១៩៩១ វាក្យខ័ណ្ឌ ៣៤ http://hudoc.echr.coe.int/eng?i=001-57653។ ECtHR *សំណុំរឿង Kostovski ទល់នឹងប្រទេសហូឡង់* ឆ្នាំ១៩៨៩ វាក្យខណ្ឌ ៤១ http://hudoc.echr.coe.int/eng?i=001-57615។

នោះត្រូវធ្វើឡើងដោយពុំមានការបង្ខិតបង្ខំដោយផ្ទាល់ ឬដោយប្រយោលតាមផ្លូវកាយ ឬតាមផ្លូវចិត្តណាមួយឡើយ។[144] ប្រសិនបើបុគ្គលនោះចោទប្រកាន់ថាមានការរំលោភបំពានលើសិទ្ធិរបស់ខ្លួន បន្ទុកនៃការបង្ហាញភស្តុតាងត្រូវធ្លាក់លើភាគីដែលបានលើកពីការសារភាពនោះមកបង្ហាញថា ការសារភាពនោះពុំត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំ ហើយបញ្ហានេះពុំមែនជាបន្ទុករបស់ជនជាប់ចោទក្នុងការបង្ហាញថា ការសារភាពនោះត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំនោះឡើយ។[145] ភស្តុតាងដែលទទួលបានដោយការរំលោភបំពានលើសិទ្ធិនេះត្រូវតែមិនអាចទទួលយកបាននៅក្នុងសវនាការ (សូមមើលចំណុច ៤.១ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព)។[146]

ចាប់ពីការប្រមូលទិន្នន័យមក នៅក្នុងចំណោមសំណុំរឿងទាំងអស់ចំនួន ២០៣ ដែលបានសង្កេតការណ៍ពុំមានអ្វីបានបង្ហាញថាមានភាគីណាមួយមិនត្រូវបានផ្តល់ឱកាសឱ្យហៅសាក្សីនោះទេ។ ទោះបីជាសិទ្ធិនេះកំពុងត្រូវបានលើកកម្ពស់យ៉ាងនេះក៏ដោយ សិទ្ធិបង្ហាញភស្តុតាងនៅតែមិនទាន់ត្រូវបានគោរពពេញលេញដោយសារហេតុផលចម្បងពីរយ៉ាង។ ទីមួយ សំណុំរឿងមួយក្នុងចំណោមពីរសំណុំរឿងដែលសាក្សីត្រូវបានកោះហៅ គឺសាក្សីបានស្ថិតនៅក្នុងបន្ទប់សវនាការមុនពេលត្រូវសាកសួរ។ ការអនុវត្តបែបនេះអាចនាំឱ្យសក្ខីកម្មរបស់សាក្សីទាំងនោះរងឥទ្ធិពលដោយសារការស្តាប់ឮសក្ខីកម្មរបស់សាក្សីផ្សេងទៀតមុនពេលផ្តល់សក្ខីកម្ម។ ការអនុវត្តប្រសើរជាងនេះ គួរតែឱ្យសាក្សីចេញពីបន្ទប់សវនាការ និងមិនត្រូវត្រឡប់ចូលបន្ទប់សវនាការវិញ រហូតទាល់តែសាក្សីនោះត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម។

លើសពីនេះទៀត សាលាឧទ្ធរណ៍ត្រូវតែធានាថា ភស្តុតាងដែលត្រូវយកមកថ្លឹងថ្លែងមានគុណតម្លៃគ្រប់គ្រាន់ (ភាពគួរជឿជាក់ និងភាពពិតប្រាកដ) និងធានាថា ភាគីទាំងអស់មានឱកាសក្នុងការជំទាស់នឹងភស្តុតាងនោះ។ ទិន្នន័យដែលបានប្រមូលនៅអំឡុងពេលសង្កេតការណ៍សវនាការបង្ហាញថា គុណភាពនៃភស្តុតាងដែលបានបង្ហាញគឺជាប្រការគួរឱ្យព្រួយបារម្ភជាខ្លាំង។ ការសារភាពចំនួន៩ត្រូវបានបង្ហាញនៅពេលសវនាការជាភស្តុតាង ហើយក្នុងចំណោមនោះ ការសារភាពចំនួន៤ត្រូវបានចៅក្រមជឿថាជាភស្តុតាង។ គុណភាព និងបរិមាណនៃភស្តុតាងដែលបានបង្ហាញ និងពិចារណានៅពេលសវនាការជំនុំជម្រះមានភាពចាំបាច់ដើម្បីធានាថា បុគ្គលគ្រប់រូបត្រូវបានរកឃើញពិរុទ្ធភាពហួសពីវិមតិសង្ស័យ។ បន្ថែមពីលើភស្តុតាងជាឯកសារ ចៅក្រម និងព្រះរាជអាជ្ញាគួរតែមានភាពសកម្មក្នុងការស្វែងរក និងពិនិត្យភស្តុតាងប្រភេទដទៃទៀតដែលពាក់ព័ន្ធ ដូចជា សាក្សីផ្ទាល់ ភស្តុតាងវេជ្ជសាស្ត្រ និងភស្តុតាងកោសល្យវិច័យជាដើម។ ការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បង្ហាញឱ្យឃើញថា ពុំមាននិន្នាការពិនិត្យលើភស្តុតាងប្រភេទនេះនៅសាលាឧទ្ធរណ៍ឡើយ។ នៅអំឡុងពេលកិច្ចប្រជុំពិគ្រោះយោបល់លើរបាយការណ៍កន្លងមក ចៅក្រមសាលាឧទ្ធរណ៍បានបញ្ជាក់ថា ពួកគាត់នឹងមិនស្នើភស្តុតាងពីសាក្សីទាំងឡាយណាដែលបានផ្តល់សក្ខីកម្មរួចហើយនៅក្នុង

---

144 គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១។ សូមមើលផងដែរ៖ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *សំណុំរឿង Deolall ទល់នឹង Guyana* សេចក្តីសម្រេចលេខ ៩១២/២០០០ ឆ្នាំ២០០៤ វាក្យខណ្ឌ ៥.១ http://juris.ohchr.org/Search/Details/1149៖ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សំណុំរឿងសំណុំរឿង *Singarasa* ទល់នឹងប្រទេសស្រីលង្កា សេចក្តីសម្រេចលេខ ១០៣៣/២០០១ ឆ្នាំ២០០៤ វាក្យខណ្ឌ ៧.៤ http://juris.ohchr.org/Search/Details/1125 គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សំណុំរឿង *Khuseynova and Butaeva* ទល់នឹងប្រទេសតាជីគីស្ថាន សេចក្តីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ ឆ្នាំ២០០៨ វាក្យខណ្ឌ ៨.៣ http://juris.ohchr.org/Search/Details/1457។

145 គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ ឆ្នាំ២០០៧ វាក្យខណ្ឌ ៤១។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *សំណុំរឿង Singarasa ទល់នឹងប្រទេសស្រីលង្កា* សេចក្តីសម្រេចលេខ ១០៣៣/២០០១ ២០០៤ វាក្យខណ្ឌ ៧.៤ http://juris.ohchr.org/Search/Details/1125។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សំណុំរឿង *Khuseynova and Butaeva ទល់នឹងប្រទេសតាជីគីស្ថាន* សេចក្តីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ ឆ្នាំ២០០៨ វាក្យខណ្ឌ ៨.៣ http://juris.ohchr.org/Search/Details/1457។

146 គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៦, ៤១ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ២៩ ឆ្នាំ២០០១ វាក្យសព្ទ ៧, ១៥ http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d/PPRiCAqhKb7yhsjYoiCfMKoIRv2FVaVzRkMjTnjRO%2Bfud3cPVrcM9YR0iix49nlFOsUPO4oTG7R/o7TSsorhtwUUG%2By2PtslYr5BldM8DN9shT8B8NpbsC%2B7bODxKR6zdESeXKjiLnNU%2BgQ%3D%3D។

ដំណាក់កាលជំនុំជម្រះលើកមុននោះឡើយ ហើយមានតែសាក្សីថ្មីប៉ុណ្ណោះដែលត្រូវបានកោះឱ្យផ្តល់សក្ខីកម្មនៅក្នុងសវនាការ។[147]

ឆ្លើយតបនឹងចំណុចនេះ សាលាឧទ្ធរណ៍បានបញ្ជាក់ជាថ្មីម្តងទៀតថា គូភាគី រួមទាំងតំណាងអយ្យការផង មានសិទ្ធិបង្ហាញភស្តុតាង ទាំងដាក់បន្ទុក និងដោះបន្ទុកដោយសេរី កុំឱ្យតែនីតិវិធីត្រូវបានបញ្ចប់។ ចំណុចនេះ សាលាឧទ្ធរណ៍ទទួលពិនិត្យភស្តុតាង ប្រសិនបើភស្តុតាងនោះមានប្រយោជន៍បង្ហាញឱ្យឃើញនូវការពិត និងផ្តល់យុត្តិធម៌ដល់គូភាគី ការទទួលយកភស្តុតាង អាស្រ័យលើការពិចារណាអំពីអត្ថប្រយោជន៍នៃភស្តុតាងដែលតុលាការអាចជឿ និងមានប្រយោជន៍ផ្លូវច្បាប់។[148]

## ៤.៧ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣៥៧ | "សាលក្រមទាំងអស់ត្រូវមានពីរផ្នែកៈ<br>• ផ្នែកសំអាងហេតុពោលគឺជាទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច។<br>• ផ្នែកសម្រេច ពោលគឺសេចក្តីសម្រេចរបស់តុលាការ។<br>អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការត្រូវតែពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកឡើងនៅពេលសវនាការ។ នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី។ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេសអំពីបទល្មើសដែលជនជាប់ចោទប្រព្រឹត្តខុសអត្ថបទច្បាប់ដែលអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៤០៣ | "វិធានស្តីពីទម្រង់ និងហត្ថលេខាសាលក្រមរបស់តុលាការសាលាដំបូង ត្រូវយកមកអនុវត្តលើសាលដីការបស់សាលាឧទ្ធរណ៍"។ |

សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុគឺជាប់ជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងត្រូវបានរួមបញ្ចូលនៅក្នុងសិទ្ធិទទួលបានសេចក្តីប្រកាសសេចក្តីសម្រេចជាសាធារណៈ។ យោងតាមបទដ្ឋានអន្តរជាតិ ដើម្បីអនុវត្តសិទ្ធិប្រកបដោយប្រសិទ្ធភាពក្នុងការស្នើឱ្យតុលាការជាន់ខ្ពស់ ពិនិត្យពីការចោទប្រកាន់ និងការផ្តន្ទាទោសមកលើខ្លួន បុគ្គលដែលត្រូវបានកាត់ឱ្យជាប់ទោសមានសិទ្ធិទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុង

---

[147] នៅថ្ងៃទី១៣ ខែសីហា ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយនឹងប្រធាន អនុប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ និងអគ្គលេខាធិការរងនៃសាលាឧទ្ធរណ៍ភ្នំពេញដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍ ឆ្នាំ ២០១៨/២០១៩។

[148] លិខិតឆ្លើយតបរបស់សាលាឧទ្ធរណ៍ភ្នំពេញ លេខ ៤៣១ របឧ/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ លើសេចក្តីព្រាងរបាយការណ៍របស់ ម.ស.ម.ក ឆ្នាំ២០១៩/២០២០។

រយៈពេលមួយសមរម្យ ដែលមានសំអាងហេតុត្រឹមត្រូវ ក្នុងការបើកផ្លូវប្តឹងជំទាស់ទៅតុលាការជាន់ខ្ពស់ ។[149] ក្នុងបរិបទកម្ពុជា សិទ្ធិនេះត្រូវបានគោរពដោយជនជាប់ចោទ និងអយ្យការ ដែលមានសិទ្ធិប្តឹងសារទុក្ខលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូលបន្ថែមទៀត។

ក្រមនីតិវិធីព្រហ្មទណ្ឌចែងថា សាលក្រមទាំងអស់ដែលចេញដោយសាលាដំបូង ត្រូវតែមានពីរផ្នែកៈ ផ្នែកសំអាងហេតុ ពោលគឺជា "ទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច" និងសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៣៥៧)។ សាលក្រមត្រូវតែច្បាស់លាស់ ហើយចៅក្រមត្រូវតែពិនិត្យមើល "បទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកឡើងនៅពេលសវនាការ"។ នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី (មាត្រា ៣៥៧)។ មាត្រា ៤០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា បញ្ញត្តិទាំងនេះត្រូវតែអនុវត្តលើសាលដីការបស់សាលាឧទ្ធរណ៍។

នៅខែមីនា ឆ្នាំ២០១៨ សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី រ៉ូណា ស្មីត បានគូសបញ្ជាក់អំពីសារសំខាន់នៃសិទ្ធិនេះ ដោយអំពាវនាវឱ្យមាន "តម្លាភាពកាន់តែល្អប្រសើរនៅក្នុងសេចក្តីសម្រេចរបស់តុលាការ" និង "នាំឱ្យមានភាពស៊ីសង្វាក់កាន់តែល្អប្រសើរនៅក្នុងសេចក្តីសម្រេចលើភស្តុតាង និងការអនុវត្តច្បាប់ជាធរមាន" ដើម្បីលើកកម្ពស់ឱ្យមានភាពច្បាស់លាស់ផ្នែកច្បាប់កាន់តែល្អប្រសើរ និងកែលម្អការយល់ឃើញរបស់សារធារណជន។ លោកស្រីបានផ្តល់អនុសាសន៍ថា "ផែនការបង្កើតសិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ និងសំអាងហេតុផ្លូវច្បាប់គួរតែអនុវត្តឱ្យមានវឌ្ឍនភាព"។[150]

សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ សំដៅលើការចេញសាលក្រមព្រហ្មទណ្ឌប្រឆាំងលើនរណាម្នាក់ ត្រូវតែពន្យល់អំពីមូលហេតុ និងដំណើរការឈានដល់ការកាត់ទោស និងមូលហេតុដែលបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធភាព និងភាពគ្មានទោស។ ដើម្បីធ្វើដូចនេះបាន ទាំងអង្គហេតុ និងអង្គច្បាប់ដែលជាសំអាងហេតុក្នុងការចេញសាលក្រមត្រូវតែពន្យល់៖

- ***អង្គហេតុ៖*** សាលក្រមត្រូវតែបញ្ជាក់ឱ្យបានច្បាស់នូវអង្គហេតុដែលជាសំអាងហេតុក្នុងការកាត់ទោសលើជនជាប់ចោទ រួមទាំង កាលបរិច្ឆេទ ទីកន្លែង និងហេតុការណ៍ជាក់ស្តែងផងដែរ។ ដើម្បីធ្វើបែបនេះ ចៅក្រមត្រូវយោងឱ្យបានត្រឹមត្រូវតាមភស្តុតាងនីមួយៗដែលជាសំអាងក្នុងធ្វើសេចក្តីសម្រេច ឧទាហរណ៍ ការសារភាព ឬសក្ខីកម្មជាក់លាក់របស់សាក្សី និងពន្យល់អំពីមូលហេតុដែលខ្លួនផ្អែកលើចំណុចទាំងនេះ។
- ***អង្គច្បាប់៖*** សាលក្រមក៏ត្រូវតែដាក់បញ្ចូលផងដែរនូវមូលដ្ឋានច្បាប់ដែលជាសំអាងហេតុនៃការកាត់ទោស ទាំងនៅក្នុងន័យច្បាប់ព្រហ្មទណ្ឌ (ព្រហ្មទណ្ឌ) និងទំនួលខុសត្រូវបទព្រហ្មទណ្ឌ (ទម្រង់នៃទំនួលខុសត្រូវៈ ឧក្រិដ្ឋជនផ្ទាល់ អ្នកផ្សំគំនិត ។ល។)។

[149] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៩។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សំណុំរឿង *V. Francis ទល់នឹង Jamaica* សេចក្តីសម្រេចលេខ ៣២០/១៩៨៨ ឆ្នាំ១៩៩៣ វាក្យខណ្ឌ ១២.២ http://hrlibrary.umn.edu/undocs/html/320-1988.html។

[150] នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ សេចក្តីថ្លែងបញ្ចប់បេសកកម្មរបស់អ្នករាយការណ៍ពិសេស។ https://cambodia.ohchr.org/sites/default/files/End%20of%20Mission%20statement%2014%20March%202018.pdf ("SRSHRC, សេចក្តីថ្លែងបញ្ចប់បេសកកម្ម (ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨)")

ការចេញសាលក្រមមានសំអាងហេតុ គឺមានសារៈសំខាន់ក្នុងការធានានូវសុវត្ថិភាពពីការកាត់ទោសតាមទំនើងចិត្ត[151] ដោយហេតុថាការណ៍នេះតម្រូវឱ្យចៅក្រមពន្យល់អំពីការធ្វើសេចក្តីសម្រេចរបស់ខ្លួន និងធានាថាជនដែលត្រូវកាត់ទោសបានដឹងអំពីមូលហេតុ និងហេតុផលដែលខ្លួនត្រូវបានកាត់ទោស។

ក្នុងបរិបទកម្ពុជា សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុមានភាពចាំបាច់ណាស់ ដោយហេតុថាជនជាប់ចោទមានសិទ្ធិប្តឹងសារទុក្ខលើសេចក្តីសម្រេចតម្កល់ទុកជាបានការរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូលបន្ថែមទៀត។ គួរឱ្យសោកស្តាយ នៅស្ទើរតែគ្រប់សំណុំរឿងទាំងអស់ដែល ម.ស.ម.ក បានសង្កេតការណ៍ ចៅក្រមមិនបានផ្តល់មូលដ្ឋានហេតុផលចំពោះសេចក្តីសម្រេចរបស់ខ្លួនឡើយ ផ្ទុយទៅវិញ ចៅក្រមគ្រាន់តែអាន និងប្រកាសសេចក្តីសម្រេចតែប៉ុណ្ណោះ។

នៅឆ្នាំ២០១៤-២០១៥ ចៅក្រមមិនបានបញ្ជាក់អំពីមាត្រាច្បាប់ពាក់ព័ន្ធនៅពេលប្រកាសសាលដីកាចំនួន ៨០% ហើយមិនបានលើកឡើងអំពីភស្តុតាងក្នុងសំណុំរឿង ៧៣%។ នៅក្នុងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ សំណុំរឿងចំនួន ៦៧,៥% មិនត្រូវបានផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចគ្រប់គ្រាន់ឡើយ។ នៅអំឡុងពេលធ្វើរបាយការណ៍ ឆ្នាំ២០១៧-២០១៨ សំណុំរឿងចំនួន ៨៧,៤% ពុំមានការផ្តល់សំអាងហេតុគ្រប់គ្រាន់ឡើយ។ ខណៈដែលមានការកត់សម្គាល់ឃើញថា មានការកែលម្អនៅរយៈពេលធ្វើរបាយការណ៍ចុងក្រោយ ដោយសាលដីកាដែលពុំបានផ្តល់សំអាងហេតុគ្រប់គ្រាន់មានចំនួនត្រឹមតែ ៤៧,៥% ប៉ុន្តែការកែលម្អនេះមិនបានរក្សាស្ថិតនៅទេ ដោយហេតុថានៅអំឡុងពេលធ្វើរបាយការណ៍នេះឃើញថាសាលដីកាដែលពុំបានផ្តល់សំអាងហេតុគ្រប់គ្រាន់បែបនេះមាន ៦៤,៧%។

អាស្រ័យហេតុនេះ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុនៅតែមិនទាន់បានគោរពតាមពេញលេញនៅឡើយ។ ដូចដែលបានបង្ហាញខាងលើ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុគឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានភាគច្រើនផ្សេងទៀត។ ជាប្រការចាំបាច់ដែលត្រូវបង្កើនការយកចិត្តទុកដាក់លើបញ្ហានេះ ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា។

---

[151] "សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌" អង្គការលើកលែងទោសអន្តរជាតិ ទំព័រ ១៧៤ ផ្នែក ២៤.២ https://www.amnesty.org/download/Documents/8000/pol300022014en.pdf ("សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ")។

*តួលេខទី ១៥៖ ការវិវត្តនៃសំណុំរឿងដែលសាលដីកាពុំផ្តល់សំអាងហេតុគ្រប់គ្រាន់ (ឆ្នាំ២០១៤-២០២០)*[152]




អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានកត់សម្គាល់ថា ក្នុងសំណុំរឿងទាំងអស់ ដែលសាលដីកាត្រូវបានប្រកាសនៅពេលដែល ម.ស.ម.ក បានកំពុងសង្កេតការណ៍សវនាការសាលាឧទ្ធរណ៍ បានចេញសាលដីកាផ្តន្ទាទោសដោយតម្កល់ទុកសេចក្តីសម្រេចរបស់សាលាដំបូងទុកជាបានការដដែល ជានិន្នាការដែលនៅតែបន្តចាប់ពីអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៦/២០១៧ មកម្ល៉េះ។ ចំណុចនេះ បូករួមជាមួយនឹងកង្វះនៃការអានសំអាងហេតុនៅក្នុងសេចក្តីសម្រេច បង្កើតឱ្យមានមូលហេតុគួរឱ្យព្រួយបារម្ភថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានគោរពឬយ៉ាងណា។

ឆ្លើយតបនឹងរបាយការណ៍នេះ សាលាឧទ្ធរណ៍បានបញ្ជាក់ថា ចៅក្រមបានប្រកាសសាលដីកា ដោយអានទាំងសំអាងហេតុ និងសេចក្តីសម្រេច លើកលែងតែមិនមានវត្តមានគូភាគី ទើបចៅក្រមអានតែសេចក្តីសម្រេច។ តាមគោលការណ៍ច្បាប់ ចៅក្រមអាចប្រកាសទាំងផ្នែកសំអាងហេតុ និងផ្នែកសេចក្តីសម្រេច ឬអាចប្រកាសផ្នែកសេចក្តីសម្រេចដោយផ្អែកទៅតាមស្ថានភាពនៃរឿងក្តី និងពេលវេលា។[153]

## ៤.៨ សិទ្ធិរបស់អនីតិជន

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(១) | ក.អ.ស.ព.ន មាត្រា ១៤ (១)៖ "សារព័ត៌មាន និងសាធារណជន អាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ [...] នៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឱ្យធ្វើដូច្នេះ [...] ប៉ុន្តែការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ រដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍ អនីតិជនតម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់ កុមារ។" |

[152] ទិន្នន័យនេះផ្អែកទៅលើចំនួនសំណុំរឿងសរុបដែលអ្នកសង្កេតការណ៍សវនាការមានវត្តមាននៅពេលប្រកាសសាលដីកានៅឆ្នាំ២០១៤/២០១៥ (២៦ សំណុំរឿង) ឆ្នាំ២០១៦/២០១៧ (២៥៥ សំណុំរឿង) ឆ្នាំ២០១៧/២០១៨ (៩៥ សំណុំរឿង) ឆ្នាំ២០១៨/២០១៩ (៩៩ សំណុំរឿង) និង ឆ្នាំ២០១៩/២០២០ (១៨ សំណុំរឿង)។

[153] លិខិតឆ្លើយតបរបស់សាលាឧទ្ធរណ៍ភ្នំពេញ លេខ ៤៣១ បឧ/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ លើសេចក្តីព្រាងរបាយការណ៍របស់ ម.ស.ម.ក ឆ្នាំ២០១៩/២០២០។

| | |
|---|---|
| អនុសញ្ញាស្តីពីសិទ្ធិកុមារ<br>មាត្រា ៤០(២)(ខ)<br>(vii) | "រដ្ឋភាគីត្រូវធានា ជាពិសេសថា [...] ត្រូវគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារ នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។" |
| អនុសញ្ញាស្តីពី<br>សិទ្ធិកុមារ<br>មាត្រា ៤០(៤) | "ចំណាត់ថ្នាក់មួយចំនួន ដូចជា ការថែទាំ របៀបណែនាំ និងដីកាតាមដានពិគ្រោះយោបល់ ការសាកល្បងឱ្យនៅក្រៅឃុំ ការថែទាំដោយឪពុក-ម្តាយធម៌ កម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមធ្យោបាយផ្សេងៗទៀតជំនួសការថែទាំតាមស្ថាប័ន ត្រូវធ្វើឱ្យមាន ដើម្បីធានាថា កុមារទទួលបាននូវចំណាត់ការដែលសមស្រប ចំពោះសុខុមាលភាពរបស់ខ្លួន និងមានសមាមាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៣១ | "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុង [...] កតិកាសញ្ញា ព្រមទាំង អនុសញ្ញាទាំងឡាយទាក់ទងនឹង [...] សិទ្ធិកុមារ។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៤៨ | "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១០០ | "កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជន។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ២១២ | "អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្តាយអ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។" |
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ៣៩ | "អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន អាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។" |

| | |
|---|---|
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ៤០ | "វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ៖ ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្ដិសមនឹងមានទំនុកចិត្ត ការប្រគល់អនីតិជន ឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ការប្រគល់ អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ការប្រគល់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។" |
| **ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥** | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា [...] ត្រូវផ្ដល់ឱកាសឱ្យអនីតិជនសម្ដែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន។ ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី។[154] ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្ដន្ទាទោស អនីតិជនជាវិធានចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន [...]" |
| ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន<br>មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស ត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖<br>• សិទ្ធិមិនផ្ដល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី<br>• សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង<br>• សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន<br>• សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល<br>• សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់<br>• សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់<br>• សិទ្ធិទទួលបានជំនួយពីមេធាវីដោយស្របតាមលក្ខខណ្ឌនៃច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីដោយ ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី<br>• សិទ្ធិឱ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្ដី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន |

[154] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន មាត្រា ៤ ចំណុច ៧។

| | |
|---|---|
| | • សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់<br>• សិទ្ធិបង្ហាញភស្តុតាង<br>• សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី<br>• សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ<br>• សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ<br>• សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស<br>• សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។" |
| **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៣៩** | "ការឃុំខ្លួនអនីតិជនបណ្តោះអាសន្នជាវិធានការចុងក្រោយ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៤៧ | "ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការអសាធារណៈ [...]" |
| **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៤៨** | "[...] ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញាអាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៤៩ | "ក្នុងករណីតុលាការឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឱ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឱ្យដោះលែងអនីតិជនដែលជាប់ឃុំឃាំងជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឱ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ [...]" |
| **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥៤** | "សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ ជាគោលការណ៍សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី។ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបានក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។" |

| | |
|---|---|
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥៧ | "[...] ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព។ ក្នុងករណីរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព។" |

ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិទទួលស្គាល់ថា អនីតិជនពាក់ព័ន្ធនឹងនីតិវិធីព្រហ្មទណ្ឌចាំបាច់ត្រូវការការការពារជាពិសេស។

យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក") ដែលបានកំណត់និយមន័យកុមារថាជាបុគ្គលទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ[155] រដ្ឋភាគីត្រូវព្យាយាមលើកកម្ពស់ឱ្យមានការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នដែលត្រូវអនុវត្តជាពិសេសចំពោះកុមារជាជនជាប់ចោទ ឬកុមារដែលត្រូវបានទទួលស្គាល់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ[156] ជាពិសេស៖

i. រដ្ឋត្រូវកំណត់អាយុអប្បបរមាក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលកុមារត្រូវបានសន្មតថាពុំមានសមត្ថភាពអាចបំពានច្បាប់ព្រហ្មទណ្ឌបាន។[157] កុមារដែលមានអាយុក្រោមអាយុអប្បបរមានៅពេលប្រព្រឹត្តបទល្មើសមិនអាចទទួលខុសត្រូវចំពោះនីតិវិធីច្បាប់ព្រហ្មទណ្ឌបានទេ[158]។ ជាគោលការណ៍អន្តរជាតិ អាយុអប្បបរមាបំផុតជាទូទៅគឺអាយុ ១៤ ឆ្នាំ។[159] អាយុ ១៤ ឆ្នាំគឺជាអាយុអប្បបរមា ដែលបានកំណត់ដោយច្បាប់កម្ពុជា។[160]
ii. កុមារដែលមានអាយុត្រឹម ឬលើសពីអាយុអប្បបរមានៃទំនួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែមានអាយុក្រោម ១៨ ឆ្នាំ អាចត្រូវបានចោទប្រកាន់ជាផ្លូវការ និងត្រូវដំណើរការនីតិវិធីយុត្តិធម៌កុមារដោយអនុលោមតាម អ.ស.ក។[161] ទោះបីជាយ៉ាងនេះក្តី យោងតាម អ.ស.ក រដ្ឋភាគីត្រូវបានតម្រូវឱ្យលើកកម្ពស់វិធានការដោះស្រាយជាមួយកុមារ ដោយមិនដោះស្រាយតាមដំណើរការនីតិវិធីតុលាការនោះទេ "នៅពេលសមស្រប និងត្រូវការ"។[162] វិធានការនេះអាចជាវិធានការផ្លូវកាត់ ដែលជា "វិធានការបញ្ជូនកុមារឱ្យទៅឆ្ងាយពីប្រព័ន្ធតុលាការ នៅពេលណាមួយមុនពេល ឬក្នុងអំឡុងពេលដំណើរការនីតិវិធីពាក់ព័ន្ធ" (ឧ៖ ការងារសហគមន៍ ការត្រួតពិនិត្យ និងណែនាំដោយមន្ត្រីដែលបានចាត់តាំង) ឬវិធានការនៅក្នុងបរិបទនៃដំណើរការតុលាការ។[163]

---

[155] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ១៖ "សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារមានន័យថាជាមនុស្សមានអាយុក្រោម ១៨ ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ។"

[156] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០(៣)។

[157] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០(៣)។

[158] គណៈកម្មាធិការស្តីពីសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ២៤, ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩, វាក្យខណ្ឌ ២០ ("UNCRC, សេចក្តីពន្យល់ទូទៅលេខ ២៤") សូមមើល គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, វាក្យខណ្ឌ ៤៣។

[159] គណៈកម្មាធិការស្តីពីសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១។

[160] ច្បាប់ស្តីពីអនីតិជន មាត្រា ៤៩។

[161] គណៈកម្មាធិការស្តីពីសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១។

[162] មាត្រា ៤០(៣) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ១៣។

[163] មាត្រា ៤០(៣) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ UNCRC សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ១៣។ សូមមើល គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៤។

បន្ថែមលើនេះទៀត ចំណាត់ការមួយចំនួន ដូចជាការថែទាំ ដឹកាណែនាំ និងត្រួតពិនិត្យ ការប្រឹក្សាយោបល់ ការព្យួរទោសសាកល្បង ការថែទាំដោយអាណាព្យាបាល កម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទោសជំនួសផ្សេងៗទៀតសម្រាប់ការថែទាំតាមស្ថាប័នត្រូវធ្វើឱ្យមានដើម្បីធានាថា កុមារទទួលបាននូវចំណាត់ការដែលសមស្របចំពោះសុខុមាលភាពរបស់ខ្លួន និងសមាមាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។[164]

អនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ ដែលត្រូវអនុវត្តចំពោះមនុស្សពេញវ័យ ព្រមទាំងមានសិទ្ធិទទួលបានកិច្ចការពារបន្ថែមដោយពិចារណាទៅលើអាយុ ភាពចាស់ទុំ និងការអភិវឌ្ឍផ្នែកសតិបញ្ញារបស់កុមារ។ ក.អ.ស.ព.ន និង អ.ស.ក ដែលបានចូលជាធរមានក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២ ចែងពីមាត្រាជាក់លាក់ស្តីពីការប្រព្រឹត្តចំពោះអនីតិជនក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។[165] លិខិតូបករណ៍គតិយុត្តិទាំងអស់នេះបានទទួលការគាំទ្រពីវិធាន និងគោលការណ៍ណែនាំអន្តរជាតិមួយចំនួន។ ដូចបានបញ្ជាក់ខាងលើហើយថា បទប្បញ្ញត្តិច្បាប់មួយចំនួនក្នុងច្បាប់កម្ពុជាចែងបន្ថែមទៀតអំពីការប្រព្រឹត្តចំពោះអនីតិជន ដែលខុសប្លែកពីការប្រព្រឹត្តចំពោះមនុស្សពេញវ័យលើវិស័យសំខាន់ៗមួយចំនួន។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័តនៅឆ្នាំ ២០១៦ ដើម្បីធានាសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

### *តួលេខទី ១៦៖ អាយុជនជាប់ចោទនៅពេលបទល្មើសកើតឡើង[166]*




នៅអំឡុងពេលធ្វើរបាយការណ៍ ក្នុងចំណោមជនជាប់ចោទចំនួន ២៥៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍ ជនជាប់ចោទចំនួន ១៥ នាក់ជាអនីតិជននៅពេលបទល្មើសបានកើតឡើង ដែលជនជាប់ចោទទាំងអស់ក្នុងចំណោមនោះត្រូវបានឃុំខ្លួន។ ជនជាប់ចោទជាអនីតិជនភាគច្រើនដែលជាភាគីក្នុងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍នៅអំឡុងពេលធ្វើរបាយការណ៍នេះមានអាយុ ១៦-១៧ ឆ្នាំ នៅពេលមានបទល្មើសបានកើតឡើង (១៣ នាក់ ក្នុងចំណោម ១៥ នាក់ ឬស្មើនឹង ៨៧%) ហើយជនជាប់ចោទ ២ នាក់ (១៣%) មានអាយុ ១៤-១៥ ឆ្នាំ នៅពេលបទល្មើសបានកើតឡើង។

---

164 អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០(៤)។

165 មាត្រា ៤០(៣) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ UNCRC សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ១៣។ សូមមើល គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៤។

166 ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទជាអនីតិជនសរុប (១៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ១៥ ដែលបានសង្កេតការណ៍។

*តួលេខទី ១៧៖ ភាគរយជនជាប់ចោទជាអនីតិជនត្រូវបានឃុំខ្លួន (ឆ្នាំ២០១៤-២០២០)*[167]




ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាការពិចារណាចម្បងនៅពេលចេញដីកា ឬបង្គាប់ឱ្យមានការផ្តន្ទាទោសលើអនីតិជនដែលត្រូវបានរកឃើញថាបានបំពានច្បាប់ព្រហ្មទណ្ឌ។[168] ការដកហូតសិទ្ធិសេរីភាពរបស់អនីតិជន គិតចាប់ពីថ្ងៃចាប់ខ្លួន ក្នុងអំឡុងពេលអនុវត្តនីតិវិធី និងរហូតដល់ការកាត់ទោស ត្រូវបានចាត់ទុកថាជាវិធានការនៃជម្រើសចុងក្រោយបំផុត ហើយគួរត្រូវបានយកមកអនុវត្តតែក្នុងករណីពិសេស និងសម្រាប់តែរយៈពេលខ្លីបំផុតយ៉ាងសមស្របតែប៉ុណ្ណោះ។[169] ច្បាប់គួរតែផ្តល់វិធានការមិនឃាត់ខ្លួនខុសៗគ្នា និងគួរតែកំណត់អាទិភាពសម្រាប់ការអនុវត្តវិធានការទាំងនេះ។[170] ច្បាប់កម្ពុជាចែងឱ្យមានវិធានជំនួសផ្សេងទៀតក្រៅពីការកាត់ទោសជាប់ពន្ធនាគារផងដែរ[171]។ ហេតុនេះ តួលេខខាងលើបង្ហាញអំពីការព្រួយបារម្ភយ៉ាងខ្លាំង ព្រមទាំងការមិនអនុលោមតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដោយហេតុថា ការឃុំខ្លួនអនីតិជនបណ្តោះអាសន្នហាក់ធ្វើឡើងទៅតាមទម្លាប់ជាជាងជាវិធានការនៃជម្រើសចុងក្រោយបំផុត។

នៅក្រោមច្បាប់សិទ្ធិមនុស្ស អនីតិជនមានសិទ្ធិទទួលបានការគោរពចំពោះឯកជនភាពរបស់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។[172] សិទ្ធិនេះរួមមានចាប់តាំងពីការចូលមកពាក់ព័ន្ធជាដំបូងជាមួយការអនុវត្តច្បាប់ រហូតដល់សេចក្តីសម្រេចជាស្ថាពរ ឬប្រសិនបើត្រូវបានកាត់ឱ្យជាប់ទោស ការដោះលែងចេញពីការត្រួតពិនិត្យ ការឃាត់ខ្លួន ឬការដកហូតសេរីភាព។[173] មូលដ្ឋានហេតុផលដែលធ្វើឱ្យមានការអនុវត្តបែបនេះគឺដើម្បីចៀសវាងការបង្កផលប៉ះពាល់តាមរយៈការបង្ហាញព័ត៌មានជាសាធារណៈមិនសមស្រប ឬការផ្សព្វផ្សាយនាំឱ្យមានផលប៉ះពាល់។[174] ហេតុនេះ

---

[167] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុបដែលពាក់ព័ន្ធក្នុងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥ (អនីតិជនចំនួន ១១ នាក់) ឆ្នាំ២០១៦/២០១៧ (អនីតិជន ៣៥ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១៩ ដែលបានសង្កេតការណ៍) ឆ្នាំ២០១៧/២០១៨ (អនីតិជន ៩ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន៨ ដែលបានសង្កេតការណ៍)ឆ្នាំ២០១៨/២០១៩ (អនីតិជន ២២ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន១៤ ដែលបានសង្កេតការណ៍) និងឆ្នាំ២០១៩/២០២០ (អនីតិជន ១៥ នាក់ ពាក់ព័ន្ធនៅក្នុងសំណុំរឿងចំនួន ១៥ ដែលបានសង្កេតការណ៍)។

[168] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣(១) សូមមើល អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ១០, វាក្យខណ្ឌ ១០ ៧១។

[169] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣៧(ខ) សូមមើល អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ២៤, វាក្យខណ្ឌ ១៩, ៧៣, ៨២-៨៥។

[170] អនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤, វាក្យខណ្ឌ ៧៣។

[171] ក្រមព្រហ្មទណ្ឌ មាត្រា ៤០។

[172] ក្រមព្រហ្មទណ្ឌ មាត្រា ៤០(២)(vii) សូមមើល អ.ស.ក មាត្រា ១៦ និង ៤០(១) អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ២៤, វាក្យខណ្ឌ ៦៦។

[173] អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ១០ វាក្យខណ្ឌ ៦៤។

[174] អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧០។

វិធាននេះគួរតែថា សវនាការយុត្តិធម៌កុមារត្រូវធ្វើឡើងនៅក្នុងបន្ទប់បិទជិត ដោយមានការលើកលែងមានកម្រិតដែលត្រូវបានចែងដោយច្បាប់។[175] ឯកជនភាពរបស់ជនរងគ្រោះ ឬជនជាប់ចោទជាអនីតិជនអាចត្រូវបានការពារបន្ថែមទៀតតាមរយៈការដាក់អនីតិជនឱ្យនៅខាងក្រោយរបាំង ឬប្រើប្រាស់មធ្យោបាយជំនួសដទៃទៀតក្នុងការផ្តល់សក្ខីកម្ម។ ការប្រើប្រាស់ឧបករណ៍នានា ដូចជាប្រព័ន្ធឆ្លើយឆ្លងតាមវីដេអូ ឬសវនាការអសាធារណៈ គួរត្រូវបានពិចារណា។ ប្រសិនបើសាលដីកា ឬការកាត់ទោសត្រូវប្រកាសជាសាធារណៈ អត្តសញ្ញាណរបស់កុមារមិនគួរបង្ហាញឡើយ។[176] ជាចុងក្រោយ រាល់ឯកសារពាក់ព័ន្ធនឹងកុមារគួរត្រូវបានរក្សាទុកជាការសម្ងាត់ជាទីបំផុត និងអសារណៈចំពោះភាគីទីបីលើកលែងតែអ្នកទាំងនោះមានពាក់ព័ន្ធដោយផ្ទាល់ក្នុងការស៊ើបសង្កេតនិងការវិនិច្ឆ័យទោសលើសំណុំរឿង។[177] ចំណុចនេះគួរត្រូវបានធានា បើទោះបីជាកុមារឈានចូលអាយុ ១៨ ឆ្នាំក៏ដោយ។[178]

### *តួលេខទី ១៨៖ ការការពារឯកជនភាពរបស់អនីតិជន*[179]




ពុំមានវិធានការណាមួយដែលត្រូវបានអនុវត្តដើម្បីការពារឯកជនភាពរបស់អនីតិជន ដែលបង្ហាញខ្លួននៅពេលសវនាការនៅអំឡុងពេលធ្វើរបាយការណ៍នេះឡើយ។ លើសពីនេះទៅទៀត សវនាការទាំងអស់នេះគឺបើកឱ្យសាធារណជនចូលរួម។ ចំណុចនេះគឺជាបញ្ហាចម្បង ជាពិសេសដែលនាំឱ្យមានចម្ងល់ចំពោះសិទ្ធិឯកជនភាពរបស់អនីតិជននៅអំឡុងពេលសវនាការព្រហ្មទណ្ឌត្រូវបានពិភាក្សាជាមួយនឹងសាលាឧទ្ធរណ៍នៅខែសីហា ឆ្នាំ២០១៩ ហើយសាលាឧទ្ធរណ៍បានបដិសេធរបកគំហើញអវិជ្ជមាននៃរបាយការណ៍ពាក់ព័ន្ធនឹងសិទ្ធិអនីតិជន។ ដើម្បីគាំទ្រដល់ចំណុចនេះ សាលាឧទ្ធរណ៍បានលើកឡើងអំពីការដំឡើងបច្ចេកវិទ្យាប្រព័ន្ធឆ្លងឆ្លើយតាមវីដេអូនាពេលថ្មីៗ ដែលបានឧបត្ថម្ភដោយអង្គការយូនីសេហ្វ ដើម្បីការពារឯកជនភាពរបស់អនីតិជនឱ្យកាន់តែល្អប្រសើរ។ សាលាឧទ្ធរណ៍ក៏បានស្នើឱ្យ ម.ស.ម.ក កត់ត្រា និងរាយការណ៍អំពីចៅក្រមដែលមិនបានគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសំណុំរឿងអនីតិជន ព្រមទាំងសំណុំរឿងដែលឯកជនភាពមិនត្រូវបានគោរពពេញលេញនៅអំឡុងពេលសវនាការជូនប្រធានសាលាឧទ្ធរណ៍បានជ្រាបផងដែរ។ លើសពីនេះទៅទៀត សាលាឧទ្ធរណ៍បានលើកឡើងអំពីភាពជាក់ស្តែង ដែលការអនុវត្តកម្មវិធីបង្វែរសម្រាប់ជនល្មើសជាអនីតិជន ដែលតម្រូវឱ្យមានទោសជំនួសសម្រាប់ការផ្តន្ទាទោសជាផ្លូវការ គឺមិនអាចអនុវត្ត

[175] អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[176] អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[177] អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[178] អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧០។

[179] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទជាអនីតិជន (១៥ នាក់) ដែលបានពាក់ព័ន្ធនឹងសំណុំរឿង ១៥ ដែលបានសង្កេតការណ៍។

បានទេ ដោយសារតែកង្វះយន្តការគាំទ្រកម្មវិធីនេះ[180]។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងបែបនេះក៏ដោយ សិទ្ធិរបស់អនីតិជននៅតែប្រឈមនឹងការរំលោភបំពានជាប្រចាំនៅសាលាឧទ្ធរណ៍។

ផ្អែកលើលទ្ធផលរកឃើញពីការសង្កេតការណ៍ សាលាឧទ្ធរណ៍បានលើកឡើងនៅអំឡុងពេលកិច្ចប្រជុំពិគ្រោះយោបល់អំពីរបកគំហើញនៃរបាយការណ៍នេះថា នៅក្នុងករណីដែលមានជនជាប់ចោទ ជនរងគ្រោះ ឬសាក្សីជាអនីតិជន សវនាការត្រូវបានធ្វើឡើងដោយមានរនាំងបាំង និងតាមវីដេអូឆ្លងឆ្លើយ។ សាលាឧទ្ធរណ៍បានលើកឡើងថាទាំងសវនាការនិងការប្រកាសសាលដីកាសម្រាប់សំណុំរឿងអនីតិជនត្រូវបានធ្វើឡើងជាអសាធារណៈ ទោះបីជាសំណុំរឿងអនីតិជនមានជនជាប់ចោទជាមនុស្សពេញវ័យក៏ដោយ។[181]

[180] នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ម.ស.ម.ក បានជួបប្រជុំមួយជាមួយប្រធាន អនុប្រធានទាំងអស់ អគ្គព្រះរាជអាជ្ញា តំណាងចៅក្រមម្នាក់ និងអគ្គលេខាធិការរដ្ឋបាលនៃសាលាឧទ្ធរណ៍ដើម្បីពិភាក្សាអំពីរបកគំហើញនៃរបាយការណ៍ឆ្នាំ២០១៧/២០១៨។

[181] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយនឹងប្រធាន អនុប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ និងអគ្គលេខាធិការ និងអគ្គលេខាធិការរងនៃសាលាឧទ្ធរណ៍ភ្នំពេញដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍ឆ្នាំ២០១៨/២០១៩។

# ៥. ឆ្នាំ២០១៤-២០២០៖ ការវិវឌ្ឍនៃការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

ផ្នែកនេះលើកឡើងអំពីនិន្នាការសំខាន់ៗ ពាក់ព័ន្ធនឹងការគោរពតាមយ៉ាងខ្ជាប់ខ្ជួនទៅនឹងបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិដោយសាលាឧទ្ធរណ៍នៅអំឡុងពេលធ្វើរបាយការណ៍ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២០។[182]

## ៥.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួនត្រូវបានគោរពយ៉ាងស៊ីសង្វាក់ដោយសាលាឧទ្ធរណ៍ចាប់តាំងពីឆ្នាំ២០១៤ មក។

**សិទ្ធិក្នុងការជួបពិភាក្សាជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី៖** សិទ្ធិក្នុងការជួបពិភាក្សាជាមួយមេធាវីមុនពេលជំនុំជម្រះ និងទិដ្ឋភាពនៃសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ដែល ម.ស.ម.ក បានសង្កេតការណ៍ត្រូវបានគោរពយ៉ាងស៊ីសង្វាក់ចាប់តាំងពីឆ្នាំ២០១៤ មក។ ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម នៅក្នុងសំណុំរឿងជាង ៩៣,៧% ដែល ម.ស.ម.ក បានសង្កេតការណ៍ ពុំមានការលើកឡើងថាមេធាវីរបស់ជនជាប់ចោទត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៅសាលាឧទ្ធរណ៍ឡើយ។[183] ពុំមានសំណុំរឿងណាមួយដែលបានសង្កេតការណ៍ចាប់តាំងពីឆ្នាំ ២០១៤ មក មានបញ្ហាពាក់ព័ន្ធនឹងពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីត្រូវបានលើកឡើងដោយមេធាវីការពារឡើយ។[184]

---

182 សូមកត់សម្គាល់ថា គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានផ្អាកជាបណ្តោះអាសន្នចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ដោយសារកង្វះថវិកា។ ជាលទ្ធផលគឺពុំមានទិន្នន័យសម្រាប់រយៈពេលនោះទេ។

183 ទិន្នន័យនេះផ្អែកលើចំនួនសរុបនៃជនជាប់ចោទដែលមានមេធាវីតំណាង៖ ១៤៩ សំណុំរឿង (ក្នុងចំណោម ១៦១ សំណុំរឿង) ឆ្នាំ២០១៤/២០១៥, ៤៤៣ សំណុំរឿងក្នុងចំណោម ៥៦២ សំណុំរឿងនៅឆ្នាំ ២០១៦/២០១៧, ២៤១ សំណុំរឿងក្នុងចំណោម ៣១៥ សំណុំរឿងនៅឆ្នាំ ២០១៧/២០១៨ និង ២៦២ សំណុំរឿងក្នុងចំណោម ៣៥២ សំណុំរឿងនៅឆ្នាំ២០១៨/២០១៩។

184 ទិន្នន័យនេះផ្អែកលើសំណុំរឿងដែលបានសង្កេតការណ៍ ដែលជនជាប់ចោទមានវត្តមាន និង/ឬមានមេធាវីតំណាង៖ ១៥៩ សំណុំរឿង (ក្នុងចំណោម ១៦១ សំណុំរឿង) នៅឆ្នាំ២០១៤/២០១៥, ៤៤៤ សំណុំរឿង (ក្នុងចំណោម ៥៦២ សំណុំរឿង) នៅឆ្នាំ២០១៦/២០១៧, ២៤០ សំណុំរឿង(ក្នុងចំណោម ៣១៥ សំណុំរឿង) នៅឆ្នាំ២០១៧/២០១៨ និង ២៦២ សំណុំរឿង (ក្នុងចំណោម ៣៥២ សំណុំរឿង) នៅឆ្នាំ ២០១៨/២០១៩។

*តួលេខទី ១៩៖ ការវិភាគសិទ្ធិក្នុងការជួបពិភាក្សាជាមួយមេធាវីមុនពេលជំនុំជម្រះ (ឆ្នាំ២០១៤-២០២០)*[185]




**សិទ្ធិទទួលបានសាលដីកាជាសាធារណៈ៖** ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២០ សាលដីកាត្រូវបានប្រកាសជាសាធារណៈសម្រាប់សំណុំរឿងដែលបានសង្កេតការណ៍ដែលព័ត៌មានអាចរកបានអំពីចំណុចនោះ។[186]

**ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ៖** គោលការណ៍នៃការអនុវត្តអនុ ភាពប្រតិសកម្មនៃច្បាប់ក៏ត្រូវបានគោរពយ៉ាងស៊ីសង្វាក់។ នៅក្នុងសំណុំទាំងអស់ដែលម.ស.ម.កបានសង្កេតការណ៍ចាប់តាំងពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២០ ច្បាប់ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ត្រូវបានចូលជាធរមាននៅថ្ងៃដែលបទល្មើសត្រូវបានចោទប្រកាន់។[187]

**ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល៖** គោលការណ៍នៃការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល (*ne bis in idem*) ត្រូវបានគោរពតាមយ៉ាងស៊ីសង្វាក់ចាប់តាំងពីឆ្នាំ២០១៤ មក។ ជាក់ស្ដែង

185 ទិន្នន័យនេះផ្អែកលើចំនួនសរុបនៃជនជាប់ចោទដែលមានមេធាវីតំណាង៖ ១៤៩ សំណុំរឿង (ក្នុងចំណោម ១៦១ សំណុំរឿង) នៅឆ្នាំ២០១៤/២០១៥, ៤៨៣ សំណុំរឿង (ក្នុងចំណោម ៥៦២ សំណុំរឿង) នៅឆ្នាំ២០១៦/២០១៧, ២៤១ សំណុំរឿង (ក្នុងចំណោម ៣១៥ សំណុំរឿង) នៅឆ្នាំ២០១៧/២០១៨, ២៦២ សំណុំរឿង (ក្នុងចំណោម ៣៥២ សំណុំរឿង) នៅឆ្នាំ២០១៨/២០១៩ និង ១៨៣ សំណុំរឿង (ក្នុងចំណោម ២០៣ សំណុំរឿង) នៅឆ្នាំ២០១៩/២០២០។

186 ទិន្នន័យនេះគឺផ្អែកលើគ្រប់សំណុំរឿងទាំងអស់ដែលគ្របដណ្ដប់ក្នុងឆ្នាំ២០១៤/២០១៥, ២៥២ សំណុំរឿង (ក្នុងចំណោម ៣៤១ សំណុំរឿង) ដែលបានសង្កេតការណ៍ក្នុងឆ្នាំ២០១៦/២០១៧, ៩៥ សំណុំរឿង (ក្នុងចំណោម ២១៣ សំណុំរឿង) ដែលបានសង្កេតការណ៍ក្នុងឆ្នាំ២០១៧/២០១៨ និង ៩៩ សំណុំរឿង (ក្នុងចំណោម ២៣៩ សំណុំរឿង) ត្រូវបានសង្កេតការណ៍ក្នុងឆ្នាំ២០១៨/២០១៩។

187 ទិន្នន័យនេះផ្អែកលើជនជាប់ចោទចំនួន ១៦១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥, ជនជាប់ចោទចំនួន ៥៥៨ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទចំនួន ៣១៥ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍ក្នុងឆ្នាំ២០១៧/២០១៨ ហើយជនជាប់ចោទចំនួន ៣៥២ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតការណ៍ក្នុងឆ្នាំ២០១៨/២០១៩។

លើកលែងតែជនជាប់ចោទ ២ នាក់ ពុំមានការលើកឡើងថា ជនជាប់ចោទនៅក្នុងសំណុំរឿងដែលបានសង្កេតការណ៍ចាប់តាំងពីឆ្នាំ២០១៤-២០២០ ត្រូវបានជំនុំជម្រះ និងកាត់ទោសលើបទល្មើសដែលបានចោទប្រកាន់ពីមុនមកទេ។[188]

## ៥.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនទាន់ត្រូវបានគោរពពេញលេញ

សិទ្ធិសំខាន់ៗមួយចំនួនមិនទាន់ត្រូវបានគោរពពេញលេញចាប់តាំងពីឆ្នាំ២០១៤ មក។ ចំណុចនេះបង្កឱ្យមានក្តីបារម្ភជាខ្លាំង ជាពិសេសបញ្ហានានាដែលបានលើកឡើងដល់អាជ្ញាធរជាច្រើនលើកមកហើយ។

### *៥.២.១ បម្រែបម្រួលៈ ពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពទៅជាមិនបានគោរពពេញលេញ*

**សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសៈ** បន្ទាប់ពីត្រូវបានចាត់ចំណាត់ថ្នាក់ថាត្រូវបានគោរពសម្រាប់អំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៤/២០១៥ សិទ្ធិនេះបានប្តូរចំណាត់ថ្នាក់ទៅជាមិនត្រូវបានគោរពពេញលេញវិញ។ ទោះបីជាពុំមានសំណុំរឿងណាមួយដែលត្រូវបានសង្កេតការណ៍ចាប់តាំងពីឆ្នាំ២០១៤/២០១៥ មក ដែលចៅក្រមបានលើកឡើងពីពិរុទ្ធភាពរបស់ជនជាប់ចោទមុនពេលចេញសាលដីកា ឬជនជាប់ចោទត្រូវបានដាក់ខ្នោះនៅពេលសវនាការក៏ដោយ [189] ក៏នៅតែមានកត្តាមួយចំនួនដែលបានបង្ហាញថា សិទ្ធិនេះត្រូវបានចាត់ទុកថាមិនបានគោរពពេញលេញនៅឡើយ។ ជាក់ស្តែង នៅក្នុងសំណុំរឿងភាគច្រើនដែលបានសង្កេតការណ៍ចាប់តាំងពីឆ្នាំ ២០១៤ មក ចៅក្រមមិនបានប្រាប់ ឬពន្យល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេនោះទេ។ គួរកត់សម្គាល់ផងដែរថា នៅអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ ការគោរពសិទ្ធិនេះពីសំណាក់សាលាឧទ្ធរណ៍មានភាពល្អប្រសើរគួរកត់សម្គាល់។

---

188 ទិន្នន័យនេះផ្អែកលើសំណុំរឿងដែលបានសង្កេតការណ៍ ដែលជនជាប់ចោទមានវត្តមាន និង/ឬមានមេធាវីតំណាងៈ ១៥៩ សំណុំរឿង (ក្នុងចំណោម ១៦១ សំណុំរឿង) នៅឆ្នាំ២០១៤/២០១៥, ៤៤៤ សំណុំរឿង (ក្នុងចំណោម ៥៦២ សំណុំរឿង) នៅឆ្នាំ២០១៦/២០១៧, ២៤០ សំណុំរឿង (ក្នុងចំណោម ៣១៥ សំណុំរឿង) នៅឆ្នាំ២០១៧/២០១៨ និង ២៦២ សំណុំរឿង (ក្នុងចំណោម ៣៥២ សំណុំរឿង) នៅឆ្នាំ២០១៨/២០១៩។ មានការបង្ហាញថា ជនជាប់ចោទម្នាក់ត្រូវបានជំនុំជម្រះ និងកាត់ទោសចំពោះបទចោទប្រកាន់ពីមុននៅឆ្នាំ២០១៦/២០១៧ និង ឆ្នាំ២០១៧/២០១៨។

189 ទិន្នន័យនេះផ្អែកលើចំនួនសរុបនៃជនជាប់ចោទដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងដែលបានសង្កេតការណ៍នៅអំឡុងពេលធ្វើរបាយការណ៍ៈ ជនជាប់ចោទចំនួន ១៦១ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥, ជនជាប់ចោទចំនួន ៥៥៨ នាក់ ពាក់ព័ន្ធនៅក្នុងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទចំនួន ៣១៥ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៧/២០១៨ និងជនជាប់ចោទចំនួន ៣៥២ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៨/២០១៩។

*តួលេខទី ២០៖ ការប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀម (ឆ្នាំ២០១៤-២០២០)*[190]




ជាក់ស្តែង ចំនួនជនជាប់ចោទដែលបង្ហាញខ្លួននៅចំពោះមុខតុលាការនៅក្នុងឯកសណ្ឋានអ្នកទោសបានកើនឡើងចាប់តាំងពីឆ្នាំ២០១៤ បានបញ្ជាក់បន្ថែមទៀតថា សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសមិនត្រូវបានគោរពពេញលេញនៅឡើយ។ ដូចដែលបានបង្ហាញនៅក្នុងតួលេខខាងក្រោម ទិន្នន័យនេះបង្ហាញថាខណៈដែលមានជនជាប់ចោទចំនួន ៥,៤% ប៉ុណ្ណោះដែលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានអ្នកទោសនៅឆ្នាំ២០១៤/២០១៥ ប៉ុន្តែនៅឆ្នាំ២០១៨/២០១៩ មានចំនួន ២៨,២%។ តួលេខនេះបង្ហាញថា មានភាពល្អប្រសើរតិចតួចប៉ុណ្ណោះបើធៀបនឹងឆ្នាំ២០១៨/២០១៩ ដែលករណីនេះមានជនជាប់ចោទចំនួន ៣០,៣%។

[190] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥, សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៦/២០១៧, សំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៧/២០១៨, សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៨/២០១៩ និងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៩/២០២០។

*តួលេខទី ២១៖ ភាគរយនៃជនជាប់ចោទដែលបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានអ្នកទោស (២០១៤-២០២០)*[191]




**សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់៖** ទោះបីជាសិទ្ធិនេះត្រូវបានចាត់ទុកថាបានគោរពនៅអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៤/២០១៥ និងឆ្នាំ២០១៦/២០១៧ ប៉ុន្តែបន្ទាប់ពីពេលនោះមក សិទ្ធិនេះត្រូវបានចាត់ទុកថាមិនត្រូវបានគោរពពេញលេញនៅឡើយ។ យោងតាមតួលេខដែលបានបង្ហាញខាងក្រោម មានការធ្លាក់ចុះជាបន្តបន្ទាប់នូវភាគរយនៃសំណុំរឿង ដែលចៅក្រមបានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់លើជនជាប់ចោទ កាលបរិច្ឆេទនៃបទល្មើស ឬភាគីពាក់ព័ន្ធ។ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់ផងដែរចំពោះភាគរយនៃសំណុំរឿង ដែលចៅក្រមមិនបានប្រាប់អំពីច្បាប់ពាក់ព័ន្ធ ឬទីកន្លែងប្រព្រឹត្តបទល្មើស។

---

191 ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍ មានវត្តមាននៅពេលសវនាការ និងជាប់ពន្ធនាគារ៖ ជនជាប់ចោទចំនួន ១២៩ នាក់ ក្នុងចំណោម ១៦១ នាក់ នៅឆ្នាំ២០១៤/២០១៥, ជនជាប់ចោទចំនួន ៣៥៦ នាក់ ក្នុងចំណោម ៥៥៨ នាក់ នៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទចំនួន ២៤៩ នាក់ ក្នុងចំណោម ៣១៥ នាក់ នៅឆ្នាំ២០១៧/២០១៨ និងជនជាប់ចោទចំនួន ២៥៤ នាក់ ក្នុងចំណោម ៣៥២ នាក់ នៅឆ្នាំ២០១៨/២០១៩ និង ជនជាប់ចោទចំនួន ២២១ នាក់ ក្នុងចំណោម ២៥៥ នាក់ នៅឆ្នាំ២០១៩/២០២០។

## *តួលេខទី ២២៖ ការវិវឌ្ឍនៃសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ (ឆ្នាំ២០១៤-២០២០)*[192]




---

192 ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥ (លើកលែងតួលេខទី ២៣.ក ដែលទិន្នន័យផ្អែកលើសំណុំរឿងចំនួន ១០៩ ដែលបានដឹងព័ត៌មាន) សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៦/២០១៧ សំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៧/២០១៨, សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៨/២០១៩ និងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៩/២០២០។




**សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ៖** ទោះបីជាត្រូវបានចាត់ចំណាត់ថ្នាក់ថាត្រូវបានគោរពនៅអំឡុងឆ្នាំ២០១៤/២០១៥ ចាប់តាំងពីពេលនោះមក សិទ្ធិនេះត្រូវបានចាត់ចំណាត់ថ្នាក់ថាមិនត្រូវបានគោរពពេញលេញ។ ដូចមានបង្ហាញនៅក្នុងតួលេខខាងក្រោម ភាគរយនៃជនជាប់ចោទមានមេធាវីតំណាងបានធ្លាក់ចុះថេរចាប់តាំងពីឆ្នាំ២០១៤/២០១៥។

*តួលេខទី ២៣៖ ការវិវឌ្ឍនៃសិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ (ឆ្នាំ២០១៤-២០២០)*[193]




លើសពីនេះទៅទៀត ស្ទើរតែពុំមានសំណុំរឿងណាមួយ ដែលជនជាប់ចោទមានវត្តមាននៅពេលសវនាការ ដែលចៅក្រមបានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវី ឬការការពារខ្លួន។

---

193 ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (២៥៥ នាក់) ដែលបានពាក់ព័ន្ធនឹងសំណុំរឿង ២០៣ ដែលបានសង្កេតការណ៍។

*តួលេខទី ២៤៖ ការប្រាប់ និងពន្យល់អំពីសិទ្ធិមានមេធាវី ឬការការពារខ្លួនឯង (ឆ្នាំ២០១៤-២០២០)*[194]




**សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព៖** សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាពត្រូវបានចាត់ចំណាត់ថ្នាក់ថាត្រូវបានគោរពនៅអំឡុងពេលធ្វើបោយការណ៍ឆ្នាំ២០១៧/២០១៨។ ដូចដែលបានបង្ហាញនៅក្នុងផ្នែក ៤.១ ខាងលើ ខណៈដែលទំនោរនៅឆ្នាំ២០១៨/២០១៩ បង្ហាញថាមានការធ្លាក់ចុះតិចតួច បើធៀបនឹងអំឡុងពេលធ្វើបោយការណ៍ឆ្នាំ២០១៧/២០១៨ ទិន្នន័យដែលបានប្រមូលនៅអំឡុងពេលធ្វើបោយការណ៍ឆ្នាំ២០១៩/២០២០ បង្ហាញថា ចំនួនជនជាប់ចោទដែលមានបានអះអាងថា អំពើហិង្សា ឬទារុណកម្មត្រូវបានប្រើប្រាស់មកលើពួកគេមានការកើនឡើងជាថ្មីម្តងទៀត។ នេះ គួបផ្សំជាមួយនឹងការណ៍ដែលថាការចោទប្រកាន់ថាមានការគំរាមកំហែង ឬអំពើហិង្សាត្រូវបានលើកឡើងជាប់ជាប្រចាំចាប់តាំងពីឆ្នាំ២០១៤ មក ដែលជាហេតុផលបញ្ជាក់ថាសិទ្ធិនេះមិនត្រូវបានគោរពពេញលេញនៅឡើយ។

194 ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥, សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៦/២០១៧, សំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៧/២០១៨, សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៨/២០១៩ និងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៩/២០២០។

*តួលេខទី ២៥៖ ការវិវឌ្ឍនៃសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព (ឆ្នាំ២០១៤-២០២០)*




## ៥.២.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញ ចាប់តាំងពីឆ្នាំ២០១៤ មក

**សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ៖** បញ្ជាក់ថានៅចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០២០ មានតែសំណុំរឿងចំនួនមួយប៉ុណ្ណោះ ដែលសាធារណជន ឬអ្នកសារព័ត៌មានត្រូវបានហាមឃាត់ក្នុងការចូល ឬបណ្ដេញចេញពីបន្ទប់សវនាការ។ ប៉ុន្តែសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈត្រូវបានចាត់ចំណាត់ថ្នាក់ថាមិនត្រូវបានគោរពតាមពេញលេញនៅឡើយចាប់តាំងពីឆ្នាំ២០១៦ មក នៅពេលដែល ម.ស.ម.ក ចាប់ផ្ដើមជូនដំណឹងពីការសង្កេតការណ៍ដោយសារតែនៅក្នុងសំណុំរឿងតែចំនួន ៣១ ប៉ុណ្ណោះ ដែលតំណាងដោយចំនួន ៣,១% នៃសំណុំរឿងសរុបដែលបានសង្កេតការណ៍មានការជូនដំណឹងអំពីសវនាការបិទនៅលើក្ដារខៀនព័ត៌មានខាងក្រៅបន្ទប់សវនាការ។[195]

**សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ៖** ការគោរពសិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុនៅតែមានបញ្ហានៅគ្រប់អំឡុងពេលធ្វើរបាយការណ៍ទាំងអស់។ ទោះបីជាមានភាពល្អប្រសើរគួរឱ្យកត់សម្គាល់នៅឆ្នាំ២០១៨/២០១៩ យ៉ាងណាក្ដី នៅពេលសេចក្ដីសម្រេចពុំមានសំអាងហេតុគ្រប់គ្រាន់មានតែចំនួន ៤៧,៥% នៃសំណុំរឿង បើធៀបទៅនឹងចំនួន ៨៧.៤% នៅឆ្នាំ២០១៧/២០១៨ ភាពល្អប្រសើរនេះមានរយៈពេលខ្លីប៉ុណ្ណោះ ដោយសារតែនៅអំឡុងពេលធ្វើរបាយការណ៍នេះបានឃើញថាសេចក្ដីសម្រេចចំនួន ៦៤,៧% ពុំមានសំអាងហេតុគ្រប់គ្រាន់។

**សិទ្ធិបង្ហាញភស្តុតាង៖** ចាប់តាំងពីឆ្នាំ២០១៤ ម.ស.ម.ក បានលើកកង្វល់អំពីគុណភាពនៃភស្តុតាងដែលបានបង្ហាញនៅពេលសវនាការ។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីឆ្នាំ២០១៦ មក នៅក្នុងសំណុំរឿងតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានបង្ហាញថាភាគីមិនត្រូវបានផ្ដល់ឱកាសដើម្បីកោះហៅសាក្សីដែលនេះគឺជារបបគំហើញបែបវិជ្ជមានតែ ម.ស.ម.ក ក៏បានកត់សម្គាល់ឃើញថា សំណុំរឿងភាគច្រើន ដែលសាក្សីត្រូវបានកោះហៅ ពួកគេមានវត្តមាននៅក្នុងបន្ទប់សវនាការនៅមុនពេលពួកគេត្រូវបានសាកសួរ។ ការអនុវត្តបែបនេះអាចនាំឱ្យសក្ខីកម្មរបស់សាក្សីទទួលរងឥទ្ធិពលដោយសារការស្ដាប់សក្ខីកម្មរបស់សាក្សីផ្សេងទៀត។

[195] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥, សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៦/២០១៧, សំណុំរឿងចំនួន ២១៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៧/២០១៨, សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៨/២០១៩ និងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតការណ៍នៅឆ្នាំ២០១៩/២០២០។

**សិទ្ធិរបស់អនីតិជន៖** ចាប់តាំងពីឆ្នាំ២០១៤ មក សិទ្ធិរបស់ជនជាប់ចោទជាអនីតិជន ដែលគួរតែទទួលបានកិច្ចការពារជាពិសេសស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិកម្ពុជា ជាញឹកញាប់ ត្រូវបានព្រងើយកន្តើយ៖ អនីតិជនភាគច្រើនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ហើយនៅក្នុងសំណុំរឿងភាគច្រើនមិនមានវិធានការណាមួយដើម្បីការពារឯកជនភាពរបស់អនីតិជនឡើយ។ លើសពីនេះទៅទៀត មិនមានសំណុំរឿងណាមួយ ដែលបានសង្កេតការណ៍មានការបង្ហាញថា ចៅក្រមពិចារណាលើការកាត់ទោសមិនមែនទោសពន្ធនាគារឡើយ។[196]

*តួលេខទី ២៦៖ ភាគរយនៃជនជាប់ចោទជាអនីតិជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន(ឆ្នាំ២០១៤-២០២០)*[197]




*តួលេខទី ២៧៖ ភាគរយនៃសំណុំរឿងដែលមានវិធានការការពារឯកជនភាពរបស់អនីតិជន (ឆ្នាំ២០១៤-២០២០)*[198]




---

[196] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទជាអនីតិជនដែលសាលដីកាត្រូវបានស្តាប់ ឬដឹង៖ អនីតិជនចំនួន ១១ នាក់ នៅឆ្នាំ២០១៤/២០១៥, ចំនួន ២៨ នាក់ នៅឆ្នាំ២០១៦/២០១៧, ចំនួន បីនាក់ នៅឆ្នាំ២០១៧/២០១៨ និងចំនួនប្រាំមួយ នាក់ នៅឆ្នាំ២០១៨/២០១៩។

[197] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទជាអនីតិជនចំនួន ១១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥, ជនជាប់ចោទជាអនីតិជនចំនួន ៣៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទជាអនីតិជនចំនួន ៩ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៧/២០១៨, ជនជាប់ចោទអនីតិជនចំនួន ២២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍ឆ្នាំ២០១៨/២០១៩ និងជនជាប់ចោទជាអនីតិជនចំនួន ១៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៩/២០២០។

[198] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទជាអនីតិជនចំនួន ១១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៤/២០១៥, ជនជាប់ចោទជាអនីតិជនចំនួ ៣៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទជាអនីតិជនចំនួន ៩ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៧/២០១៨, ជនជាប់ចោទជាអនីតិជនចំនួន ១៨

# ៦.សេចក្តីសន្និដ្ឋាន

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួនត្រូវបានធានានៅសាលាឧទ្ធរណ៍ រួមមានសិទ្ធិក្នុងការជួបពិភាក្សាជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ។ លើសពីនេះ សាលាឧទ្ធរណ៍បានលើកកម្ពស់យ៉ាងស៊ីសង្វាក់នូវការការពារប្រឆាំងនឹងការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល និងការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ផងដែរ។

ប៉ុន្តែ ការសង្កេតការណ៍នេះក៏បានរកឃើញពីកង្វះការអនុលោមតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានមួយចំនួនផងដែរ។ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាពមិនទាន់ត្រូវបានគោរពពេញលេញនោះទេនៅអំឡុងពេលធ្វើរបាយការណ៍ ដោយមានជនជាប់ចោទចំនួន ១៧ នាក់ (ក្នុងចំណោមជនជាប់ចោទចំនួន ២៥៥នាក់) ដោយបានលើកឡើងថាមានការប្រើអំពើហិង្សា ឬទារុណកម្មមកលើពួកគេនៅអំឡុងពេលដំណើរការស៊ើបអង្កេត ដើម្បីឱ្យពួកគេសារភាពថាបានប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់។ អ្វីដែលគួរឱ្យកាន់តែព្រួយបារម្ភទៀតនោះគឺទោះបីជាមានការលើកឡើងបែបនេះក្តី ចៅក្រមនៅតែកម្កល់សាលក្រមសម្រេចថាមានពិរុទ្ធភាពទុកជាបានការដដែល។ បើនិយាយអំពីសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិនេះមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ ដោយសារមានតែសវនាការចំនួន ៣១ ប៉ុណ្ណោះក្នុងចំណោមសវនាការដែល ម.ស.ម.ក បានសង្កេតការណ៍ (ក្នុងចំណោមសវនាការចំនួន ២០៣) បានបិទផ្សាយការជូនដំណឹងអំពីសវនាការនៅលើក្តារខៀនក្រៅបន្ទប់សវនាការ។ ជាងនេះទៅទៀត សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅតែជាសិទ្ធិមួយ ដែលមិនទាន់ត្រូវបានគោរពពេញលេញ ដោយក្នុងនោះ ៧៨,៣% នៃសំណុំរឿងដែលបានសង្កេតការណ៍ ដែលចៅក្រមបានប្រាប់អំពីការចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទ។ ស្រដៀងនឹងឆ្នាំមុន សិទ្ធិមានមេធាវីមិនទាន់ត្រូវបានគោរពពេញលេញនោះទេ៖ ចំនួន ២៨,២% នៃជនជាប់ចោទនៅក្នុងសំណុំរឿង ដែល ម.ស.ម.ក បានសង្កេតការណ៍ ពុំមានមេធាវីតំណាងឡើយ។ លើសពីនេះទៅទៀត ចំនួន ៧,៤% នៃសំណុំរឿងទាំងអស់ ចៅក្រមមិនបានប្រាប់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីរបស់ពួកគេឡើយ ដែលនេះគឺជានិន្នាការមួយគួរព្រួយបារម្ភ។

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសគឺជាសិទ្ធិមួយទៀត ដែលនៅតែមិនទាន់ត្រូវបានគោរពពេញលេញ ទោះបីជាចំនួនជនជាប់ចោទ ដែលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតបានថយចុះថេរចាប់តាំងពីអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៧/២០១៨ មកក្តី។ ជាចុងក្រោយ សិទ្ធិរបស់ជនជាប់ចោទជាអនីតិជនដែលត្រូវបានការពារជាពិសេសតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិ ជាញឹកញាប់មិនទទួលបានការគាំពារពេញលេញទេ៖ ពុំមានវិធានការដាក់លាក់ណាមួយត្រូវបានដាក់ចេញដើម្បីការពារសិទ្ធិរបស់អនីតិជនឡើយ ជាពិសេសឯកជនភាពរបស់ពួកគេ និងពុំមានសូចនាករ ដែលបង្ហាញថា ចៅក្រមពិចារណាដាក់ទោសមិនមែនជាទោសជាប់ពន្ធនាគារផងដែរ។

ជាការកត់សម្គាល់ថា ដោយសារតែសិទ្ធិមួយចំនួនត្រូវបានការពារយ៉ាងស៊ីសង្វាក់ចាប់តាំងពីឆ្នាំ២០១៤ ក្តី តែនៅមានសិទ្ធិជាច្រើនផ្សេងទៀតនៅតែមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

---

នាក់ (ក្នុងចំណោម ២២ នាក់) ដែលមានវត្តមាននៅពេលសវនាការនៅឆ្នាំ២០១៨/២០១៩ និងជនជាប់ចោទជាអនីតិជនចំនួន ១៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៩/២០២០។

- សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ
- សិទ្ធិបង្ហាញភស្តុតាង និង
- សិទ្ធិរបស់អនីតិជន។

នៅពេលធ្វើការប្រៀបធៀបរបកគំហើញនៃរបាយការណ៍បច្ចុប្បន្នទៅនឹងរបាយការណ៍កាលពីឆ្នាំមុន របកគំហើញភាគច្រើនមានលក្ខណៈប្រហាក់ប្រហែលគ្នា ក្នុងន័យដែលសិទ្ធិមួយចំនួនត្រូវបានគោរព និងសិទ្ធិមួយចំនួនទៀតមិនទាន់ត្រូវបានគោរពពេញលេញ។

ទោះជាយ៉ាងនេះក្តី មានចំណុចមួយបានលេចចេញឡើង គឺសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាព ដែល ម.ស.ម.ក បានរកឃើញថាត្រូវបានការពារនៅឆ្នាំ២០១៧/២០១៨ ត្រូវបានប្តូរទៅផ្នែក "មិនត្រូវបានគោរពពេញលេញ" នៅឆ្នាំ ២០១៨/២០១៩ ហើយនៅតែស្ថិតនៅក្នុងផ្នែកនេះដដែលសម្រាប់អំឡុងពេលឆ្នាំ២០១៩/២០២០ ដោយហេតុថាការការពារសិទ្ធិនេះត្រូវបានសង្កេតឃើញថាមានការថយចុះ។ ការលើកឡើងពីការប្រើប្រាស់អំពើហិង្សា ឬការធ្វើទារុណកម្មត្រូវតែមានការស៊ើបអង្កេតជាបន្ទាន់និងឱ្យបានហ្មត់ចត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ភស្តុតាងនេះបង្ហាញថា ទោះបីជាមានភាពល្អប្រសើរនៅផ្នែកខ្លះក៏ដោយ ចាំបាច់ត្រូវតែមានវិធានការជាបន្ទាន់ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។ផ្នែកខាងក្រោមនេះគឺជាអនុសាសន៍សំខាន់ៗ ដើម្បីជួយរដ្ឋាភិបាល និងអាជ្ញាធរក្នុងការបន្តអនុវត្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន។

# ៧. អនុសាសន៍

ជាទូទៅ បញ្ហាភាគច្រើនដែលត្រូវបានគូសបញ្ជាក់ក្នុងរបាយការណ៍នេះអាចត្រូវបានដោះស្រាយបានតាមរយៈវិធានការងាយៗ ចំណាយអស់តិច និងអាចអនុវត្តបានយ៉ាងឆាប់រហ័ស។ ឧទាហរណ៍ ការកែលម្អការសម្របសម្រួលទាក់ទងការដឹកជញ្ជូនជនជាប់ចោទពីមណ្ឌលកែប្រែមកចូលរួមសវនាការ ការសុំឱ្យសាក្សីចាកចេញពីបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មក្នុងសវនាការ និងការតម្រូវឱ្យចៅក្រមពន្យល់ប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់គេជាដើម។ បញ្ហាមួយចំនួនទៀតនឹងអាចកែលម្អបានយ៉ាងងាយស្រួលតាមរយៈការបណ្តុះបណ្តាលចៅក្រម និងមេធាវីក្នុងការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាចុងក្រោយ ម.ស.ម.ក សូមស្វាគមន៍ចំពោះការបង្កើតសាលាឧទ្ធរណ៍តំបន់នៅខេត្តត្បូងឃ្មុំ បាត់ដំបង និងខេត្តព្រះសីហនុ ដែលបានបើកដំណើរការនៅឆ្នាំ២០២០ ព្រោះថាការបង្កើតសាលាឧទ្ធរណ៍បន្ថែមនេះនឹងដោះស្រាយបញ្ហាមួយចំនួនដែលបានលើកឡើងខាងលើ។ តាមរយៈការចាត់វិធានការបន្ទាន់ដើម្បីដោះស្រាយកង្វល់ទាំងអស់នេះ សាលាឧទ្ធរណ៍អាចបង្កើតយុត្តិសាស្ត្រដើរតួជាឧទាហរណ៍ដល់សាលាដំបូង ព្រមទាំងអាចជះឥទ្ធិពលជាវិជ្ជមានលើគុណភាពនៃការផ្តល់យុត្តិធម៌ជាទូទៅក្នុងប្រទេសកម្ពុជា និងអាចចូលរួមចំណែកគួរជាទីកត់សម្គាល់ដើម្បីពង្រឹងនីតិរដ្ឋ។

## ៧.១ អនុសាសន៍ទូទៅ

៧.១.១ ក្រសួងយុត្តិធម៌គួររៀបចំការប្រជុំជាប្រចាំស្តីពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បែបអនុវត្តជាក់ស្តែងជាមួយចៅក្រមសាលាឧទ្ធរណ៍ ផ្អែកតាមទស្សនាទានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្អែកលើបទដ្ឋានជាតិ និងអន្តរជាតិ។

៧.១.២ ក្រសួងយុត្តិធម៌គួរបង្កើតទម្រង់បទដ្ឋានមួយសម្រាប់ប្រើប្រាស់នៅក្នុងតុលាការទាំងអស់ ហើយផ្ញើទម្រង់នេះទៅតុលាការទាំងអស់ដើម្បីអនុវត្ត។ ព័ត៌មានដូចខាងក្រោមត្រូវបានបញ្ចូលដើម្បីធានាឱ្យបានថា របាយការណ៍សង្ខេបដែលអានដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះនោះជារបាយការណ៍ពេញលេញដូចជា៖

- បទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់ និងច្បាប់ពាក់ព័ន្ធ
- កាលបរិច្ឆេទ ពេលវេលា ទីកន្លែងនៃបទល្មើស និងភាគីដែលពាក់ព័ន្ធ
- សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលជនជាប់ចោទមានសិទ្ធិបានទទួលបាន ដូចមានចែងក្នុងទំព័រទី ២២ នៃរបាយការណ៍នេះ។

ជាពិសេស ទម្រង់បទដ្ឋាននៃសេចក្តីសម្រេចគួរតែរំឭកដល់ចៅក្រមអំពីសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសរបស់ជនជាប់ចោទ រហូតដល់សេចក្តីសម្រេចស្ថាពរ និងមិនអាចប្តឹងជំទាស់បាន និងបន្ទុកភស្តុតាងដែលត្រូវជាបន្ទុករបស់អយ្យការ។

៧.១.៣ ចៅក្រមគួរសួរទៅជនជាប់ចោទដោយផ្ទាល់ ថាតើពួកគេយល់អំពីបទចោទប្រកាន់ និងអំពីសិទ្ធិរបស់ខ្លួនដែរឬទេ។ ការខកខានក្នុងការអានព័ត៌មានខាងលើនៅពេលចាប់ផ្តើមការជំនុំជម្រះគួរមានមូលដ្ឋានប្តឹងតវ៉ានឹងសេចក្តីសម្រេចឱ្យមានពិរុទ្ធភាព។

## ៧.២ អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព

៧.២.១ សាលាឧទ្ធរណ៍ត្រូវតែធ្វើការស៊ើបអង្កេតភ្លាមៗ និងឱ្យបានគ្រប់ជ្រុងជ្រោយលើការអះអាងថាមានការបង្ខិតបង្ខំ ហិង្សា ឬទារុណកម្ម ដើម្បីទទួលបានការសារភាពអំពីទោសនៅមុនពេលចេញសេចក្តីសម្រេចរបស់ខ្លួន។

៧.២.២ សាលាឧទ្ធរណ៍ត្រូវតែធានាថា ប្រសិនបើមានការអះអាងថាមានការបង្ខិតបង្ខំ ហិង្សា ឬទារុណកម្ម ត្រូវបានបញ្ជាក់ឱ្យឃើញបន្ទាប់ពីមានការស៊ើបអង្កេត នោះរាល់ភស្តុតាង ឬការសារភាពដែលទទួលបានតាមវិធីសាស្ត្រនេះគឺមិនទទួលយកបាន ហើយដំណើរការសវនាការឡើងវិញនឹងត្រូវធ្វើឡើង ហើយត្រូវធានាការត្រៀមលក្ខណៈសមស្របសម្រាប់ជនរងគ្រោះ។

## ៧.៣ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

៧.៣.១ សាលាឧទ្ធរណ៍ និងក្រសួងយុត្តិធម៌គួរធានាថា កាលវិភាគសវនាការប្រចាំថ្ងៃទាំងអស់ត្រូវបានបិទផ្សាយនៅលើក្តារខៀនព័ត៌មានខាងក្រៅបន្ទប់សវនាការយ៉ាងហោចណាស់ឱ្យបាន ២៤ ម៉ោងមុនពេលសវនាការ ហើយបន្តធានាលទ្ធភាពចូលរួមរបស់សាធារណជនមកក្នុងបន្ទប់សវនាការបានទាំងអស់ លើកលែងតែក្នុងករណីពិសេស ដែលអាចរួមមានសំណុំរឿងអនីតិជន។ ពេលដែលព័ត៌មានទាំងអស់នេះត្រូវបានបិទផ្សាយនៅលើក្តារខៀនព័ត៌មាន ឈ្មោះរបស់អនីតិជនមិនគួរត្រូវបានសរសេរចេញមកឡើយ ហើយគួរតែហៅអនីតិជនដោយប្រើអក្សរដើមនៃឈ្មោះដើម្បីការពារឯកជនភាពរបស់ពួកគេ។

## ៧.៤ អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

៧.៤.១ ចៅក្រមសាលាឧទ្ធរណ៍គួរប្រាប់ជនជាប់ចោទអំពីការចោទប្រកាន់លើពួកគេ និងផ្តល់ព័ត៌មានពាក់ព័ន្ធដូចជាកាលបរិច្ឆេទ ទីកន្លែង ភាគីពាក់ព័ន្ធ និងច្បាប់ពាក់ព័ន្ធ។ ចំណុចនេះគឺមានសារសំខាន់ក្នុងករណីដែលការចោទប្រកាន់អាចត្រូវបានប្តូរ ឬកែប្រែចាប់តាំងពីការចាប់ខ្លួន/ចោទប្រកាន់ដំបូង។ ចៅក្រមគួរយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាថាខ្លួនបានប្រាប់អំពីច្បាប់ពាក់ព័ន្ធ និងទីកន្លែងនៃបទល្មើស ដោយសារតែចំណុចទាំងនេះ ភាគច្រើនត្រូវបានមើលរំលង យោងតាមទំព័រ ៤៥ នៃរបាយការណ៍នេះ។

៧.៤.២ ចៅក្រមសាលាឧទ្ធរណ៍គួរផ្តល់ការពន្យល់ពេញលេញអំពីសិទ្ធិទទួលបានការជំនុំជម្រះរបស់ជនជាប់ចោទ។

៧.៤.៣ ចៅក្រមសាលាឧទ្ធរណ៍គួរសួរជនជាប់ចោទដោយផ្ទាល់ថាតើពួកគេយល់ដឹងអំពីការចោទប្រកាន់មកលើខ្លួន និងសិទ្ធិរបស់ខ្លួន ឬទេ។

## ៧.៥ អនុសាសន៍ទាក់ទងនឹងសិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ

៧.៥.១ សាលាឧទ្ធរណ៍ និងអគ្គនាយកដ្ឋានពន្ធនាគារគួរពិគ្រោះយោបល់ និងសម្របសម្រួលជាមួយគ្នាដើម្បីដោះស្រាយបញ្ហាភស្តុភារ និងបញ្ហាការប្រាស្រ័យទាក់ទងគ្នាឱ្យបានឆាប់តាមដែលអាចធ្វើបានទាក់ទងជាមួយទីកន្លែងឃុំខ្លួនរបស់ជនជាប់ចោទចោទ។

៧.៥.២ អគ្គនាយកដ្ឋានពន្ធនាគារចាំបាច់ត្រូវធានាថា ព័ត៌មានស្តីពីការផ្ទេរជនជាប់ឃុំត្រូវបានបញ្ជូនមកឱ្យមហាអយ្យការជាទៀងទាត់ ដើម្បីធានាថាសាលាឧទ្ធរណ៍ផ្តល់ព័ត៌មានទាក់ទងជាមួយកាលបរិច្ឆេទ និងពេលវេលា

នៃសវនាការលើបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ជូនទៅត្រូវមណ្ឌលកែប្រែ ដែលជាកន្លែងជនជាប់ចោទត្រូវបានឃុំខ្លួនឱ្យបានត្រឹមត្រូវ។

៧.៥.៤ ចៅក្រមសាលាឧទ្ធរណ៍គួរពន្យារសវនាការ ប្រសិនបើជនជាប់ចោទពុំមានវត្តមាននៅពេលសវនាការ បើទោះបីជាជនជាប់ចោទនោះមានមេធាវីតំណាងក៏ដោយ លើកលែងតែជនជាប់ចោទបានបោះបង់សិទ្ធិមានវត្តមាននៅពេលសវនាការរបស់ខ្លួនយ៉ាងជាក់ច្បាស់ និងជាផ្លូវការ។

៧.៥.៥ សាលាឧទ្ធរណ៍គួរធានាថានឹងគ្មានទំនាស់ផលប្រយោជន៍កើតឡើងឡើយ ប្រសិនបើមេធាវីម្នាក់តំណាងឱ្យជនជាប់ចោទច្រើននាក់នៅពេលសវនាការ។

៧.៥.៦ ចៅក្រមសាលាឧទ្ធរណ៍គួរប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីរបស់ពួកគេ ប្រសិនបើពួកគេមិនមានមេធាវីតំណាងនោះទេ។

៧.៥.៧ ក្រសួងយុត្តិធម៌គួរផ្តល់ព័ត៌មានអំពីសិទ្ធិទទួលជំនួយផ្នែកច្បាប់ដែលឧបត្ថម្ភដោយរដ្ឋ ដូចជាតាមរយៈការផ្សព្វផ្សាយនៅប៉ុស្តិ៍នគរបាល ពន្ធនាគារ និងអគារតុលាការ។

## ៧.៦ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

៧.៦.១ ចៅក្រមសាលាឧទ្ធរណ៍ត្រូវតែជូនដំណឹងដល់ជនជាប់ចោទឱ្យបានច្បាស់លាស់អំពី៖

- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតដល់ពេលចេញសេចក្តីសម្រេចស្ថាពរ
- អង្គហេតុដែលបន្ទុកនៃភស្តុតាងស្ថិតនៅលើព្រះរាជអាជ្ញា និង
- ថាជនជាប់ចោទមានសិទ្ធិនៅស្ងៀម ដោយមិនប្រើប្រាស់ការនៅស្ងៀមនោះមកប្រឆាំងនឹងពួកគេទេ។

៧.៦.២ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃត្រូវចេញ និងផ្សព្វផ្សាយគោលការណ៍ណែនាំយ៉ាងច្បាស់លាស់ ដោយគូសបញ្ជាក់ថា ជនជាប់ចោទដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬជនដែលត្រូវបានជំនុំជម្រះរួចហើយ ប៉ុន្តែសេចក្តីសម្រេចមិនទាន់ស្ថាពរ ចាំបាច់ត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួនចំពោះមុខតុលាការដោយស្លៀកសម្លៀកបំពាក់ធម្មតា។

៧.៦.៣ ចៅក្រមសាលាឧទ្ធរណ៍គួរអនុញ្ញាតឱ្យជនជាប់ចោទទាំងអស់ដែលត្រូវបាននាំខ្លួនមកសាលាឧទ្ធរណ៍ក្នុងឯកសណ្ឋានទណ្ឌិត ស្លៀកពាក់ឯកសណ្ឋានធម្មតាជំនួសវិញមុនពេលដំណើរការសវនាការ។

៧.៦.៤ ចៅក្រមសាលាឧទ្ធរណ៍គួរតែលើកកម្ពស់ឱ្យមានការប្រើប្រាស់ទោសជំនួសក្រៅពីការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន រួមមានការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[199] ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ១៦.៣.២។

## ៧.៧ អនុសាសន៍ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាង

៧.៧.១ ចៅក្រមសាលាឧទ្ធរណ៍ត្រូវប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិបង្ហាញភស្តុតាងនៅក្នុងលក្ខខណ្ឌដូចគ្នាជាមួយភស្តុតាងដែលត្រូវបានបង្ហាញដើម្បីប្រឆាំងរូបគាត់។

---

[199] អ្នករាយការណ៍ពិសេស "សេចក្តីថ្លែងបញ្ចប់បេសកកម្ម" ទំព័រ ៤ (២០០៨) https://cambodia.ohchr.org/sites/default/files/End%20of%20Mission%20statement%2014%20March%202018.pdf ។

៧.៧.២ ចៅក្រមសាលាឧទ្ធរណ៍គួរបង្គាប់ឱ្យសាក្សីចាកចេញពីបន្ទប់សវនាការ ហើយមិនត្រូវវិលមកកាន់បន្ទប់សវនាការវិញឡើយ រហូតទាល់តែដល់ពេលដែលពួកគេត្រូវបានហៅចូលមកធ្វើសក្ខីកម្ម ជាមធ្យោបាយមួយដើម្បីបញ្ជាក់ថា សាក្សីពុំបានរងឥទ្ធិពលពីភស្តុតាង ឬសក្ខីកម្មដទៃទៀតដែលត្រូវបានបង្ហាញនៅអំឡុងពេលសវនាការ។

៧.៧.៣ ចៅក្រមសាលាឧទ្ធរណ៍ត្រូវវាយតម្លៃដោយប្រុងប្រយ័ត្នថាតើភស្តុតាងដែលត្រូវបានបង្ហាញចំពោះមុខសវនាការអាចបង្កើតមូលដ្ឋានហួសពីវិមតិសង្ស័យដែលបញ្ជាក់ថាជនជាប់ចោទមានពិរុទ្ធភាព ឬអត់។ ប្រសិនបើមានការបកស្រាយនៃភស្តុតាងដែលស៊ីសង្វាក់ជាមួយភាពគ្មានគ្មានទោសរបស់ជនជាប់ចោទ ត្រូវឱ្យជនជាប់ចោទរួចផុតពីបទចោទ។

៧.៧.៤ ក្រសួងយុត្តិធម៌គួរតែរៀបចំគោលការណ៍ណែនាំច្បាស់លាស់ពាក់ព័ន្ធនឹងការបង្ហាញ និងការវាយតម្លៃភស្តុតាង ដោយផ្អែកទៅលើការងាររបស់ អ.វ.ត.ក[200] និងធានាថាចៅក្រមទាំងអស់ទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ។

## ៧.៨ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

៧.៨.១ ធានាថាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយកែសម្រួលនូវព័ត៌មានមួយចំនួននៅពេលចាំបាច់ដើម្បីការពារអត្តសញ្ញាណរបស់ជនជាប់ចោទ ជនរងគ្រោះ ឬសាក្សី ឬដោយសារតែមូលហេតុផ្សេងទៀត។

៧.៨.២ អនុវត្តតាមការអនុវត្តរបស់ អ.វ.ត.ក[201] ដោយបង្កើតក្របខ័ណ្ឌ ដែលចៅក្រមមានកាតព្វកិច្ចប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីមូលហេតុដែលឈានដល់ការសម្រេចទោស និងត្រូវធានាថា សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុត្រូវបានប្រគល់ជូនជនជាប់ចោទ។

## ៧.៩ អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់អនីតិជន

៧.៩.១ ចៅក្រមសាលាឧទ្ធរណ៍គួរតែពន្លឿន និងពង្រឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាពិសេស មាត្រា ៤៧ ដែលចែងថាដំណើរការជំនុំជម្រះ និងការចេញសេចក្តីសម្រេចត្រូវតែធ្វើឡើងនៅក្នុងសវនាការអសាធារណៈ។

៧.៩.២ ចៅក្រមសាលាឧទ្ធរណ៍គួរតែអនុវត្តតាមការប្រតិបត្តិល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអនុញ្ញាតឱ្យជនជាប់ចោទជាអនីតិជនបង្ហាញខ្លួនចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ។

---

[200] ការអនុវត្តល្អរបស់ អ.វ.ត.ក អាចបញ្ជាក់នូវការណែនាំដ៏មានប្រយោជន៍ ជាពិសេសវិធានផ្ទៃក្នុងរបស់ខ្លួន ក៏ដូចជាវាក្យសព្ទ ២០៤ ដល់ ២០៩ នៃបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ សូមមើល "បណ្តឹងសាទុក្ខ" អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតុលាការកំពូល (ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦) សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
<https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/F36_KH.pdf>។

[201] សូមមើល "បណ្តឹងសាទុក្ខ" អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ <https://www.eccc.gov.kh/sites/default/files/documents/courtdoc/2016-11-23%2011:55/Case%20002_01%20Appeal%20Judgement.pdf >។

៧.៩.៣ ចៅក្រមសាលាឧទ្ធរណ៍គួរតែកម្រិតការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន សម្រាប់តែករណីលើកលែងដែលពុំមានជម្រើសផ្សេងទៀត និងធានាថានៅក្នុងករណីបែបនេះ វិធានចាំបាច់ទាំងអស់ត្រូវបានអនុវត្តដើម្បីការពារសិទ្ធិរបស់អនីតិជន។

៧.៩.៤ ក្រសួងយុត្តិធម៌គួរតែធានាថា ចៅក្រម និងព្រះរាជអាជ្ញាបានឆ្លងកាត់ការបណ្ដុះបណ្ដាលជាក់លាក់ទាក់ទងនឹងបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន។

៧.៩.៥ ចៅក្រមសាលាឧទ្ធរណ៍គួរតែពិនិត្យ និងប្រើប្រាស់ទោសជំនួសផ្សេងពីទោសឃុំខ្លួនអនីតិជន និងអនុវត្តគោលការណ៍ណែនាំក្នុងការកាត់ទោសទាក់ទងនឹងអនីតិជន ដោយក្នុងនោះត្រូវផ្ដោតការយកចិត្តទុកដាក់លើការស្ដារនីតិសម្បទារបស់អនីតិជន ជាជាងការផ្ដន្ទាទោសតែមួយមុខ និងលើឧត្តមប្រយោជន៍របស់កុមារ។

៧.៩.៦ សាលាឧទ្ធរណ៍គួរណែនាំអំពីវិធានទូទៅ ដែលសវនាការយុត្តិធម៌កុមារគួរត្រូវបានអនុវត្តនៅក្នុងសវនាការអសាធារណៈ ដោយមានករណីលើកលែងមានកម្រិត ដែលចែងដោយច្បាប់ ដើម្បីគោរពឯកជនភាពរបស់ជនជាប់ចោទជាអនីតិជន។

៧.៩.៧ ក្នុងករណីពាក់ព័ន្ធជនជាប់ចោទជាអនីតិជនដែលត្រូវដំណើរការសវនាការជាសាធារណៈ គួរអនុវត្តវិធានការមួយចំនួន ដើម្បីការពារឯកជនភាពរបស់ជនជាប់ចោទ ដូចជាការប្រើប្រាស់របាំងការពារឯកជនភាព។ សាលាឧទ្ធរណ៍គួរប្រើប្រាស់ប្រព័ន្ធឆ្លើយឆ្លងតាមវីដេអូ ដែលបច្ចុប្បន្នមានរួចហើយនៅសាលាឧទ្ធរណ៍ និងធានាថា មន្ត្រីរបស់ខ្លួនបានទទួលការបណ្ដុះបណ្ដាលពីការប្រើប្រាស់ប្រព័ន្ធនេះ។

៧.៩.៨ ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាគួរអនុវត្តកម្មវិធីបង្វែរដោយក្នុងនោះជនល្មើសជាអនីតិជនបានទទួលការគាំទ្រ និងស្ដារនីតិសម្បទានៅក្នុងសហគមន៍ ជាទោសជំនួសឱ្យការកាត់ទោសជាផ្លូវការ។ កម្មវិធីនេះត្រូវបានអនុវត្តសម្រាប់ជនចាប់ចោទប្រព្រឹត្តបទល្មើសលើកដំបូងគ្រប់រូប លើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។

៧.៩.៩ ក្រសួងយុត្តិធម៌ត្រូវពិនិត្យឡើងវិញលើបទដ្ឋានគតិយុត្តិជាធរមាន រួមទាំងច្បាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅរបស់តុលាការ ដើម្បីធានាអនុលោមតាមបទដ្ឋានអន្តរជាតិស្ដីពីប្រព័ន្ធយុត្តិធម៌អនីតិជន ដោយក្នុងនោះ រួមមានទាំងវិធានជាបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ សម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន ("វិធានក្រុងប៉េងកាំង")។[202] គោលការណ៍ណែនាំរបស់អង្គការយូនីសេហ្វសម្រាប់កំណែទម្រង់ផ្នែកច្បាប់ស្ដីពីយុត្តិធម៌អនីតិជន[203] សៀវភៅជំនួយស្មាតីសម្រាប់ការអនុវត្តរបស់អង្គការយូនីសេហ្វសម្រាប់អនុសញ្ញាស្ដីពី

---

[202] មហាសន្និបាតអង្គការសហប្រជាជាតិ, វិធានជាបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន ("*វិធានក្រុងប៉េងកាំង*")" (ថ្ងៃទី២៩ខែវិច្ឆិកា ឆ្នាំ១៩៨៥) <https://www.ohchr.org/EN/ProfessionalInterest/Pages/BeijingRules.aspx>។

[203] អង្គការយូនីសេហ្វ "គោលការណែនាំសម្រាប់កំណែទម្រង់ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន" <http://www.unicef.org/policyanalysis/files/Juvenile_justice_16052011_final.pdf.>។

សិទ្ធិកុមារ[204] និងរបាយការណ៍កំណែទម្រង់ច្បាប់ និងការអនុវត្តច្បាប់របស់ អង្គការយូនីសេហ្វទាក់ទងនឹង អនុសញ្ញាស្តីពីសិទ្ធិកុមារ។[205]

---

204 អង្គការយូនីសេហ្វ `ការអនុវត្តសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារ´ ទំព័រ ១០៧ <https://www.unicef.org/Implementation_Handbook_for_the_Convention_on_the_Rights_of_the_Child.pdf >។

205 អង្គការយូនីសេហ្វ `កំណែទម្រង់ច្បាប់ និងការអនុវត្តសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារ´ ទំព័រ ៨៦<http://www.unicef-irc.org/publications/pdf/law_reform_crc_imp.pdf>។

# ៨. គន្លឹះនិទ្ទេស

## ៨.១ នីតិជាតិ

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧) https://sithi.org/km/law/2008-08-07-criminal-procedure-code-2007-new ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣ ដូចដែលបានធ្វើវិសោធនកម្ម)
http://www.ccc.gov.kh/admin/uploads/Constitution%20of%20the%20Kingdom%20of%20Cambodia.pdf។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៩) https://sithi.org/km/law/2014-01-31-criminal-code-2014។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ឆ្នាំ២០១៦) https://sithi.org/km/law/2016-06-29-law-on-juvenile-justice។

ច្បាប់ស្តីពីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា (២០១១)។
http://cambodia.ohchr.org/~cambodiaohchr/sites/default/files/Prison%20law%202011%20-%20KHM.pdf។

ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ (ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៩៨)
https://sithi.org/km/law/1998-03-31-proclamation-no-217-on-the-administration-of-prisons-1998។

បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (១៩៩២) https://www.wto.org/english/thewto_e/acc_e/khm_e/WTACCKHM3A3_LEG_11.pdf។

## ៨.២ លិខិតូបករណ៍គោលនយោបាយកម្ពុជា

នាយករដ្ឋមន្ត្រី ហ៊ុន សែន '*សុន្ទរកថាអំពីយុទ្ធសាស្ត្រចតុកោណសម្រាប់ការអភិវឌ្ឍ ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី ២*' (កិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១ នៃអណត្តិទី ៤ នៃរដ្ឋសភា ទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ) (ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨) https://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/---sro-bangkok/documents/genericdocument/wcms_112939.pdf។

ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា "ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ២០១៨-២០២០" ខែធ្នូ ឆ្នាំ២០១៨
https://www.unicef.org/cambodia/sites/unicef.org.cambodia/files/2019-03/JJLSOP_Khmer.pdf ។

## ៨.៣ នីតិអន្តរជាតិ

### សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ '*អនុសញ្ញាស្តីពីសិទ្ធិកុមារ*' (ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩)
https://www2.ohchr.org/english/bodies/crc/docs/CRC.C.GC.10.pdf។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ '*អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប*' (ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨៤)
https://cambodia.ohchr.org/sites/default/files/book/CAT-KH.pdf។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ '*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*' (ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦) http://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf។

អង្គមហាសន្និបាទអង្គការសហប្រជាជាតិ '*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*' (ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨)
http://cambodia.ohchr.org/sites/default/files/Softlaw/BOOKLET_Kh%20V6Low.pdf។

សហភាពអាហ្រ្វិក ធម្មនុញ្ញអាហ្រ្វិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១) https://au.int/sites/default/files/treaties/36390-treaty-0011_-_african_charter_on_human_and_peoples_rights_e.pdf ។

ក្រុមប្រឹក្សាអឺរ៉ុប អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០)

https://www.echr.coe.int/Documents/Convention_ENG.pdf ។

សហភាពអឺរ៉ុប ធម្មនុញ្ញអឺរ៉ុបស្តីពីសិទ្ធិមូលដ្ឋាននៃសហភាពអឺរ៉ុប (ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០០)

https://www.europarl.europa.eu/charter/pdf/text_en.pdf ។

អង្គការរដ្ឋអាមេរិក អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩)

https://www.cidh.oas.org/basicos/english/basic3.american%20convention.htm ។

**ឧបករណ៍ច្បាប់អន្តរជាតិដទៃទៀត**

អង្គការសហប្រជាជាតិ *គោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ* (អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៧ ស្តីពីការបង្ការបទល្មើស និងប្រព្រឹត្តទៅលើជនល្មើស រៀបចំឡើងនៅទីក្រុងមីឡាន ពីថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ១៩៨៥ គាំទ្រដោយសេចក្តីសម្រេចនៃអង្គមហាសន្និបាតលេខ ៤០/៣២) (ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ និង លេខ ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ១៩៨៥)

https៖//www.ohchr.org/EN/ProfessionalInterest/Pages/IndependenceJudiciary.aspx។

អង្គការសហប្រជាជាតិ *គោលការណ៍មូលដ្ឋានស្តីពីមេធាវី* អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៨ ស្តីពីការបង្ការបទល្មើស និងការប្រព្រឹត្តទៅលើជនល្មើសរៀបចំឡើង នៅទីក្រុង ហាវ៉ាណា ប្រទេសគុយបា (នៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ១៩៩០) http://hrlibrary.umn.edu/instree/i3bprl.htm។

